ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី
និងយុត្តិធម៌ (ខុមហ្វ្រែល)

# របាយការណ៍សង្ខេប២០១៥



## ភាពមិនប្រក្រតផ្នែកនយោបាយ៖

### ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ និងអំពើពុករលួយផ្នែកនយោបាយ

ខែ មីនា ឆ្នាំ ២០១៦

# មាតិការឿង


១. សេចក្តីផ្តើម ........ 2

២. បទបញ្ញត្តិច្បាប់ ស្តីពីការហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ........ 4

៣. បទប្បញ្ញត្តិច្បាប់ទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ........ 6

៤. ដែនកំណត់ និងក្របខណ្ឌនៃការប្រើប្រាស់ពាក្យក្នុងរបាយការណ៍ ........ 8

៥. ការរកឃើញ ........ 10

៥.១. ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ........ 10

៥.១.១. ភាពមិនប្រក្រតីនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ........ 14

៥.១.២. ភាពមិនប្រក្រតីនៃតម្លាភាពថវិកាជាតិ ........ 15

៥.២. អំពើពុករលួយទាក់ទងនឹងនយោបាយ ........ 29

៥.២.១. ការរំលោភអំណាចដោយមន្ត្រីនយោបាយជាន់ខ្ពស់ ........ 29

៥.២.២. ភាពមិនប្រក្រតីនៃតំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម (Nepotism, Cronyism) និងទំនាស់ផលប្រយោជន៍ (Conflict of Interest) ........ 30

៥.២.៣. ភាពមិនប្រក្រតីនៃសំណូកនយោបាយ និងការគិបកេងដោយមន្ត្រីនយោបាយមានអាណត្តិ ........ 33

៥.២.៤.ភាពមិនប្រក្រតីនៃសំណូក និងគិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែង ........ 34

៥.៣. ភាពមិនប្រក្រតីនៃទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សសំខាន់ៗ ........ 35

៦. សន្និដ្ឋាន ........ 36

៧. ឧបសម្ព័ន្ធ ........ 38

៧. ១. ឧទាហរណ៍ ឯកសារខ្លះទាក់ទិននឹងគណបក្សប្រជាជនមានរចនាសម្ព័ន្ធក្នុងស្ថាប័នរដ្ឋ ........ 38

៧.២. ឧទាហរណ៍ ឯកសារទាក់ទិននឹងញត្តិគាំទ្រគណបក្សកាន់អំណាច ឬប្រឆាំងគណបក្សជំទាស់ ........ 42

៧.៣. ឧទាហរណ៍ ឯកសារព័ត៌មានចុះផ្សាយស្តីពីការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋបម្រើប្រយោជន៍គណបក្សកាន់អំណាច ........ 47

៧.៤. សារព័ត៌មានចុះផ្សាយទាក់ទិននឹងការចេញផ្សាយនៃរបាយការណ៍ ........ 51

## ១. សេចក្តីផ្តើម

អំពើពុករលួយ មិនមែនជាបញ្ហាអ្វីថ្មីសម្រាប់សង្គមមនុស្សឡើយ។ អំពើពុករលួយមានជាច្រើនបែប ច្រើនសណ្ឋានស្ទើរតែគ្រប់សង្គមទាំងអស់។ បញ្ហានៃអំពើពុករលួយ គឺជាឧបសគ្គរារាំងការអភិវឌ្ឍន៍ប្រទេសដ៏ធ្ងន់ធ្ងរ។ អំពើពុករលួយធ្វើឲ្យបាត់បង់ធនធានសង្គម ដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បង្កើនប្រព័ន្ធអប់រំ និងពង្រឹងសេវាសុខភាពសាធារណៈ។

ផលលំបាកកើតចេញពីអំពើពុករលួយទាំងក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិត្រូវបានគេទទួលស្គាល់។ ជាពិសេស អំពើពុករលួយត្រូវបានគេមើលឃើញថា មានភាពស្រួចស្រាវខ្លាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារលក្ខខណ្ឌនយោបាយនៃប្រទេសនោះផង និងដោយសារអវត្តមាននៃនីតិវិធី និងវិធានការនៃការទប់ស្កាត់។ អំពើពុករលួយ ស៊ីសំណូក និងការក្លែងបន្លំងាយនឹងចាក់ឫសគល់ និងក្លាយទៅជាវប្បធម៌ ឬទម្លាប់ដែលដកមិនងាយចេញ ឬមិនងាយកែប្រែ។ សកម្មភាពខុសច្បាប់ក្លាយជាទម្លាប់សាមញ្ញ ដូចជាការឲ្យលុយដើម្បីពន្លឿនការងារសាធារណៈជាដើម។ នៅពេលដែលអំពើខុសច្បាប់ទាំងនោះប្រមូលផ្តុំច្រើនទៅៗ ថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋនឹងត្រូវធ្លាក់ទៅក្នុងហោប៉ៅឯកជនអ្នកមានអំណាច ឬឥទ្ធិពលដែលនឹងជម្រុញឲ្យប្រជាជនទូទៅ ដែលមិនបានទទួលផលពីអំពើពុករលួយកាន់តែក្រីក្រទៅៗ និងគំរាមកំហែងដល់ស្ថេរភាពនយោបាយនាថ្ងៃអនាគត។ ដោយសារហេតុផលទាំងនេះហើយ ការដោះស្រាយបញ្ហានៃអំពើពុករលួយបានក្លាយទៅជាបន្ទុក មិនត្រឹមតែប្រទេសសាមីឡើយ តែជាការងាររបស់ស្ថាប័នជាន់ខ្ពស់ក្នុងក្របខ័ណ្ឌអន្តរជាតិថែមទៀត ដែលមានធនាគារពិភពលោក អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស ដូចជាអង្គការតម្លាភាពអន្តរជាតិជាដើម។

នៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ចំណុះឲ្យទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែស្ថាប័ននេះមិនអាចដំណើរការការងារបាន រហូតដល់ពាក់កណ្តាលឆ្នាំ២០១០ ដោយសារច្បាប់ប្រឆាំងអំពើពុករលួយ មិនទាន់ត្រូវបានអនុវត្តដោយរដ្ឋសភា។ បន្ទាប់ពីរដ្ឋសភាជាតិបានអនុម័តច្បាប់ប្រឆាំងអំពើពុករលួយនៅក្នុងខែមីនា ឆ្នាំ២០១០ និងត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ អង្គភាពប្រឆាំងអំពើពុករលួយ ដែលជាស្ថាប័នប្រតិបត្តិនៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយត្រូវបានបង្កើតឡើង និងដាក់ឲ្យស្ថិតនៅក្រោមស្ថាប័ននីតិប្រតិបត្តិ និងស្ថិតនៅក្រោមការមើលការខុសត្រូវរបស់នាយករដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥នៃរដ្ឋសភា ក្នុងគោលនយោបាយជាតិក៏បានលើកឡើងនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ថា នឹងបន្តបេសកកម្មរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការធ្វើឱ្យប្រសើរឡើងនូវ

អភិបាលកិច្ច គឺជាកត្តាដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ ស្តីពីការប្រឆាំងអំពើពុករលួយនៅឆ្នាំ២០០៧។ នៅកម្ពុជា យុទ្ធនាការ និងឆន្ទៈរបស់រដ្ឋាភិបាលក្នុងកិច្ចការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានគេមើលឃើញថា នៅមានកំរិតខ្សោយនៅឡើយ ដោយសារតែមន្ត្រីដែលមានតួនាទី និងឋានៈធំៗមានអំណាចនៅតែមានឱកាសប្រព្រឹត្តអំពើពុករលួយ ដោយគ្មានការញញើត និងត្រូវបានចាត់ការប្រឆាំង។ វិធានការរបស់អង្គភាពប្រឆាំងនឹងអំពើពុករលួយនៅមានការយោគយល់ និងអត់ធ្មត់ខ្លាំងជាមួយជនសង្ស័យដែលត្រូវបានប្តឹង និងចោទប្រកាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើពុករលួយ។ ការចាប់ខ្លួន និងការបញ្ជូនខ្លួនទៅតុលាការ ភាគច្រើនជាមន្ត្រីដែលមានឋានៈតួនាទី និងបុណ្យស័ក្តិតូចតាច ហើយការដាក់ទោសទណ្ឌទៅលើជនល្មើសដែលរកឃើញពិរុទ្ធភាពនៃការប្រព្រឹត្តិអំពើពុករលួយ ក៏នៅមានកំរិតស្រាល និងដោយការយោគយល់សណ្តោសប្រណីច្រើន ខណៈដែលជនទាំងនោះបានប្រព្រឹត្តអំពើពុករលួយ ស្ទើរតែពេញមួយជីវិតរបស់ខ្លួនទៅហើយ។ មន្ត្រីនយោបាយធំៗក្នុងជួររដ្ឋាភិបាល បន្តប្រើប្រាស់ធនធានរដ្ឋ និងប្រព្រឹត្តអំពើពុករលួយទាក់ទិននយោបាយខុសច្បាប់។

អំពើពុករលួយនៅក្នុងវិស័យសាធារណៈ នៅមានកំរិតខ្ពស់នៅឡើយ។ មន្ត្រីមានអំណាច និងតួនាទីធំៗក្នុងក្រសួង និងស្ថាប័នរដ្ឋ នៅតែឱកាសប្រព្រឹត្តអំពើពុករលួយដោយការរំលោភ និងបំពានអំណាចដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួក។ អង្គការតម្លាភាពអន្តរជាតិហៅកាត់ថា (TI) បានចាត់ថ្នាក់កម្ពុជាជាប្រទេស ដែលមានអំពើពុករលួយខ្លាំងជាងគេ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន និងមានកម្រិតអំពើពុករលួយខ្ពស់នៅឡើយ ក្នុងពិភពលោកសម្រាប់ឆ្នាំ២០១៥ ខណៈដែលកម្ពុជាទទួលបានលេខរៀង១៥០ ក្នុងចំណោមប្រទេស១៦៨ទូទាំងពិភពលោកដែលបានធ្វើការវាយតម្លៃ។ សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ (CPI) របស់អង្គការតម្លាភាពអន្តរជាតិ ដែលត្រូវបានប្រកាសដោយអង្គការតម្លាភាពនៅកម្ពុជាបានឱ្យដឹងថា ប្រទេសកម្ពុជាបានរក្សាពិន្ទុ២១ លើពិន្ទុ១០០ និងចំណាត់ថ្នាក់លេខរៀង១៥០ ក្នុងចំណោមប្រទេស១៦៨ទូទាំងពិភពលោក ដែលត្រូវបានធ្វើការវាយតម្លៃពីកម្រិតនៃអំពើពុករលួយ។ នៅឆ្នាំ២០១៤កន្លងទៅ កម្ពុជាទទួលបានពិន្ទុ២១ និងមានចំណាត់ថ្នាក់១៥៦ ក្នុងចំណោម១៧៥ប្រទេស។ អង្គការនេះបានពន្យល់ថា អំពើពុករលួយនៅតែជាបញ្ហាចំបង ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលស្ទើរតែគ្មានអ្វីដែលប្រជាពលរដ្ឋអាចទទួលបាន ដោយគ្មានការផ្តល់សំណូកឡើយ។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅមិនទាន់មានប្រសិទ្ធភាព និងគ្រប់គ្រាន់នៅឡើយទេ។(1) ខណៈដែល

---

[1] លោក ឱក សេរីសោភក្ត៏ ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពកម្ពុជា ថ្លែងនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ក្នុងព្រឹត្តិការណ៍បង្ហាញរបាយការណ៍របស់អង្គការតម្លាភាពអន្តរជាតិទូទាំងពិភពលោក នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ភ្នំពេញ។

ការធ្វើកំណែទម្រង់វិស័យមួយចំនួន ត្រូវបានកត់សម្គាល់ និងទទួលបានការស្វាគមន៍ ប៉ុន្តែកំណែទម្រង់ទៅលើស្ថាប័នសាធារណៈនានា ផ្តោតសំខាន់ទៅលើស្ថាប័នសំខាន់ៗប្រព័ន្ធតុលាការ ស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នដែលផ្តល់សេវាសាធារណៈនៅមានកំរិតនៅឡើយ។

អំពើពុករលួយនេះ អាចបណ្តាលមកពីមូលហេតុអ្នកមានអំណាចខាងនយោបាយ និងអ្នកមានឥទ្ធិពលក្នុងការសម្រេចចិត្ត។ អំពើពុករលួយខាងនយោបាយ គឺនិយាយទៅដល់អ្នកមានអំណាចខាងនយោបាយ និងការសម្រេចចិត្តក្នុងតួនាទីដោយប្រើប្រាស់ថវិកាជាតិ ប្រើប្រាស់ធនធានរបស់រដ្ឋ[2] ប្រព្រឹត្តអំពើកិបកេង សំណូក ការរំលោភអំណាច និងការបង្កើតទំនាស់ផលប្រយោជន៍ គ្រួសារនិយម និងបក្សពួកនិយមជាដើម។ ដោយឡែក គុណភាពនៃច្បាប់ប្រឆាំងអំពើពុករលួយ គឺនៅតែមានបញ្ហា ជាពិសេសនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និងកិច្ចការពារអ្នកផ្តល់ព័ត៌មាន ស្តីពីអំពើពុកលួយ ឬសាក្សីនៅមិនទាន់ត្រូវបានចែងជាបទបញ្ញត្តិ ការពារដោយច្បាប់នៅឡើយ។ ច្បាប់ស្តីការប្រឆាំង អំពើពុករលួយត្រូវការធ្វើវិសោធនកម្មនូវមាត្រាមួយចំនួន។

របាយការណ៍នេះ គឺជាអត្ថបទរាយការណ៍សង្កេត និងកត់ត្រា ចងក្រងព័ត៌មាន ទិន្នន័យការប្រើប្រាស់ធនរដ្ឋមិនត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍គណបក្សនយោបាយ និងអំពីអំពើពុករលួយក្នុងវិស័យនយោបាយ ដែលប្រព្រឹត្តដោយមន្ត្រីនយោបាយ ដែលមានតួនាទីពាក់ព័ន្ធកិច្ចការនយោបាយ ព្រមទាំងអំពើបំពានអំណាច ច្បាប់ទាំងឡាយណាដែលប្រព្រឹត្តដោយមន្ត្រីរាជការសាធារណៈក្នុងមុខតំណែង និងតួនាទី ក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍នយោបាយនៃគណបក្សណាមួយ។

## ២. បទបញ្ញត្តិច្បាប់ ស្តីពីការហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិ និងសេរីភាពក្នុងការអនុវត្តន៍សិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋដើម្បីចូលរួមក្នុងសង្គម និងកិច្ចការនយោបាយដោយគ្មានដោយការរើសអើង។ ទោះបីយ៉ាងណាក៏ដោយ រដ្ឋសភាបានអនុម័តច្បាប់មួយចំនួន ដូចជាច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤[3] និងច្បាប់ស្តីពីវិសោធនកម្មឆ្នាំ១៩៩៩[4] ច្បាប់ស្តីពីគណបក្សនយោបាយឆ្នាំ១៩៩៧[5] ច្បាប់ស្តីពីលក្ខន្តិកៈទូទៅ

---

[2] ធនធានរដ្ឋ សំដៅទៅលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់រដ្ឋទាំងអស់ (ចលនទ្រព្យ និងអចលនទ្រព្យ ទ្រព្យរូបិយ និងអរូបិយរបស់រដ្ឋ) ហើយក្នុងនោះក៏រាប់បញ្ចូលផងដែរ នូវបុគ្គលិក ឬមន្ត្រីរាជការរបស់រដ្ឋ។

[3] មាត្រា៣៧ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការស៊ីវិលត្រូវមានអព្យាក្រិតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្ម ភាពនយោបាយដូចខាងក្រោម៖

- ធ្វើការដើម្បីផលប្រយោជន៍បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណា មួយ។
- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។
- ការប្រព្រឹត្តផ្ទុយនឹងមាត្រានេះ ចាត់ទុកជាកំហុស និងការវ្តាំឆ្គងក្នុងវិជ្ជាជីវៈ។

[4] មាត្រា ៣៧ មានចែងអំពីអព្យាក្រិតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្ម ភាពនយោបាយ របស់មន្ត្រីរាជការស៊ីវិល។

[5] មាត្រា១៥ កថាខណ្ឌទី២ ផ្តល់សិទ្ធិ សេរីភាព ដល់បព្វជិត មន្ត្រីតុលាការ និងកងយោធពលខេមរភូមិន្ទ អាចក្លាយជាសមាជិកនៃគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តបាន ប៉ុន្តែមានការហាមឃាត់មិនឲ្យពួកគេធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ

ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទឆ្នាំ១៩៩៧[6] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៥[7] បានកំណត់នូវសិទ្ធិ និងសកម្មភាពមួយចំនួន លើសិទ្ធិនយោបាយចំពោះមន្ត្រីរាជការ ដូចមានចែងក្នុងក្របខ័ណ្ឌនៃច្បាប់ខាងលើដែលការកំណត់សិទ្ធិនេះ គឺក្នុងគោលបំណងដើម្បីធានានូវឯករាជ្យភាព អព្យាក្រឹត្យភាព គុណតំលៃ ប្រពៃណីរបស់ក្រុមពលរដ្ឋទាំងនោះ។ ច្បាប់បានដៅច្បាស់ទៅលើមន្ត្រីរបស់រដ្ឋ ប៉ុន្តែមិនរាប់បញ្ចូលមន្ត្រីជាប់ឆ្នោត ឬមន្ត្រីនយោបាយរបស់រដ្ឋាភិបាល។[8]

មន្ត្រីរបស់រដ្ឋ គឺសំដៅទៅដល់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលជាដើម។ ក្រុមទាំងនេះ រួមជាមួយបុព្វជិត(ព្រះសង្ឃ)ផងដែរ មិនត្រូវបានអនុញ្ញាតឲ្យចូលរួម ក្នុងសកម្មភាពគាំទ្រ ឬប្រឆាំងទៅលើគណបក្សនយោបាយណាមួយឡើយ បើទោះបីជាក្រុមប្រជាជនទាំងនេះមានសិទ្ធិក្នុងការបោះឆ្នោត និងបញ្ចេញឆន្ទៈនយោបាយតាមរយៈសន្លឹកឆ្នោត និងជាសមាជិកគណបក្សនយោបាយណាមួយ ឬអាចចូលរួមជាបេក្ខជនក្នុងការបោះឆ្នោត។ ច្បាប់ខាងលើ ជាពិសេសច្បាប់បោះឆ្នោតនេះ បានហាមឃាត់ក្រុមប្រជាជនខាងលើ មិនឲ្យសំដែងលេចចេញជាសកម្មភាពជោកជាំ ផុសផុល សកម្មក្នុងសកម្មភាពបម្រើផលប្រយោជន៍ឲ្យគណបក្សនយោបាយណាមួយ។ ចំណែកច្បាប់ស្តីពីគណបក្សនយោបាយ បានហាមឃាត់គណបក្សនយោបាយ ក្នុងការរៀបចំរចនាសម្ព័ន្ធចាត់តាំងនៅក្នុងស្ថាប័នសាសនា តុលាការ កងកម្លាំងប្រដាប់អាវុធ និងនគរបាលជាតិ។ ដូច្នេះ ជនទាំងឡាយណា ឬគណបក្សណាមួយដែលបានប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់ដែលលើកឡើងខាងលើ គឺវាជាអំពើអនីត្យានុកូល

---

ឡើយ ហើយគណបក្សនយោបាយទាំងនោះ ក៏មិនអាចមានសិទ្ធិក្នុងការរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ។

[6] សូមអានមាត្រា៩, ១០ និង១០នៃច្បាប់នេះច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ឆ្នាំ១៩៩៧។ មាត្រា៩នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ យោធិនមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត។ ក៏ប៉ុន្តែការប្រើសិទ្ធិ និងសេរីភាពខ្លះ ត្រូវមានការកម្រិត ស្រមតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ។

[7] មាត្រា៨២នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០១៥។ បញ្ញត្តិនៃមាត្រានេះ ហាមឃាត់មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការនូវសកម្មភាព ដូចជាការប្រើប្រាស់ឥទ្ធិពល អំណាចតួនាទីរបស់ខ្លួន ដោយប្រយោល ឬផ្ទាល់ទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬប្រយោល ឬជាលាយលក្ខណ៍អក្សរ ក្នុងន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឲ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យជាដើម ការប្រើប្រាស់អាគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនារកសម្លេងឆ្នោតឲ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ ការចូលរួមឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។ មាត្រានេះបានចែងអំពោះសកម្មភាពដែលត្រូវហាមឃាត់ដល់មន្ត្រីរាជការ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការពីរប្រភេទ (ទី១) គឺជាការហាមទូទៅ មិនចំពោះ លើសកម្មភាពនានាដូចដែលមានចែងក្នុងកថាខណ្ឌទី១ និងទី(២) គឺជាការហាមឃាត់ចំពោះមន្ត្រីរាជការ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច។ សកម្មភាពទាំងនោះ រួមមានការហាមមិនឲ្យធ្វើជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ មិនឲ្យចូលរួមការជួបជុំ ឬការចូលរួមដង្ហែក្បួន និងព្យុហយាត្រាដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ សកម្មភាពដើរស្ទង់មតិពលរដ្ឋបម្រើឲ្យគណបក្សនយោបាយ, ការបើកបរយានជំនិះរបស់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ សកម្មភាពចែកអំណោយ សម្ភារៈឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោតក្នុងគោលបំបណងបម្រើផលប្រយោជន៍គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ធ្វើសេចក្តីថ្លែងការណ៍សារធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ចូលរួមលេងភ្លេង ប្រគំតន្ត្រី ឬច្រៀង ឬផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសម្លេង ដើម្បីគាំទ្រគណបក្ស ឬបេក្ខជនណាម្នាក់។

[8] មន្ត្រីនយោបាយ គឺរាប់ចាប់ពីតំណែងឋានៈរដ្ឋលេខាធិការ រដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រី។

ឬបំពានច្បាប់។

### ៣. បទប្បញ្ញត្តិច្បាប់ទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

កម្ពុជាមានច្បាប់ និងវិធានច្រើនគួរសមដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល។ ក្នុងរបាយការណ៍នេះ អំពើពុករលួយទាក់ទងនឹងនយោបាយ គឺសំដៅដល់ការរំលោភ ឬបំពានអំណាចរបស់មន្ត្រីនយោបាយ ខ្សែស្រឡាយ ឬសាច់ញាតិនិយម ទំនាស់ផលប្រយោជន៍របស់មន្ត្រីនយោបាយ ភាពមិនប្រក្រតីនៃសំណូក (សូកប៉ាន់ និងស៊ីសំណូក) ឬកិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែងខ្ពស់ ដែលចំណុចទាំងអស់នេះត្រូវបានហាមឃាត់ និងមានចែងក្នុងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ និងបញ្ញត្តិមួយចំនួនក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពិសេសផ្សេងៗទៀត។

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ មានចែងអំពីគោលបំណង គោលដៅ វិសាលភាព និងនិយមន័យនៃអំពើពុករលួយ។ ទី១៖ គោលបំណងនៃច្បាប់នេះ គឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ច និងនីតិរដ្ឋនៅក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌ ដែលជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍន៍សង្គមជាតិ និងកាត់បន្ថយភាពក្រីក្រ[9]។ ទី២៖ គោលដៅនៃច្បាប់នេះ គឺដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការចាត់វិធាន ការអប់រំ បង្ការទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាប់បទល្មើសពុករលួយ ហើយដោយមានការចូលរួម និងគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ[10]។ ទី៣៖ វិសាលភាពនៃច្បាប់នេះ គឺអនុវត្តចំពោះអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្ត ក្រោយពេលដែលច្បាប់នេះមានអានុភាពអនុវត្ត។[11] និងទី៤៖ និយមន័យបានហាមមន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់ឆ្នោតដោយអាណត្តិពីបទរំលោភអំណាច ក្នុងការបំពេញមុខងារ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ[12]។

តាមពិត ច្បាប់ប្រឆាំងអំពើពុករលួយ គឺជាព្រហ្មទណ្ឌពិសេសដាច់ដោយឡែក ដែលមានកំណត់បន្ថែមអំពីអំពើល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ ដែលបទល្មើសទាំងនោះ ភាគច្រើនមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩រួចស្រេចទៅហើយ ហើយបញ្ញត្តិទាំងអស់ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ២០០៩ទាំងនោះ ក៏មិនបានចូលជាធរមានភ្លាមៗ ក្រោយពីរដ្ឋសភាអនុម័តដែរ។

---

[9] មាត្រា១ នៃច្បាប់ប្រឆាំងអំពើពុករលួយ។

[10] មាត្រា២ នៃច្បាប់ប្រឆាំងអំពើពុករលួយ។

[11] មាត្រា៣ នៃច្បាប់ប្រឆាំងអំពើពុករលួយ។

[12] មាត្រា ៣៥ -បទរំលោភអំណាច អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់៤.០០០.០០០(បួនលាន)រៀលទៅ១០.០០០.០០០(ដប់លាន)រៀល។ បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព។

មាតិកាទី៣ ដែលមានចែងអំពីការធ្វើឲ្យប៉ះពាល់ដល់ដំណើរការរដ្ឋបាលសាធារណៈ គឺចែកជាពីរជំពូក ដែលជំពូកទី១ និយាយអំពីអំពើល្មើសដែលប្រព្រឹត្តដោយអ្នកតំណាង តំណាងអាជ្ញាធរសាធារណៈ និងជំពូកទីពីរ និយាយអំពីអំពើល្មើសដែលប៉ះពាល់ដល់រដ្ឋបាលសាធារណៈប្រព្រឹត្តឡើងដោយបុគ្គលឯកជន។ ជំពូកទី១នៃមាតិកាទី៣នេះ ទើបតែបានចូលជាធរមាននៅក្រោយវិសោធនកម្មច្បាប់ប្រឆាំងអំពើពុករលួយប៉ុណ្ណោះ។ នៅក្នុងជំពូកទី១នៃមាតិកាទី៣នេះ មានបែងចែកជាបួនផ្នែកថែមទៀត[13] ក្នុងនោះរួមមាន បទល្មើសដែលពាក់ព័ន្ធនឹងអំពើរំលោភអំណាច[14] បទរំលោភអំណាចប្រឆាំងនឹងបុគ្គល[15] អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល (រួមមាន *បទល្មើស វិតិក្រម អំពើស៊ីសំណូក ជំនួញឥទ្ធិពលអកម្ម អំពើការកេងយកប្រយោជន៍ដោយខុសច្បាប់ និងបក្ខានុគ្រោះ)* ការបំផ្លាញ និងការគៃបំបាត់[16] និងការប៉ុនប៉ង និងទណ្ឌកម្មលើជនល្មើសដែលប្រព្រឹត្តក្នុងជំពូកទី១នៃមាតិកាទី៣នេះ។ ជំពូកទី៦ ជាពិសេសមាត្រា៣២នៃច្បាប់នេះ បានកំណត់បទល្មើសពុករលួយទាំងអស់ ដែលមានចែងស្រាប់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។[17]

និយមន័យនៃអំពើពុករលួយនយោបាយ ដែលត្រូវបានឱ្យនិយមន័យដោយអង្គការតម្លាភាពកម្ពុជា អំពើពុករលួយនយោបាយជា"*ការកេងបន្លំធនធាន គោលនយោបាយ ធនធានស្ថាប័នរដ្ឋដែលប្រព្រឹត្តដោយអ្នកនយោបាយដែលមានអំណាច ឬមន្ត្រីរាជការក្នុងតំណែង ដោយការរំលោភអំណាច និងតួនាទីរបស់ខ្លួន ដើម្បីរក្សា ឬបង្កើនតំណែង តួនាទី ឋានន្តរសក្តិ លាភសក្ការៈ ពង្រឹងអំណាច ការយោគយល់ និងដើម្បីផលប្រយោជន៍របស់ខ្លួន និងក្រុមគ្រួសារ សាច់ញាតិ បក្សពួករបស់ខ្លួន*"។

---

13 ផ្នែកទី១៖ ការមិនគោរពកាតព្វកិច្ច (មាត្រា៥៨៦ ដល់មាត្រា៥៩១) ផ្នែកទី២៖ អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល (មាត្រា៥៩២ ដល់មាត្រា៦០០) ផ្នែកទី៣៖ ការបំផ្លាញ និងការគៃបំបាត់ (មាត្រា៦០១ និងមាត្រា៦០២) និងផ្នែកទី៤៖ អំពីការប៉ុនប៉ង និងទណ្ឌកម្ម។

14 ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា៥៨៦ និងមាត្រា៥៨៧។

15 មាត្រា ៥៨៨ ដល់មាត្រា ៥៩១។

16 មាត្រា ៦០១ និងមាត្រា៦០២។

17 ក្រៅពីបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ (*មាត្រា៣២ ដល់មាត្រា៤៩ នៃច្បាប់ប្រឆាំងអំពើពុករលួយ*) បទល្មើសដែលមានចែងនៅក្នុងមាត្រា ២៧៨ (បទស៊ីសំណូកនៃនិយោជិត) មាត្រា២៧៩ (បទសូកប៉ាន់ដល់នៃនិយោជិត) មាត្រា២៨០ (បទស៊ីសំណូករបស់អភិបាលជាអាទិ) មាត្រា៣៨៧ (បទដេញថ្លៃមិនត្រឹមត្រូវ) មាត្រា៤០៤ (និយមន័យនៃការសម្អាតប្រាក់) មាត្រា ៤០៥ (ទោសដែលត្រូវអនុវត្ត) មាត្រា៤០៦ (ស្ថានទម្ងន់ទោស) មាត្រា៤០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា៥១៧ (បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម) មាត្រា៥១៧ (បទសូកប៉ាន់ចំពោះចៅក្រម ) មាត្រា៥១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា៥៤៧ (បទស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ) មាត្រា៥៤៨ (បទសូកប៉ាន់សាក្សី) មាត្រា៥៥៣ (បទស៊ីសំណូករបស់អ្នកបកប្រែ) មាត្រា៥៥៤ (បទសូកប៉ាន់អ្នកបកប្រែ) មាត្រា៥៥៣ (បទស៊ីសំណូករបស់អ្នកជំនាញ) មាត្រា៥៥៦ (បទសូកប៉ាន់អ្នកជំនាញ) មាត្រា៥៥៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា៥៩២ (និយមន័យនៃវីតិក្រម) មាត្រា៥៩៣ (ទោសដែលត្រូវអនុវត្ត) មាត្រា៥៩៤ (បទស៊ីសំណូក) មាត្រា៥៩៥ (និយមន័យនៃជំនួញឥទ្ធិពលអកម្ម) មាត្រា៥៩៦ (ទោសដែលត្រូវអនុវត្ត) មាត្រា៥៩៧ (និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់) មាត្រា ៥៩៨ (ទោសដែលត្រូវអនុវត្ត) មាត្រា៥៩៩ (និយមន័យនៃបក្ខានុគ្រោះ) មាត្រា៦០០ (ទោសដែលត្រូវអនុវត្ត) មាត្រា៦០១ (បទបំផ្លាញដោយចេតនា និងគៃបំបាត់ដោយទុច្ចរិត) មាត្រា៦០៥ (បទសូកប៉ាន់) មាត្រា៦០៦ (បទឥទ្ធិពលសកម្ម) មាត្រា៦០៧ (បទសម្លុតគំរាម) មាត្រា៦០៨ (បទបំផ្លាញ និងគៃបំបាត់) មាត្រា៦២៥ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា៦៣៧ (បទស៊ីសំណូកដោយអ្នកមាននីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីលិខិតបញ្ជាក់មិនពិត) មាត្រា៦៣៩ (បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា៦៤០ (បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា៦៤១ (ការអនុវត្តន៍បទមជ្ឈឹមនៃមាត្រា៦៣៦ និង៦៤០ ចំពោះគ្រប់វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ) និងមាត្រា៦២២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌជាបទល្មើសពុករលួយដែលត្រូវអនុវត្តតាមច្បាប់នេះ។

សម្រាប់លិខិតូបករណ៍អន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ដែលគោលបំណងនៃអនុសញ្ញានេះ គឺដើម្បីលើកកម្ពស់ និងពង្រឹងវិធានការដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយកាន់តែមានប្រសិទ្ធភាព និងមានប្រសិទ្ធភាពលើកកម្ពស់ សម្រួល និងគាំទ្រដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយបច្ចេកទេសក្នុងការបង្ការ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមទាំងការស្រោចស្រង់ទ្រព្យសម្បត្តិ ដែលបាត់បង់ដោយសារអំពើពុករលួយ និងដើម្បីលើកកម្ពស់សុចរិតភាព គណនេយ្យភាព និងការគ្រប់គ្រងត្រឹមត្រូវនៃកិច្ចការ និងទ្រព្យសម្បត្តិសាធារណៈ។

អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ បានតម្រូវឱ្យរដ្ឋភាគី ត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗ ដូចជាករណីដែលពាក់ព័ន្ធនឹងការរំលោភតួនាទី ការកិបកេង/កេងប្រវ័ញ្ច និងការស៊ីសំណូករបស់មន្ត្រីសាធារណៈរបស់រដ្ឋ[18]។ល។

## ៤. ដែនកំណត់ និងក្របខណ្ឌនៃការប្រើប្រាស់ពាក្យក្នុងរបាយការណ៍

ខាងក្រោមនេះ គឺជាពាក្យគន្លឹះ ប្រើនៅក្នុងរបាយការណ៍ដែលត្រូវបានកំណត់ និងបកស្រាយ។

៤.១.*ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍នយោបាយ (Misuse of State Resource for Political Interest)*៖ ធនធានរដ្ឋ រួមមាន ការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ទ្រព្យសម្បត្តិទាំងចលនទ្រព្យ និងអចលនទ្រព្យ ទ្រព្យសម្បត្តិរដ្ឋទាំងរូបីយ និងអរូបីយ។ ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ គឺសំដៅទៅលើអំពើល្មើសច្បាប់ទាំងឡាយណាដែលច្បាប់ណាមួយបានចែង អំពីការហាមឃាត់ការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ប្រព័ន្ធផ្សព្វផ្សាយ សំភារៈ ឧបករណ៍ អាគារ ទីធ្លាសាធារណៈ ការិយាល័យ មន្ត្រីរាជការ យោធិន និង

---

[18] មាត្រា១៩ ការរំលោភតួនាទី៖ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗដែលចាំបាច់ ដោយការប្តេជ្ញាជាសាកលក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងអំពើ ការរំលោភមុខងារ ឬតួនាទី ដូចជាការរំលោភបំពានលើការបំពេញការងារ/មុខងារ ឬ ឬការមិនបានបំពេញមុខងារ ឬតួនាទីឲ្យបានត្រឹមត្រូវ ការប្រព្រឹត្តល្មើសច្បាប់ ដោយមន្ត្រីសាធារណៈណាម្នាក់ ក្នុងខណៈពេលដែលខ្លួនកំពុងកាន់មុខងារ ក្នុងគោលបំណងឆ្លៀតឱកាសកេងចំណេញហួសហេតុ ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់ជនដទៃ ឬសម្រាប់អង្គភាព។

មាត្រា១៧ ការប្រព្រឹត្តទុច្ចរិតដោយការកេងប្រវ័ញ្ច ការប្រព្រឹត្តមិនសមរម្យ ឬការបន្លំបង្វែរទ្រព្យសម្បត្តិ ដោយមន្ត្រីសាធារណៈ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗដែលចាំបាច់ ដោយការប្តេជ្ញាជាសាកល ដើម្បីកំណត់ឲ្យមានបទល្មើសព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិទុច្ចរិតដោយការកេងប្រវ័ញ្ច ការប្រព្រឹត្តិមិនសមរម្យ ឬការបន្លំបង្វែរទ្រព្យសម្បត្តិ មូលនិធិ ឬមូលធនប័ត្រ ឬវត្ថុមានតំលៃរបស់បុគ្គលឯកជន ឬសាធារណៈ ដោយមន្ត្រីសាធារណៈណាម្នាក់ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន បម្រើផលប្រយោជន៍ជនដទៃ ឬអង្គភាពរបស់ខ្លួន ហើយដែលវត្ថុ ឬទ្រព្យសម្បត្តិទាំងនេះ ត្រូវបានគេផ្តល់សេចក្តីទុកចិត្តឲ្យមន្ត្រីសាធារណៈរូបនោះ ក្នុងក្របខណ្ឌនៃការបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ។

មាត្រា១៥ ការប្រព្រឹត្តិស៊ីសំណូករបស់មន្ត្រីសាធារណៈរបស់រដ្ឋ រដ្ឋភាគី ត្រូបង្កើតច្បាប់ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗដែលចាំបាច់ដោយការប្តេជ្ញាជាសាកល ដើម្បីកំណត់ឲ្យមានបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ (ក)សន្យាការធ្វើជាអំណោយ ការផ្តល់ឲ្យជាសគុណដល់មន្ត្រីសាធារណៈរូបណាមួយ ទោះបីដោយប្រយោលក្តី ដោយផ្ទាល់ក្តី ក្នុងបំណងទុច្ចរិតដើម្បីទាញផលប្រយោជន៍សម្រាប់ខ្លួនគាត់ជាមន្ត្រីផ្ទាល់ ឬសម្រាប់ជនដទៃ ឬអង្គភាពរបស់ខ្លួន ដោយអំពើទាំងនេះបានញ៉ាំងឲ្យខ្លួនជាមន្ត្រីសាធារណៈ មិនបានបំពេញតួនាទីរបស់ខ្លួន។ (ខ) ការអន្ទង ឬការទទួលដោយមន្ត្រីសាធារណៈ ដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ក្នុងគោលបំណងឆ្លៀងឱកាសទាញផលប្រយោជន៍ហួសហេតុដើម្បីបម្រើផលប្រយោជន៍ខ្លួនឯងផ្ទាល់ ឬដើម្បីជន*ដទៃ ឬដើម្បីបម្រើផលប្រយោជន៍អង្គភាពរបស់ខ្លួន ដោយអំពើនេះបានញ៉ាំងឲ្យខ្លួនជាមន្ត្រីសាធារណៈ មិនបានបំពេញតួនាទីរបស់ខ្លួន។*

ថវិការបស់រដ្ឋ ដើម្បីបម្រើផលប្រយោជន៍នយោបាយឲ្យគណបក្សយោបាយណាមួយ (ដូចជាប្បញ្ញត្តិដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះអាជ្ញា ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន និងកងយោធពលខេមរភូមិន្ទ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលស្រុក/ខណ្ឌ/ខេត្តក្រុង។ល។) ក៏ចាត់ទុកថា ជាការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវផងដែរនូវការខ្វះតម្លាភាព និងភាពមិនប្រក្រតីនៃការគ្រប់គ្រងថវិកាជាតិ។

៤.២.*អំពើពុករលួយទាក់ទងនឹងនយោបាយ*៖ គឺ(១)សំដៅការរំលោភអំណាច ការប្រើប្រាស់សិទ្ធិអំណាចជាមន្ត្រីនយោបាយ ដើម្បីផលប្រយោជន៍ដល់សាច់ញាតិ និងខ្សែស្រឡាយបក្សពួកនិយម (Nepotism and Cronyism) (២)ភាពមិនប្រក្រតីក្នុងសំណូក និងការកិបកេងដោយមន្ត្រីមន្ត្រីនយោបាយ ដោយមន្ត្រីសាធារណៈក្នុងតំណែង ក្នុងបំណងដើម្បីផលប្រយោជន៍ខ្លួន និងគ្រួសារ និងផលប្រយោជន៍បក្ស។

៤.២.១.*ការរំលោភ/បំពានអំណាច*៖ គឺជាការប្រើប្រាស់សិទ្ធិអំណាច តួនាទី និងសមត្ថកិច្ចដែលកំណត់ដោយច្បាប់ ដោយមន្ត្រីនយោបាយជាន់ខ្ពស់ដែលការប្រើប្រាស់សិទ្ធិ តួនាទី និងសមត្ថកិច្ចនោះ លើសពីអ្វីដែលច្បាប់ចែង ឬគ្មានច្បាប់ចែង ឬរំលោភបទប្បញ្ញត្តិច្បាប់ដែលកំពុងចែងជាធរមាន។ ការបំពាននេះ អាចឈានដល់ការរំលោភគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន និងគោលការណ៍ប្រជាធិបតេយ្យបែងចែកអំណាច និងនីតិរដ្ឋ ដោយធ្វើយ៉ាងណាដើម្បីប្រយោជន៍នយោបាយរបស់ខ្លួន។

៤.២.២.*តំណែងសម្រាប់ខ្សែស្រឡាយ ឬសាច់ញាតិនិយម* (Cronyism and Nepotism)៖ សំដៅលើករណីការការពារ និងការផ្តល់ផលប្រយោជន៍ដោយលម្អៀងដល់ខ្សែស្រឡាយ សាច់ញាតិបង្កើត ដូចជាម្តាយ ឪពុក បងប្អូនបង្កើត កូន រួមទាំងប្តី ឬប្រពន្ធ ជាពិសេសអ្នកដែលទទួលបានតំណែងដោយគ្មានតម្លាភាពក្នុងស្ថាប័នរដ្ឋ ដែលខ្លួនជាមន្ត្រីរដ្ឋនយោបាយ ឬមន្ត្រីសាធារណៈក្នុងតំណែងដឹកនាំ ឬគ្រប់គ្រង។

៤.២.៣.ទំនាស់ផលប្រយោជន៍(Conflict of Interest) និងវិសមិតភាព(Incapability) របស់មន្ត្រីនយោបាយ៖ សំដៅទៅមន្ត្រីរដ្ឋនយោបាយដែលបានប្រើប្រាស់ឥទ្ធិពល និងតួនាទីរបស់ខ្លួនក្នុងការសម្រេចចិត្ត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនជាខ្សែស្រឡាយ ឬសាច់ញាតិខ្លួន ឬមន្ត្រីនយោបាយនោះជាសមាជិករដ្ឋាភិបាល។

៤.២.៤.ភាពមិនប្រក្រតីនៃសំណូក (Irregularity of Giving or Gaining Bribe and Inducement)៖ សំដៅការចោទប្រកាន់ និងទឡ្ហីករណ៍អំពីការស៊ីសំណូក និងសូកប៉ាន់ ឬកិបកេងថវិការដ្ឋដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែង។ ករណីភាពមិនប្រក្រតី គឺស្ថិតនៅកម្រិតការចោទប្រកាន់ និងទឡ្ហីករណ៍ដោយបុគ្គលសាធារណៈ ឬអ្នកសារព័ត៌មានដែលទុកជាការបាន។

៤.២.៥.មន្ត្រីនយោបាយ សំដៅលើសមាជិករាជរដ្ឋាភិបាល និងសមាជិកមន្ត្រីជាប់ឆ្នោត (មានអាណត្តិតាមការបោះឆ្នោត) ថ្នាក់ជាតិ និងមូលដ្ឋាន។ មន្ត្រីសាធារណៈរបស់រដ្ឋក្នុងតំណែង សំដៅមន្ត្រីមានឋានៈ និងតំណែងចាប់ពីឋានៈការិយាល័យ ឬស្ថាប័នផ្សេងទៀតដែលមានឋានៈស្មើ រហូតដល់អគ្គនាយក និងស្ថាប័នផ្សេងទៀតដែលមានឋានៈស្មើ។

ការសង្កេតធ្វើឡើងដោយពឹងផ្អែកទៅលើ ការប្រមូលព័ត៌មានដែលមានស្រាប់ នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញរបស់អង្គការខុមហ្វ្រែលនៅតាមគ្រប់រាជធានី/ខេត្ត។ ដោយឡែកសារព័ត៌មានអនឡាញ គេហទំព័ររបស់ស្ថាប័នពាក់ព័ន្ធ របាយការណ៍ និងការបោះពុម្ពរបស់ស្ថាប័នផ្សេងៗក៏ត្រូវបានប្រើប្រាស់ក្នុងការប្រមូលព័ត៌មាន ស្តីពីអំពើពុករលួយនយោបាយ និងយកមកធ្វើជាប្រភពក្នុងការវិភាគក្នុងអត្ថបទនេះដែរ។ របាយការណ៍ត្រូវបានដកស្រង់ទាំងនោះរួមមានដូចជាអង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងយុត្តិធម៌ និងស្ថាប័នរដ្ឋផ្សេងៗ គេហទំព័ររបស់គណបក្សនយោបាយ របាយការណ៍របស់អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិផ្សេងៗជាដើម។

## ៥. ការរកឃើញ

ការសង្កេត ដោយកត់ត្រាទុកក្នុងប្រព័ន្ធរក្សាទិន្នន័យ ក្នុងអំឡុងពេលចន្លោះពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៥ រកឃើញយ៉ាងហោចណាស់មានសរុប២៩៧ករណី ភាពមិនប្រក្រតីទាក់ទិននឹងនយោបាយ រួមមានការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ សំរាប់បម្រើផលប្រយោជន៍គណបក្សនយោបាយ និងអំពើពុករលួយផ្នែកនយោបាយ។ ករណីទាំងអស់នេះ គឺជាការប្រមូលតាមរយៈសារព័ត៌មានដែលចុះផ្សាយទាំងអនឡាញ និងបោះពុម្ព ព្រមទាំងបណ្តាញរបស់អង្គការខុមហ្វ្រែលនៅតាមខេត្ត/រាជធានីទូទាំងប្រទេស។ អំពីអត្រានៃករណីនៃភាពមិនប្រក្រតីនៃការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍គណបក្សនយោបាយមាន១៣៣ករណី [19] ខណៈដែលករណីពាក់ព័ន្ធនឹងការរំលោភអំណាចធ្ងន់ធ្ងរ ប្រព្រឹត្តដោយថ្នាក់ដឹកនាំជាន់ខ្ពស់នយោបាយ សមាជិករាជរដ្ឋាភិបាល សមាជិកសភា និងស្ថាប័នតុលាការមាន១១ករណី។ អំពីអត្រានៃករណីភាពមិនប្រក្រតីនៃសំណូក និងកិបកេង ដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈក្នុងតំណែង គឺមានចំនួន១៣៥ករណី។ ករណីពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃការតែងតាំង ឬដាក់បញ្ចូលខ្សែស្រឡាយ សាច់ញាតិនិយមមាន៨ករណី ជាករណីកើតឡើងបន្ថែម និងភាពមិនប្រក្រតីសំណូក និងការកិបកេងប្រព្រឹត្តដោយមន្ត្រីនយោបាយមានអាណត្តិដោយការបោះឆ្នោតមាន១១ករណី។

## ៥.១. ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ

ការសង្កេតយកចិត្តទុកដាក់ទៅលើការប្រើប្រាស់ធនធានរដ្ឋ រួមទាំងធនធានមនុស្ស សំភារៈប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីផលប្រយោជន៍គណបក្សកាន់អំណាច និង

---

[19] ករណីដែលបានប្រមូល និងកត់ត្រា គឺធ្វើឡើងចំពោះតែការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ (មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីតុលាការ) និងការប្រើប្រាស់ធនធានសម្ភារៈរបស់រដ្ឋ (អាគារ យានយន្ត)។

តម្លាភាពនៃថវិកាជាតិ។ មានការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ បម្រើឱ្យគណបក្សនយោបាយ ចំនួន១៣៣ករណី ស្មើនឹង៤៤,៧%នៃករណីដែលបានកត់ត្រាទាំងអស់(២៩៧ករណី) ក្នុងនោះ គឺជាករណីនៃការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ដូចជាការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការស៊ីវិលដែលក្នុងរបាយការណ៍ គឺបានរកឃើញថា កងកម្លាំងប្រដាប់អាវុធ ជាពិសេសថ្នាក់ដឹកនាំនៃកងកម្លាំងប្រដាប់អាវុធដែលមានឋានន្តរៈខ្ពស់ៗ ជាថ្នាក់នាយឧត្តមសេនីយ៍ និងឧត្តមសេនីយ៍ និងមន្ត្រីសាធារណៈក្នុងតំណែងផ្សេងៗទៀត និងការប្រើប្រាស់ធនធានសំភារៈរបស់រដ្ឋ ដូចជាអាគារ និងយានយន្តជាដើម។ សម្រាប់ការប្រើប្រាស់ធនធានរដ្ឋផ្សេងៗទៀត ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក្នុងការធ្វើសកម្មភាពប្រឆាំង ឬគាំទ្រចំពោះគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្សផ្សេងៗ និងភាពមិនប្រក្រតីនៃការគ្រប់គ្រងថវិកាជាតិ គឺមិនអាចកំណត់ជាចំនួនករណីបានទេ។

ចំនួននេះបានកើនឡើងចំនួន៧៣ករណី បើប្រៀបធៀបនឹងរយៈពេល១ឆ្នាំនៃឆ្នាំ២០១៤កន្លងទៅ ដែលមានតែ៦០ករណីប៉ុណ្ណោះ គឺស្មើនឹង៤៥ភាគរយ។ មូលហេតុដែលមានកំណើនច្រើនជាងឆ្នាំ២០១៤នេះ អាចជាមូលហេតុដូចតទៅ ទី១៖ គណបក្សនយោបាយ ជាពិសេសគណបក្សជាប់ឆ្នោតទាំងពីរ មានការប្រកួតប្រជែងប្រកៀកប្រកិតគ្នា ក្រោយការបោះឆ្នោតឆ្នាំ២០១៣ និងដោយសារលទ្ធផលបោះឆ្នោតក្នុងអាណត្តិកន្លងទៅ មានអាសនៈប្រដំត្រសងគ្នាខ្លាំងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលជាហេតុធ្វើឲ្យក្រុមការងារគណបក្សកាន់អំណាចខិតខំចុះជួយមូលដ្ឋានយ៉ាងសស្រាក់សស្រាំ ទៅតាមគោលដៅក្រុមការងារចុះជួយ ដែលកំណត់ជារចនាសម្ព័ន្ធដោយថ្នាក់ដឹកនាំគណបក្ស។ ទី២៖ មានព្រឹត្តិការណ៍មួយចំនួនដែលធ្វើឲ្យគណបក្សកាន់អំណាចចលនាឲ្យមន្ត្រីរបស់រដ្ឋ គាំទ្រផលប្រយោជន៍ឲ្យគណបក្សរបស់ខ្លួន ដូចជាព្រឹត្តិការណ៍នៃការបោះឆ្នោតទម្លាក់លោក កឹម សុខា ពីតំណែងជាអនុប្រធានរដ្ឋសភាទី១ ព្រឹត្តិការណ៍ការផ្ទៀងផ្ទាត់ផែនទី និងបញ្ហាព្រំដែនកម្ពុជា វៀតណាម ព្រឹត្តិការណ៍ការដកអភ័យឯកសិទ្ធិសមាជិកសភានៃមេដឹកនាំគណបក្សប្រឆាំងជាដើម ហើយស្ទើរតែគ្រប់ស្ថាប័ន ក្រសួងរបស់រដ្ឋ ពិសេសការប្រើប្រាស់កងកំលាំងប្រដាប់អាវុធដើម្បីធ្វើជាញត្តិគាំទ្រ ការប្តេជ្ញាចិត្ត ស្បថស្បែ និងការថ្លែងសារនយោបាយលម្អៀងទៅរកគណបក្សកាន់អំណាចគំរាមកំហែង បំភិតបំភ័យជាអាទិ។ សកម្មភាពជួបប្រជុំ ឬកម្មវិធីនានាដែលរៀបចំដោយគណបក្សកាន់អំណាច ដែលដឹកនាំដោយប្រធានក្រុមការងារថ្នាក់ជាតិ តំបន់របស់គណបក្ស ក្រោយពីការបោះឆ្នោតរយៈពេលជាងពីរឆ្នាំនេះ គឺហាក់ដូចជាមានសកម្មភាពផុលផុសខ្លាំង។ ទី៣៖ មូលហេតុនៃការប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់ឆ្នាំ២០១៥នេះ គឺគ្របដណ្តប់បានច្រើន។ ក្នុងចំណោម១៣៣ករណីនេះ មាន៥៦ករណី (ប្រហែល៤២%) ប្រព្រឹត្តដោយមន្ត្រីរាជការស៊ីវិលជាប្រធានអង្គភាព មន្ត្រីនយោបាយនៃស្ថាប័នរាជរដ្ឋាភិបាល/ស្ថាប័នរដ្ឋ និងមាន៧០ករណី(ប្រហែល៥៣%) ប្រព្រឹត្តដោយកងម្លាំងប្រដាប់អាវុធ ក្នុងនោះភាគច្រើន គឺប្រព្រឹត្តដោយមន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ មាន

ថ្នាក់នាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ និងស្នងការជាដើម។ ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍ឲ្យគណបក្សកាន់អំណាច កើតមានស្ទើរគ្រប់ខេត្ត/រាជធានី លើកលែងខេត្តពីរចេញ ដែលមិនមានព័ត៌មានពាក់ព័ន្ធនឹងករណីរំលោភនេះ គឺខេត្តប៉ៃលិន និងខេត្តស្ទឹងត្រែង។ រាជធានីភ្នំពេញត្រូវបានរកឃើញករណីរំលោភនេះច្រើនជាងគេ គឺមានរហូតដល់៤២ករណីក្នុងចំណោម១៣៣ករណី បន្ទាប់មកមានខេត្តកណ្ដាលមាន១៣ករណី និងខេត្តព្រះវិហារមាន១០ករណី និងខេត្តមួយចំនួនទៀតមានច្រើនជាង១ករណី និងតិចជាង១០ករណី។ ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវនេះ គឺមានតែ២ករណីគត់ ដែលត្រូវបានដោះស្រាយ/ចាត់វិធានការ។ ករណីលើសលប់ គឺពាក់ព័ន្ធនឹងការដឹកនាំ កៀងគរមន្ត្រីក្រោមឱវាទចុះជួយសកម្មភាព ចុះពង្រឹងមូលដ្ឋានតាមរយៈក្រុមការងារចុះជួយ និងគណៈពង្រឹងខេត្ត/រាជធានី ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់បម្រើឲ្យគណបក្សកាន់អំណាច។ ស្ទើរតែ១០០ភាគរយ គឺត្រូវបានរកឃើញថា សកម្មភាពទាំងអស់នោះ បម្រើផលប្រយោជន៍ឲ្យគណបក្សកាន់អំណាច។ ការប្រើប្រាស់ធនធានមនុស្ស និងសម្ភារៈរបស់រដ្ឋដើម្បីបម្រើផលប្រយោជន៍នយោបាយនេះ ក្នុងចំណោម១៣៣ករណី មាន៤៦ករណីស្មើនឹង៣៤,៥ភាគរយ ដែលរកឃើញថាធ្វើសកម្មភាពនៅថ្ងៃឈប់សម្រាក និងមាន៨៦ករណីស្មើនឹង៦៤,៦៦ភាគរយ ធ្វើសកម្មភាពនៅថ្ងៃធ្វើការ (ម៉ោងការងាររដ្ឋ)។

ការសង្កេតបានបែងចែកការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឱ្យគណបក្សនយោបាយជាពីរ គឺការចូលរួមធ្វើសកម្មភាពក្នុងថ្ងៃធ្វើការ និងថ្ងៃឈប់សម្រាករបស់មន្ត្រីសាធារណៈរបស់រដ្ឋក្នុងតំណែង រួមទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដើម្បីបម្រើសកម្មភាពផលប្រយោជន៍គណបក្សនយោបាយ ជាពិសេសគណបក្សកាន់អំណាចដែលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺមានរៀបចំដោយរចនាសម្ព័ន្ធចាត់តាំងជាក្រុមការងារ ឬក្រុមការងារចុះជួយថ្នាក់ជាតិ និងសេនាធិការរបស់ថ្នាក់ជាតិ គឺថ្នាក់ខេត្ត ស្រុកខណ្ឌ រហូតដល់ឃុំ/សង្កាត់។ សកម្មភាពនៅក្រៅប្រទេស គេសង្កេតឃើញមានមន្ត្រីការទូតបម្រើការនៅស្ថានទូតកម្ពុជាប្រចាំបរទេស បានធ្វើសកម្មភាពមួយចំនួន បម្រើផលប្រយោជន៍គណបក្សកាន់អំណាចជាប្រព័ន្ធ និងបំពេញភារកិច្ចការងារជារាជការដោយមានរើសអើង។ ឧទាហរណ៍ ករណីកើតឡើងនៅប្រទេសកូរ៉េខាងត្បូង ដែលនៅប្រទេសនេះ មានពលករចំណាកស្រុកជាជនជាតិខ្មែរ មានប្រមាណជាជិត៥០ម៉ឺននាក់ កំពុងធ្វើការងារនៅទីនោះ។ លោក ស៊ុត ឌីណា អគ្គរាជទូតកម្ពុជាប្រចាំប្រទេសកូរ៉េ ត្រូវបានគេមើលឃើញថា ជាមនុស្សដែលសកម្មបំផុត ក្នុងកិច្ចការងារបម្រើផលប្រយោជន៍នយោបាយឲ្យគណបក្សកាន់អំណាច។ ក្រៅពីករណីលោក ស៊ុត ឌីណា របាយការណ៍បានកត់ត្រាផងដែរ នូវករណីឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីសប្រទេសបារាំង។ អ្នកនាំពាក្យគណបក្សកាន់អំណាចបានបញ្ជាក់ថា គណបក្សបានផ្តល់ និងដាក់ភារកិច្ច និងការទទួលខុសត្រូវឲ្យដល់មន្ត្រីការទូតប្រចាំស្ថានទូតខ្មែរនៅបរទេស ដើម្បីការងាររបស់បក្សនៅក្រៅប្រទេសមានប្រសិទ្ធភាព។ ករណីនៃការប្រើប្រាស់ធនធានមនុស្ស និងធនធានសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើផលប្រយោជន៍នយោ

បាយមានកើតឡើងនៅ២៤ ក្នុងចំណោម២៦រាជធានី/ខេត្ត ព្រមទាំងនៅក្រៅប្រទេសកម្ពុជា។ ដោយឡែក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងព្រះវិហារមានករណីប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឱ្យគណបក្សនយោបាយច្រើនជាងគេ បើប្រៀបធៀបជាមួយខេត្តផ្សេងៗទៀត។ ពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើផលប្រយោជន៍ គណបក្សកាន់អំណាច ខុមហ្វ្រែលសង្កេតឃើញថា គណបក្សកាន់អំណាចបានប្រើប្រាស់ក្រសួង ស្ថាប័នរបស់រដ្ឋធ្វើជាសាខារបស់គណបក្ស និងបានបង្កើតរចនាសម្ព័ន្ធចាត់នៅក្នុងនោះ ឧទាហរណ៍ ដូចជា គណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្មរ៉ែ និងថាមពល គណៈកម្មាធិការគណបក្ស ក្រសួងឧស្សាហកម្ម និងសិប្បកម្មជាដើម។

របាយការណ៍បានសន្និតថា ស្ទើរតែទាំងអស់នៃមន្ត្រីសាធារណៈក្នុងតំណែង គឺបានក្លាយជាមន្ត្រីនយោបាយថ្នាក់ក្រោមជាតិរបស់គណបក្សកាន់អំណាច។ រចនាសម្ព័ន្ធចាត់តាំងឲ្យទទួលខុសត្រូវកាន់កាប់តំបន់ចុះជួយ និងក្រុមការងារចុះជួយរបស់បក្ស គឺជាភស្តុតាងស្រាប់។ មន្ត្រីឋានៈធំៗនៅតាមក្រសួង និងស្ថាប័នរដ្ឋទាំងអស់ត្រូវបានគណៈគ្រប់គ្រង ឬថ្នាក់ដឹកនាំរបស់ខ្លួន តំរូវឲ្យចុះមូលដ្ឋានធ្វើសកម្មភាពដើម្បីចុះជួយបក្ស។ មន្ត្រីរាជការនៅតាមស្ថាប័នរដ្ឋស្ទើរទាំងអស់ ត្រូវបានគេបង្ខំឲ្យបំពេញទម្រង់សមាជិកបក្សជាដាច់ខាត និងជាញឹកញាប់ គឺត្រូវបានកំណត់ឲ្យបង់វិភាគទានផងដែរ។

ក្នុងឆ្នាំ២០១៥ករណី ដែលលេចធ្លោជាងគេនៃការប្រើប្រាស់មន្ត្រីសាធារណៈ ក្នុងមុខតំណែង ជាពិសេស គឺការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ដើម្បីបម្រើផលប្រយោជន៍គណបក្សកាន់អំណាច គឺការថ្លែងសារនយោបាយល្មើសនឹងច្បាប់កងទ័ពរបស់នាយឧត្តមសេនីយ៍ជាន់ខ្ពស់ម្នាក់ក្នុងជួរកងទ័ព និងការប្រមូល និងកៀងគរឲ្យមន្ត្រីកងកម្លាំងប្រដាប់អាវុធ យោធិនចេញសេចក្តីថ្លែងការណ៍ប្រឆាំងនឹងលោក កឹម សុខា។ ករណីមួយផ្សេងទៀត គឺលោកនាយឧត្តមសេនីយ៍ផ្កាយ៤ ជា តារា បានថ្លែងនៅចំពោះមុខមន្ត្រីយោធា មន្ត្រីរដ្ឋាភិបាល និងវិស័យឯកជននៅវិមានសន្តិភាពថ្ងៃទី២៩ ខែកក្កដា ដោយលោកនិយាយសម្តីស្មោះត្រង់របស់ខ្លួនថា កងទ័ពត្រូវការចូលរួមការពារជាតិ និងការពារមិនឲ្យមានបដិវត្តន៍ពណ៌៖ *«បើនិយាយឲ្យចំកងទ័ព គឺជារបស់គណបក្សប្រជាជន ព្រោះសម្តេចតេជោជាអ្នកចិញ្ចឹម បីបាច់ ថែរក្សា ដឹកនាំបញ្ជាកងទ័ព»*[20]។ មួយវិញទៀត ការបញ្ចូលមន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាន់ខ្ពស់ចូលទៅជាសមាជិកសកម្ម ឬសមាជិកគណៈកម្មាធិការកណ្តាលរបស់គណបក្សកាន់អំណាច គឺជានិន្នាការដែលកំពុងតែកើតមានឡើងនៅកម្ពុជា និងកំពុងតែត្រូវបានចងជារចនាសម្ព័ន្ធចាត់តាំង នៅគ្រប់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការបញ្ចូលមន្ត្រីជាន់ខ្ពស់នៃកងកំលាំងប្រដាប់អាវុធថ្នាក់នាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ ស្នងការ មន្ត្រីតុលាការ ចៅក្រម និងព្រះរាជ្ញាជាសមាជិកគណៈ

---

20 ប្រាថ្នា ចេវ, *លោកផ្កាយមាស៤ ជា តារា ថាកងទ័ពជាទ័ពរបស់គណបក្សប្រជាជនកម្ពុជា*, RFA, 29, 07, 2015. http://www.rfa.org/khmer/news/politics/Dara-said-RCAF-is-belong-to-CPP-07282015235842.html

កម្មាធិការកណ្តាលរបស់បក្ស និងជាសមាជិក សមាជិការបស់បក្ស គឺវាបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតដល់ឯករាជ្យភាព អព្យាក្រឹត្យភាពនៃកងកម្លាំងប្រដាប់អាវុធ និងតុលាការ ព្រមទាំងនីត្យានុកូលភាពនៃនីតិរដ្ឋផងដែរ។ មានការព្រួយបារម្ភច្រើនអំពីផលប៉ះពាល់ដល់ដំណើរការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងបញ្ហានៃការផ្ទេរអំណាចទៅគណបក្សឈ្នះឆ្នោតផ្សេងទៀត។ ករណីគណបក្សកាន់អំណាចបច្ចុប្បន្ន មិនទទួលបានជោគជ័យ ក្នុងការបោះឆ្នោតនៅអាណត្តិខាងមុខបន្តបន្ទាប់ ថាតើគណបក្សកាន់អំណាចនឹងសុខចិត្តប្រគល់អំណាចទៅឲ្យគណបក្សដែលឈ្នះឆ្នោតដែរឬទេ នៅពេលដែលខ្លួនចាញ់ឆ្នោត ខណៈដែលបច្ចុប្បន្ននេះរចនាសម្ព័ន្ធយោធា និងកងកម្លាំងប្រដាប់អាវុធ តុលាការ គឺស្ថិតនៅក្នុងកណ្តាប់ដៃនៃគណបក្សកាន់អំណាចមួយនេះយ៉ាងរឹងមាំបំផុតទៅហើយនោះ? ក៏មានផងដែរ ការគំរាមកំហែងប្រើកងម្លាំងប្របដាប់អាវុធដើម្បីការពាររដ្ឋាភិបាលដែលដឹកនាំដោយ គឺគណបក្សប្រជាជន។

### ៥.១.១. ភាពមិនប្រក្រតីនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ

ការអង្កេតទៅលើទូរទស្សន៍ជាតិកម្ពុជា ហៅកាត់ថា «ទទក» គឺមិនបានរាប់ចេញជាករណីឡើយ គឺខុមហ្វ្រែលបានធ្វើការអង្កេត និងតាមដានត្រឹមតែអំពីកំរិតលំអៀងនៃការផ្សាយរបស់«ទទក»។

ទូរទស្សន៍ជាតិកម្ពុជា ហៅកាត់ថា «ទទក» ជាទូរទស្សន៍ជាតិ។ មានកម្មវិធីជាច្រើនដែលបុស្តិ៍ទូរទស្សន៍ជាតិកម្ពុជា ត្រូវមានកាតព្វកិច្ចក្នុងការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ និងគណបក្សផ្សេងៗទូទៅដែរ។

បើទោះជាការផ្សព្វផ្សាយពីកម្មវិធីរបស់ជាតិ ជាតួនាទីរបស់ទូរទស្សន៍ជាតិក៏ដោយ ក៏ក្រុមអ្នកអង្កេតព័ត៌មានរបស់អង្គការខុមហ្វ្រែល ផ្អែកតាមដានពីកម្មវិធីផ្សាយបានសង្កេតឃើញថា កម្មវិធីផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជាក្នុងឆ្នាំ២០១៥កន្លងមក មិនបានដើរតួនាទីជាទូរទស្សន៍របស់ជាតិដែលផ្សព្វផ្សាយកម្មវិធីជាតិប្រកបដោយតម្លាភាព និងឯករាជ្យ។ ភាគច្រើន កម្មវិធីផ្សាយទូរទស្សន៍មួយនេះ លម្អៀងមានទំនោរទៅរកបក្សកាន់អំណាចដែលកំពុងដឹកនាំរដ្ឋាភិបាល។ ការផ្សព្វផ្សាយនីមួយៗ តែងតែផ្សារភ្ជាប់ជាមួយនឹងការលើកកម្ពស់នូវគោលនយោបាយ និងសកម្មភាពរបស់គណបក្សកាន់អំណាច ដូចជាសកម្មភាពរបស់តំណាងរាស្ត្របក្សកាន់អំណាចទាំងចុះក្នុងមូលដ្ឋាន និងទៅក្រៅប្រទេស គឺទូរទស្សន៍មួយនេះបានផ្សព្វផ្សាយលើកសរសើរពីសកម្មភាពទាំងនោះថា ជាតំណាងរាស្ត្រសកម្មចេះយល់ទុក្ខធុរៈដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋជាគំរូដ៏ល្អសម្រាប់ប្រជាពលរដ្ឋជឿទុកចិត្ត និងមិនភ្លេចទេពីការផ្សារភ្ជាប់នូវគុណសម្បត្តិប្រវត្តិនៃគណបក្សកាន់អំណាចទៅនឹងសកម្មភាពរបស់តំណាងរាស្ត្រទាំងនោះ។

ដោយឡែក សកម្មភាពរបស់តំណាងរាស្ត្រក្រៅពីបក្សកាន់អំណាច គឺមិនត្រូវបានទូរទស្សន៍មួយនេះមិនបានផ្សព្វផ្សាយឡើយ បើទោះជាចុះទៅបេសកកម្មក្រៅប្រទេស ឬចុះមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋក៏ដោយ តែបើផ្សាយវិញ គឺផ្សាយបន្ទុះបង្អាប់ពីសកម្មភាពរបស់

អ្នកតំណាងរាស្ត្រនោះទៅវិញ។ រីឯការផ្សាយដែលមើលទៅកាន់តែឆ្លងពីតួនាទីជាទូរទស្សន៍ជាតិនោះ គឺរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល មិនថានាយករដ្ឋមន្ត្រី ឬសមាជិករដ្ឋាភិបាលទេ រួមទាំងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ចាប់ពីថ្នាក់កំពូលរហូតដល់ថ្នាក់មូលដ្ឋាន ការផ្សាយពីសកម្មភាពទាំងអស់តែងតែផ្សារភ្ជាប់ជាមួយនឹងគុណសម្បត្តិ និងប្រវត្តិតស៊ូរបស់គណបក្សប្រជាជនកម្ពុជាជានិច្ច បង្ហាញពីភាពរឹងមាំរបស់បក្សគណបក្សកាន់អំណាច និងអំណាចបុគ្គលរបស់លោកនាយករដ្ឋមន្ត្រីដែលកំពុងដឹកនាំរដ្ឋាភិបាល។

ប្រសិនបើមានបញ្ហាអ្វីមួយដែលកើតមានក្នុងប្រទេស ដូចជាការតវ៉ារបស់កម្មករ កម្មការិនីដើម្បីសុំទាមទារលក្ខខណ្ឌិកៈការងារសមរម្យ ការតវ៉ារបស់សហគមន៍មានជម្លោះដីធ្លី លំនៅដ្ឋានសុំរកដំណោះស្រាយ ការតវ៉ារបស់អង្គការសមាគម បណ្ដាញយុវជនដើម្បីការពារផលប្រយោជន៍ជាតិមានព្រៃឈើ ទន្លេ បរិស្ថានជាដើម ទូរទស្សន៍មួយនេះតែងតែផ្សាយពីទង្វើទាំងនោះថា ខុសច្បាប់ទាំងអស់ ព្រោះធ្វើឱ្យប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ។

ជារួមទៅ ទូរទស្សន៍មួយនេះផ្សាយព័ត៌មានអំពីសកម្មភាព លើកតម្កើងបុគ្គលច្រើនជាងផ្សាយពីសកម្មភាពដើម្បីជំរុញដំណើរការអភិវឌ្ឍន៍ក្នុងប្រទេស ហើយបានប្រែក្លាយពីទូរទស្សន៍ដែលបម្រើផលប្រយោជន៍ឱ្យជាតិ ទៅជាគាំទ្រសកម្មភាពបុគ្គល និងបក្សទៅវិញ។ ពេលខ្លះសូម្បីតែបុគ្គលម្នាក់ជាថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាលដើរលេងជាមួយគ្រួសារ ប្រើជីវិតឯកជនលំហែកាយក៏ទូរទស្សន៍នេះលើកមកផ្សាយដែរ។

សរុបជារួមមក ក្នុងឆ្នាំ២០១៥កន្លទៅថ្មីៗនេះ កម្មវិធីផ្សាយទូរទស្សន៍ជាតិកម្ពុជា ៧០%នៃព័ត៌មាន គឺលម្អៀងខាងនយោបាយគណបក្សកាន់អំណាច ដែលមិនបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ទូទៅក្នុងប្រទេស ក្នុងនាមជាទូរទស្សន៍ដែលប្រើថវិការបស់ជាតិទេ។ របាយការណ៍សង្កេតឃើញថា ទូរទស្សន៍ជាតិបានប្រើពាក្យច្រើនរាប់ពាន់ពាក្យថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចតេជោ នាយករដ្ឋមន្ត្រី ទើបធ្វើឱ្យប្រទេសមានភាពរីកចម្រើន ហើយនៅក្នុងកម្មវិធីដទៃទៀតក៏មានដូចគ្នានេះដែរ។

### ៥.១.២. ភាពមិនប្រក្រតីនៃតម្លាភាពថវិកាជាតិ

#### ៥.១.២.១ ភាពមិនប្រក្រតីនៃច្បាប់ថវិកាជាតិ

តម្លាភាពនៃការគ្រប់គ្រងថវិកានៅកម្ពុជា គឺនៅតែមានស្ថានភាពប្រហាក់ប្រហែលឆ្នាំមុនដដែល មិនមានភាពប្រសើរជាងឆ្នាំមុនៗឡើយ។ ក្នុងឆ្នាំ២០១៥នេះ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់អាក្រក់ជាងគេក្នុងលេខរៀងទី៧ក្នុងពិភពលោក(21)។ របាយការណ៍នៃអង្គការអន្តរជាតិដែលមានឈ្មោះថា International Budget Partnership(IBP) បានរកឃើញថា ការផ្សព្វផ្សាយព័ត៌មានអំពីការរៀបចំថវិកាជាតិ ឬព័ត៌មាន ស្ដីអំពីការផ្សព្វផ្សាយថវិកាជាតិទាំងមូល ការទទួលបានព័ត៌មាន ស្ដីពីថវិកាជាតិ និងដំណើរការនៃការរៀបចំថវិកាជាតិ (សេចក្ដីព្រាងថវិកា

---

[21] TAYLOR O'CONNELL AND KANG SOTHEAR, *Cambodia Seventh Worst for Budget Transparency, Report Finds*, The Cambodia Daily, NOVEMBER 18, 2015.

ជាតិ) ដោយមានការចូលរួមដោយសាធារណៈ និងដំណើរការនៃការរៀបចំថវិកាជាតិ មានការចូលរួមដោយមានការចូលរួមពីសាធារណៈ គឺមានសន្ទស្សន៍បានត្រឹមតែ៨ពិន្ទុនៃ១០០ពិន្ទុប៉ុណ្ណោះ[22]។ ពិន្ទុនេះវាទាបមែនទែន បើធៀបជាមួយប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំង១០ប្រទេស និងប្រទេសដ៏ទៃទៀតក្នុងពិភពលោក។ សេចក្ដីព្រាងច្បាប់ថវិកាជាតិ ដែលត្រូវដាក់ឲ្យត្រួតពិនិត្យដោយស្ថាប័ននីតិបញ្ញត្តិ គឺមិនទាន់មានការឆ្លុះបញ្ចាំងពីតម្លាភាព មានន័យថា របាយការណ៍ស្ដីពីការចំណាយ និងចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជា គឺភាគីរដ្ឋាភិបាលមិនបានបង្ហាញអំពីរបាយការណ៍លម្អិតទូលំទូលាយ និងច្បាស់លាស់នៅឡើយ ហើយការស្នើសុំត្រួតពិនិត្យពីសមាជិករដ្ឋសភា ទៀតសោតដើម្បីសិក្សាស្វែងយល់ស៊ីជម្រៅ ក៏មិនត្រូវបានឆ្លើយតបឲ្យបានក្បោះក្បាយ និងច្បាស់លាស់ ដែលនេះបានដាក់ជាមន្ទិលសង្ស័យយ៉ាងខ្លាំងទៅលើតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងថវិកាជាតិរបស់ខ្លួន។ រដ្ឋសភាគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាលម្អិតទៅលើសេចក្ដីព្រាងច្បាប់ថវិកាជាតិ។ នៅក្នុងឆ្នាំ២០១៥នេះ កម្ពុជាទទួលបានពិន្ទុ៥៨ លើ១០០ពិន្ទុពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ។

រដ្ឋសភា មិនបានបង្កើតក្រុមសិក្សាស្រាវជ្រាវឯករាជ្យ ឬស្ថាប័នជំនាញណាមួយធ្វើការឲ្យបានល្អិតល្អន់អំពីបញ្ហានៃច្បាប់ថវិកាជាតិនេះឡើយ។ ការរៀបចំពង្រាងថវិកាជាតិ ត្រូវបានគេមើលឃើញថា មានការចូលរួមពីសាធារណៈយ៉ាងតិចតួចបំផុត ឬស្ទើរតែគ្មាន។ រាជរដ្ឋាភិបាលកម្ពុជាមិនបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន និងសមាជិកនៃរដ្ឋសភាជាតិ អំពីព័ត៌មានលំអិតសមរម្យអំពីថវិកាជាតិ និងសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានន័យថា តម្លាភាពនៃថវិកាជាតិមិនទាន់ឆ្លុះបញ្ចាំងនូវភាពត្រឹមត្រូវស្អាតស្អំនៅឡើយ។ កត្តានេះបង្កការលំបាកដល់ប្រជាពលរដ្ឋ និងរដ្ឋសភាក្នុងការតាមដានការចាយវាយរបស់រាជរដ្ឋាភិបាល និងការទាមទារឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការគ្រប់គ្រងប្រាក់កាសសាធារណៈរបស់ខ្លួនដែលរួមមាន ការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិសាធារណៈនានាប្រកបដោយប្រសិទ្ធភាព។ ដោយឡែក ឯករាជ្យភាព និងសមត្ថភាព និងសមត្ថកិច្ចនៃស្ថាប័នសវនកម្មជាតិ *(អគ្គសវនកម្ម)* នៅមានកំរិតនៅឡើយ។ របាយការណ៍នៃអង្គការអន្តរជាតិដដែលនេះបានបង្ហាញថា ការធ្វើសវនកម្មទៅលើកញ្ចប់ថវិកាជាតិ រួមមានការចំណាយ និងចំណូលរបស់ស្ថាប័នជាតិ គឺនៅមានកម្រិតនៅឡើយ ដោយទទួលបានត្រឹមតែ៥៨ពិន្ទុនៃ១០០ពិន្ទុប៉ុណ្ណោះ។ អគ្គសវនកម្មជាតិ នៅតែមិនមានអំណាចក្នុងការធ្វើការងាររបស់ខ្លួនក្នុងក្រសួង និងស្ថាប័នធំៗមួយចំនួន ដូចជាក្រសួងការពារជាតិ និងទីស្ដីការគណៈរដ្ឋមន្ត្រីជាដើម។

រដ្ឋសភាជាតិ ក្នុងឆ្នាំ២០១៥នេះ បានអនុម័តច្បាប់ ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងខែមករា ឆ្នាំ២០១៦ នូវច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០១៤។ សំរាប់ច្បាប់ ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ

---

[22] *Transparency (Open Budget Index) 8/100*, International Budget Partnership, 2015; available at http://www.internationalbudget.org/wp-content/uploads/OBS2015-CS-Cambodia-English.pdf

២០១៣ តំណាងរាស្រ្តគណបក្សសង្គ្រោះជាតិ លោក សុន ឆៃ បានរិះគន់ថា ក្រសួងសំខាន់ៗ ដូចជាក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច និងក្រសួងអភិវឌ្ឍន៍ជនបទ បានចាយថវិកាដែលផ្តល់ឲ្យមិនអស់ ខណៈតម្រូវការសំរាប់ប្រជាជនមានច្រើន។ តំណាងរាស្រ្តគណបក្សប្រឆាំង ក៏បានរិះគន់ទីស្តីការគណៈរដ្ឋមន្រ្តី ក្នុងការចំណាយថវិការដ្ឋច្រើនលើសការកំណត់។ តំណាងរាស្រ្តក៏បានចោទប្រកាន់ពីការបាត់បង់ចំណូលថវិកាជាតិច្រើន ការចំណាយថវិកាជាតិមិនសមស្រប និងខ្ជះខ្ជាយ[23] ។

ដោយឡែក នៅក្នុងខែធ្នូឆ្នាំ២០១៥ រដ្ឋសភាបានប្រជុំត្រួតពិនិត្យ និងបានអនុម័តលើសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលតំណាងរាស្រ្តបក្សប្រឆាំងបានរិះគន់ថា មានចំណុចមិនប្រក្រតីច្រើន ការប្រមូលពន្ធដារ និងពន្ធគយមានភាព «*មិនប្រក្រតីច្រើន*» ដោយលោកចាត់ទុកថា នាំឲ្យមានការបាត់បង់ថវិកាជាតិរាប់រយលានដុល្លារសម្រាប់ឆ្នាំ២០១៤[24]។

សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងសេចក្តីព្រាងច្បាប់ ស្តីពីគណនេយ្យ និងសវនកម្មត្រូវបានរដ្ឋសភាពអនុម័តនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ដោយគ្មានសំឡេងគាំទ្រពីគណបក្សប្រឆាំង។ តំណាងរាស្រ្តគណបក្សប្រឆាំង លោក សុន ឆៃ អនុប្រធានគណៈកម្មការទី១នៃរដ្ឋសភាបានលើកឡើងថា *បើនៅក្នុងច្បាប់នេះ ការប្រមូលពន្ធដារ និងពន្ធគយសម្រាប់ឆ្នាំ២០១៤ មានការកើនឡើងជាង១០ភាគរយ តែលោករិះគន់ថា ការប្រមូលនោះមានភាពធូររលុង និងមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ*។ លោកបន្តថា *ការប្រមូលពន្ធដី ពន្ធផ្ទះ ដីសម្បទាន និងពន្ធអចលនទ្រព្យផ្សេងៗមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ និងនៅមានភាពខ្វះខាតនៅឡើយ*។ ដោយឡែកពីនេះ រាជរដ្ឋាភិបាលក៏មានភាពធូររលុងទៅលើក្រុមហ៊ុនដែលជំពាក់លុយផងដែរ និងម៉្យាងវិញទៀត "*ការប្រមូលពន្ធដារគយ នៅមានរបៀបដដែលៗ ដែលជាហេតុធ្វើឲ្យបាត់បង់ចំណូលរដ្ឋតាមការប៉ាន់ស្មានប្រហែល៨០០ ទៅ៩០០ លានដុល្លារ*។

សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤នេះ ត្រូវបានតំណាងរាស្រ្តគណបក្សសង្គ្រោះជាតិ និងអង្គការសង្គមស៊ីវិល អង្គការស្រាវជ្រាវអន្តរជាតិ ផ្នែកតម្លាភាពហិរញ្ញវត្ថុ និងកញ្ចប់ថវិការកឃើញថា មានភាពមិនប្រក្រតីច្រើនក្នុងការប្រមូលពន្ធដារ និងពន្ធគយក្នុងឆ្នាំ២០១៤ ហើយការផ្សព្វផ្សាយព័ត៌មានស្តីពីថវិកាជាតិ និងការចូលរួមពីសាធារណៈ ក្នុងដំណើរការពង្រាងថវិកាជាតិ ការអនុម័តទៅលើកញ្ចប់ថវិកាជាតិនៃសមាជិកសភាមកពីគណបក្សកាន់អំណាច ហាក់ធ្វើក្នុងស្ថានភាពមួយ ដែលមានការឆ្លុះបញ្ចាំងពីតម្លាភាពតិចតួចបំផុត។ ការប្រមូលពន្ធដារ គឺនៅមានកំរិតនៅឡើយ ខណៈវិធីសាស្រ្តនៃការមូលពន្ធដារនៅទន់

---

[23] លោក សុន ឆ័យ សមាជិកសភាមកពីគណបក្សប្រឆាំងថា ការប្រមូលពន្ធ និងការចាយថវិកាសម្រាប់ឆ្នាំ២០១៤ មានភាពមិនប្រក្រតីច្រើន ហើយបានធ្វើឲ្យបាត់បង់ថវិកាជាតិរហូតដល់ពី៨០០ ទៅ៩០០លានដុល្លារ។

[24] មើលលេខយោងខាងលើ។

ខ្សោយ ហើយអំពើពុករលួយក៏កើតមានច្រើននៅតាមអង្គភាពគយ និងពន្ធដារ ជាពិសេសតាមច្រករបៀងនានាជុំវិញប្រទេស បានធ្វើឲ្យកម្ពុជាបាត់ចំណូលពន្ធគយយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងមួយឆ្នាំៗ។ ក្រសួង និងស្ថាប័នរដ្ឋមួយចំនួនដែលត្រូវបានផ្តល់កញ្ចប់ថវិកាឲ្យជាអាទិភាព ប៉ុន្តែបែរជាចាយថវិកាជាតិមិនអស់ ខណៈតម្រូវការថវិកាដើម្បីបន្តការងារ និងតម្រូវការចាយផ្សេងៗនៅតាមក្រសួង ស្ថាប័ននោះនៅមាននៅឡើយ ដូចជាក្រសួងសុខាភិបាលចាយត្រឹមតែ៨៦ភាគរយ និងក្រសួងអប់រំចាយជាង៩០ភាគរយជាដើម។ ការរិះគន់ក៏មានផងដែរ លើការចំណាយរបស់អាជ្ញាធរអប្សរា ដែលទទួលបានថវិកាប្រមាណ២០លានដុល្លារពីចំណូលអង្គរវត្ត តែការចំណាយមិនមានខ្ទង់ច្បាស់លាស់ និងមិនមានរបាយការណ៍បញ្ជាក់ពីការចាយវាយនោះទេ។ កាលពីថ្ងៃទី២៨ ខែធ្នូ រដ្ឋសភាបានជួបជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចម្តងហើយ ដើម្បីសាកសួរពីបញ្ហានេះ។ កាលពីពេលកន្លងទៅ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួច លោក អូន ព័ន្ធមុនីរ័ត្ន ធ្លាប់បានពន្យល់ថា ការចំណាយជាក់ស្តែងនៅតាមក្រសួងនានាមិនដូចនឹងការព្រាងទុកនោះទេ ដោយថា វាមិនអាចសម្រេចបានគត់ៗនោះទេ។

គួរបញ្ជាក់ថា កាលពីខែមិថុនា ឆ្នាំ២០១៥ ក៏ដូចជាកាលពីខែមករា ឆ្នាំ២០១៦កន្លងទៅថ្មីៗនេះ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនបានបោះឆ្នោតគាំទ្រសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នោះឡើយ។

បើយោងតាមកំណត់សំគាល់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានបង្ហាញថា គឺនៅឆ្នាំ២០១១ម្តងប៉ុណ្ណោះ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សេចក្តីព្រាងច្បាប់ថវិកាជាតិដល់សង្គមស៊ីវិលដើម្បីពិនិត្យឡើងវិញ។ ចាប់ពីពេលនោះមក សង្គមស៊ីវិលមិនដែលបានទទួលទៀតឡើយ ហើយជារឿយៗ បញ្ហាពេលវេលាមិនគ្រប់គ្រាន់ជាហេតុផលដែលរាជរដ្ឋាភិបាលបានលើកឡើង ក្នុងការរារាំងការចូលរួមរបស់សង្គមស៊ីវិល[25]។ ជាក់ស្តែង ច្បាប់ស្តីពីការគ្រប់គ្រងថវិកាជាតិសម្រាប់ (ច្បាប់ថវិកាជាតិ) ឆ្នាំ២០១៦ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ បានអនុម័ត ដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនគាំទ្រ និងថែមទាំងធ្វើពហិការមិនព្រមអនុម័តលើសេចក្តីព្រាងច្បាប់នេះ។ បញ្ហានេះ គឺបណ្តាលមកពីគ្មានតម្លាភាពនៃសេចក្តីព្រាងច្បាប់ថវិកានេះ។ ច្បាប់នេះគ្រោងចំណាយប្រមាណ១៧ ៤៦២ ៤៧៧លានរៀល ឬស្មើនឹងជាង៤៣០០លានដុល្លារ សម្រាប់ការចំណាយផ្សេងៗរបស់ស្ថាប័នរដ្ឋទាំងអស់ (ការចំណាយរបស់រដ្ឋ) សម្រាប់ឆ្នាំ២០១៦។ ទំហំនៃការគ្រោងចំណាយសម្រាប់ឆ្នាំ២០១៦ ក្នុងច្បាប់នេះ គឺកំណើនការចំណាយជាង១៦,៤ភាគរយ ធៀបនឹងច្បាប់ថវិកាជាតិឆ្នាំ២០១៥ ដែលស្មើនឹងជាង២១ភាគរយនៃផលិតផលសរុបក្នុងស្រុក។

ភាគីរាជរដ្ឋាភិបាល លោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថា ច្បាប់ថវិកា២០១៦ ត្រូវបានរៀបចំគិតគូរក្នុងទិសដៅកែទម្រង់ជាក់លាក់ដើម្បីធានា

[25] NGOs Forum, NGOs and Media Call for Detail National Budget Information, 16 October 2014.

ចលនាកំណែទម្រង់ ព្រមទាំងតម្រង់ និងតម្រឹមគោលដៅនៃកំណែទម្រង់ ស្របតាមគោលបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ក៏ដូចជាសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ច្បាប់ថវិកា ២០១៦នេះ បានផ្តោតយកចិត្តទុកដាក់ខ្លាំងលើវិស័យសង្គមកិច្ច ការបណ្តុះបណ្តាលធនធានមនុស្ស ការបន្តវិនិយោគលើវិស័យរចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍន៍វិស័យកសិកម្ម ពង្រឹងវិស័យអភិបាលកិច្ច និងតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការគ្រប់កម្រិត ចាប់ពីខែមករាឆ្នាំ២០១៦ផងដែរ។ លោក ជាម យៀប ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម រដ្ឋសភាសមាជិកសភាមកពីគណបក្សប្រជាជន បានលើកឡើងថា ច្បាប់ស្តីពីការគ្រប់គ្រងថវិកាឆ្នាំ ២០១៦ នេះ នឹងបើកផ្លូវឱ្យរាជរដ្ឋាភិបាលអាចចំណាយថវិកាជាតិ ស្របតាមច្បាប់សម្រាប់អភិវឌ្ឍន៍ ប្រទេសជាតិឱ្យមានការរីកចម្រើនទៅតាមវិស័យចាំបាច់នីមួយៗ។ សមាជិកសភារូបនេះលើកឡើងថា គម្រោងចំណាយថវិកាឆ្នាំ២០១៦នេះ អាចប្រសិទ្ធនាមបានថា ថវិកានៃការប្រមូលផ្តុំនូវកម្លាំងធនធានមនុស្ស សំដៅសម្រេចបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត ដើម្បីធានាបាននូវដំណើរផ្លាស់ប្តូរឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយគុណភាព និងចីរភាព ដោយផ្សារភ្ជាប់ការគិតគូរតុល្យភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជា និងនៅលើពិភពលោក។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ២០១៦នេះ បានទម្លាក់ថវិកាជាតិច្រើនទៅលើវិស័យសង្គមកិច្ច ដែលមានរហូតទៅដល់១០៥០លានដុល្លារ ខណៈវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈបានឈរលេខរៀងទី២ ក្នុងទឹកប្រាក់ចំនួន៦៥០លានដុល្លារ រីឯវិស័យអប់រំបានឈរលេខ៣ ដែលបានទទួលថវិកាជាតិចំនួន៤៩៧លានដុល្លារ។ សេចក្តីព្រាងច្បាប់នេះក៏គ្រោងចំណាយលើវិស័យសុខាភិបាលចំនួន២៧២លានដុល្លារ លើវិស័យកសិកម្មចំនួន៤៦ លានដុល្លារ និងគ្រោងចំណាយលើវិស័យអភិវឌ្ឍន៍ជនបទ ប្រមាណជាង៣៦លានដុល្លារប៉ុណ្ណោះ។ ការចំណាយដោយមិនទាន់បានព្រាងទុក (ចំណាយមិនទាន់បែងចែកមុខសញ្ញា) មានចំនួនរហូតទៅដល់ ប្រមាណជាង៧០០លានដុល្លារអាមេរិក(៧២៧,៦៤៨,៧៨៥ដុល្លារអាមេរិក)។ ការចំណាយមិនទាន់បែងចែកមុខសញ្ញានេះ គឺមានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ណាស់។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ជាពិសេសគណៈកម្មការជំនាញរដ្ឋសភាទទួលបន្ទុកហិរញ្ញវត្ថុ ធនាគារ និងសវនកម្មមិនបានទទួលរបាយការណ៍ និងឯកសារលំអិតទាក់ទងថវិកាជាតិឆ្នាំ២០១៦នេះ បើទោះបីគណៈកម្មការនេះបានស្នើរដ្ឋាភិបាលឲ្យផ្តល់របាយការណ៍ និងឯកសារបន្ថែមក៏ដោយ។

**៥.១.២.២ ភាពមិនប្រក្រតីលើការគ្រប់គ្រងចំណូល និងចំណាយនៃថវិកាជាតិ**

ច្បាប់ថវិកាជាតិឆ្នាំ២០១៦ ដែលត្រូវបានរដ្ឋសភាបានអនុម័តដោយសម្លេងឯកបក្ស គ្រោងចំណាយប្រមាណ១៧៤៦២៤៧៧លានរៀល ឬស្មើនឹងជាង៤៣០០លានដុល្លារអាមេរិក សំរាប់ការចំណាយផ្សេងៗរបស់ស្ថាប័នរដ្ឋទាំងអស់ (ការចំណាយរបស់រដ្ឋ) សំរាប់ឆ្នាំ២០១៦។ ចំណែក

គម្រោងប្រាក់ចំណូលសម្រាប់ឆ្នាំ២០១៦នេះ រដ្ឋាភិបាលបង្កើតគ្រោងបង្កើនចំណូលឡើងដល់៤ ពាន់លានដុល្លារអាមេរិក។ មានភាពមិនប្រក្រតីជាច្រើនពាក់ព័ន្ធនឹងការគ្រប់គ្រងប្រាក់ចំណូល និងចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ករណីគ្មានតម្លាភាពមួយ គឺការគ្រប់គ្រងចំណូលនៃថវិកាជាតិ ដែលបានពីការប្រមូលចំណូលពីការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរបស់រដ្ឋ រាជរដ្ឋាភិបាលកម្ពុជាក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ឬរបាយការណ៍ និងការពន្យល់ច្បាស់លាស់ដល់សាធារណជនដែរ។ ក្នុងច្បាប់គ្រប់គ្រងថវិកាជាតិ ចំណូលមិនមែនសារពើពន្ធដែលបានពីការលក់ កាដូ ឬជួល និងសម្បទានទ្រព្យសម្បត្តិរបស់រដ្ឋ ទាំងចលនទ្រព្យ និងអចលនទ្រព្យ សេវាគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាកម្ម ផលទុនប្រាក់ពិន័យ និងដាក់ទណ្ឌកម្ម ការឧបត្ថម្ភធន អំណោយ ចំណូលបដិភាគពីប្រជាពលរដ្ឋ ផលទុននៃការរឹបអូសភាស៊ីផ្សារ និងផលទុនដែលមានមកពីការផ្តល់សេវាផ្សេងៗ និងជាពិសេស ផលទុននៃការសម្បទាន និងការជួលដីធ្លី ដែលមានទំហំទឹកប្រាក់សរុបប្រមាណ ៣៤,៨៩៥,៨៤២.៨០ដុល្លារអាមេរិក ក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១៥ ហើយចំណូលមិនមែនសារពើពន្ធទាំងនេះ បានធ្លាក់ចុះទៅវិញនៅក្នុងច្បាប់ថវិកាឆ្នាំ២០១៦ ដែលមានទឹកប្រាក់សរុបប្រមាណ៣៤,២៤៩,៨៣៨.៥៦ដុល្លារអាមរិក។

បញ្ហាចោទនៃចំនួនប្រាក់ចំណូលនៃការលក់សំបុត្រ ពីសំណាក់ភ្ញៀវទេសចរបរទេស ចូលទស្សនាប្រាសាទអង្គរវត្ត ដែលត្រូវបានចោទប្រកាន់ជារឿយៗពីសំណាក់គណបក្សប្រឆាំង ហាក់ដូចជាស្ងប់ស្ងាត់ ខណៈដែលរដ្ឋាភិបាលបានសម្រេចដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុន លោក សុខ គង់ នៅចុងឆ្នាំ២០១៥នេះដើម្បីចាត់ចែងដោយរដ្ឋផ្ទាល់។ យោងតាមសេចក្តីប្រកាសព័ត៌មានលេខ០៥/១៦រប.សបក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ របស់អាជ្ញាធរអប្សរាបានឲ្យដឹងថា ភ្ញៀវទេសចរទិញប័ណ្ណទស្សនារមណីយដ្ឋានអង្គរ ខេត្តសៀមរាប នាឆ្នាំ២០១៥កន្លងទៅ មានចំនួន ២.១០០.០១៨នាក់ និងទទួលបានចំណូលដុលសរុបចំនួន៦០.០៥៣.៧០០ដុល្លារអាមេរិក ពោលគឺ បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ២០១៥ មានការកើនឡើងចំនួន១,២០ភាគរយ ដែលនៅឆ្នាំ២០១៤ កម្ពុជាទទួលបានភ្ញៀវបរទេសចំនួន១លាន៨ សែននាក់ មកទស្សនាប្រាសាទអង្គរវត្ត។

លេខចំណូលដុលរយៈពេល៦ឆ្នាំជាប់ៗគ្នា ប្រកាសដោយអាជ្ញាធរអប្សរា បានមកពីការធ្វើសេវាកម្មប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរ គ្រប់គ្រងដោយក្រុមហ៊ុន សុខា អូតែល របស់លោកឧកញ៉ា សុខ គង់ កើតចេញពីកិច្ចសន្យាសម្បទាន(មិនឆ្លងកាត់ការដេញថ្លៃសាធារណៈ) រវាងរាជរដ្ឋាភិបាលកម្ពុជា(តំណាងដោយអាជ្ញាធរអប្សរា ) និងក្រុមហ៊ុនសុខា អូតែលនោះ មានដូចខាងក្រោម ៖

- ឆ្នាំ២០១០ ចំនួន ៣៣.១១៣.៥០០ដុល្លារអាមេរិក
- ឆ្នាំ២០១១ ចំនួន ៤២.១៨៥.៣០០ដុល្លារអាមេរិក

- ឆ្នាំ២០១២ ចំនួន ៥១.៣១៩.១៨០ដុល្លារអាមេរិក
- ឆ្នាំ២០១៣ ចំនួន ៥៧.៦៨៧.៦៨០ដុល្លារអាមេរិក
- ឆ្នាំ២០១៤ ចំនួន ៥៩.៣៨២.០០០ដុល្លារអាមេរិក
- ឆ្នាំ២០១៥ ចំនួន ៦០.០៥៣.៧០០ដុល្លារអាមេរិក។[26]

គួរបញ្ជាក់ជូនថា ចាប់ពីឆ្នាំ២០១៦នេះតទៅ កិច្ចសន្យាស្តីពីការប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានប្រាសាទអង្គរវត្តជាមួយក្រុមហ៊ុនសុខា អូតែល របស់លោកឧកញ៉ា សុខ គង់ ត្រូវបញ្ចប់ហើយៗរដ្ឋ ជាអ្នកគ្រប់គ្រងប្រមូលចំណូលដោយផ្ទាល់វិញ ក្រោមរូបភាពសហគ្រាសសាធារណៈ។ ដោយឡែក បុគ្គលិកទាំងអស់របស់ក្រុមហ៊ុនសុខា អូតែល ដែលកំពុងបម្រើការងារផ្នែកប្រមូលចំណូលនឹងបន្តការងាររបស់ខ្លួនដដែល ក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈដែលបង្កើតឡើងនោះ។

ការប្រមូលពន្ធពីកាស៊ីណូ កម្ពុជារកបានប្រាក់ចំណូលពីវិស័យនេះប្រហែល២៥លានដុល្លារកាលពីឆ្នាំ២០១៤ និងឆ្នាំ២០១៥កើនឡើងដល់៣៤,៧លានដុល្លារ កើន៣៣ភាគរយ ក្នុងនោះចំណូលពន្ធពីណាហ្គាវើល ជាកាស៊ីណូឈានមុខគេរបស់កម្ពុជាមានប្រហែល២៣ភាគរយ ឬ៩លានដុល្លារនៃប្រាក់ចំណូលនេះ ប៉ុន្តែចំណូលនេះរាប់បញ្ចូលទាំងពន្ធពីសណ្ឋាគារ ភោជនីយដ្ឋាន និងឧបករណ៍កម្សាន្តផងដែរ។[27] ចំណូលពន្ធបានពីកាស៊ីណូដែលមានអាជ្ញាប័ណ្ណចំនួន៦៣កាស៊ីណូ នៅទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥។ ចំនួននេះបានកើនឡើង៤កាស៊ីណូ បើធៀបនឹងឆ្នាំ២០១៤ ដែលមានចំនួនត្រឹមតែចំនួន៥៩កាស៊ីណូតែប៉ុណ្ណោះ[28]។ ការប្រមូលពន្ធចំណូលបានមកពីឧស្សាហកម្មកាស៊ីណូនេះត្រូវបានគេមើលឃើញថា នៅតែមានចំនួនតិចតួចដដែល ហើយមិនបានឆ្លុះបញ្ចាំងពីចំនួនកាស៊ីណូដែលកំពុងដំណើរការអាជីវកម្មនៅកម្ពុជា និងប្រាក់ចំណេញដែលកាស៊ីណូទាំងនោះទទួលបានក្នុងមួយឆ្នាំៗ។ កង្វះច្បាប់ ស្តីពីការគ្រប់គ្រងកាស៊ីណូ គឺជាបញ្ហាប្រឈមដ៏ធំមួយរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងកាស៊ីណូ និងការគ្រប់គ្រងការប្រមូលពន្ធ។ នៅក្នុងឆ្នាំនេះដែរ រដ្ឋាភិបាលបានសន្យាសារជាថ្មីថា ច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូនឹងត្រូវអនុម័តដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៦នេះ។

លើសពីនេះទៅទៀត មានករណីធំៗនៃការលក់ ជួល ឬដោះដូរ ចលន ឬអចលនទ្រព្យរបស់រដ្ឋ ដែលមិនមានព័ត៌មានអំពីចំណូលលម្អិតទាំងនោះក្នុងថវិកាជាតិមានដូចជា ដីនៅតំបន់បឹងទំពុន និងបឹងជើងឯកដែលរដ្ឋាភិបាលបានសម្បទានទៅឲ្យក្រុមហ៊ុនអាយ អិន ជី ហូលឌីង ខូ អិលធីឌី (ING Holding Co., Ltd) ដែលមានទំហំទឹកប្រាក់វិនិយោគប្រមាណ៧០០លានដុល្លារលើទំហំដីចំនួន២,៥៧២ហិកតា។ ករណីដូចគ្នានេះ ដីនៅតំបន់បឹងកក់ដែលមានផ្ទៃក្រឡា១៣៣ហិចតា ដែលរដ្ឋបានជួលទៅឱ្យក្រុមហ៊ុន ហ្ស៊ូកាគូ (shukaku Inc) របស់លោកឧកញ៉ា ឡៅ ម៉េង

---

[26] សេចក្តីប្រកាសព័ត៌មានលេខ០៥/១៦រប.សបក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ របស់អាជ្ញាធរអប្សរា។

[27] Ananth Baliga, *ចំណូលពន្ធបានពីកាស៊ីណូមានជាង ៣៤ លានដុល្លារ*, ភ្នំពេញប៉ុស្តិ៍, Wed, 13 January 2016។

[28] ម៉ៃ គុណមករា, សេចក្តីព្រាងច្បាប់គ្រប់គ្រងកាស៊ីណូនឹងអនុម័តឆ្នាំនេះ, ភ្នំពេញប៉ុស្តិ៍, Mon, 6 April 2015។

ឃិន និងជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជារយៈពេល៩៩ឆ្នាំ ក្នុងតម្លៃ៧៩លានដុល្លារអាមេរិក[29] ដីនៅតំបន់កោះពេជ្រ៧៥ហិកតាលក់ទៅឱ្យឧកញ៉ា ពង្ស ខៀវសែ ការជួលតំបន់ជុំវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ដីដ៏ធំល្វឹងល្វើយនៅតំបន់បឹងទំពុន សួនច្បារសាធារណៈដែលក្រុមហ៊ុននេះជួលធ្វើការដ្ឋានសំណង់អស់រយៈពេលជាច្រើនឆ្នាំ។ល។ ចលនទ្រព្យ ស្ថាប័នរដ្ឋ ដូចជាទីស្នាក់ការក្រសួង មន្ទីរ ទីលានកីឡាតាមបណ្តាខេត្តនានា ដូចជាខេត្តកំពង់ធំជាដើម ឬអចលនទ្រព្យផ្សេងៗទៀត ក្នុងការវិនិយោគធ្វើជាតំបន់អភិវឌ្ឍន៍ជាដើម។ល។ បើទោះបីរដ្ឋបានលក់ ឬជួលពហុកីឡាដ្ឋាន(ស្តាត)ចាស់ បុរីកីឡា និងដីនៅជុំវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ទៅឲ្យក្រុមហ៊ុនឯកជន ប៉ុន្តែរដ្ឋបែរជាគ្មានថវិកាសំរាប់កសាងពហុកីឡាដ្ឋានជាតិថ្មី ដែលកំពុងសាងសង់សម្រាប់ត្រៀបការប្រកួតកីឡាស៊ីហ្គេម បែរជាទៅខ្ចីលុយប្រទេសចិន រហូតដល់ទៅ១០០លានដុល្លារសំរាប់កសាងទៅវិញ មិនតែប៉ុណ្ណោះស្តាតថ្មីនេះ ត្រូវដាក់ឈ្មោះងារលោកនាយករដ្ឋមន្ត្រី «មរកតេជោ» ថែមទៀត។

ចំណូលដែលបានមកពីការលក់ ជួល ឬដោះដូរធ្វើសម្បទាន ប្រជាពលរដ្ឋខ្មែរមិនបានដឹង ឬមិនសូវបានទទួលបានព័ត៌មាន ឬដឹងថា តើទំហំប្រាក់ចំណូល ទំហំទឹកប្រាក់ដែលទទួលបានមកពីការជួល ឬដោះដូរ លក់ ឬធ្វើសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងអស់នោះ មានទំហំប៉ុណ្ណា? ឬថាប្រាក់ចំណូលរាប់លានដុល្លារទាំងនោះ បានដាក់បញ្ចូលទៅក្នុងប្រភេទប្រភពចំណូលណាមួយឲ្យពិតប្រាកដនៃថវិកាជាតិ? ជាទូទៅ រដ្ឋាភិបាលមិនមានរបាយការណ៍លម្អិតស្តីពីទំហំប្រាក់ចំណូលទាំងនោះ តាមប្រភពនីមួយៗឡើយ។ ការស្នើសុំឲ្យការផ្តល់ឯកសាររបាយការណ៍លម្អិតពីក្រុមអង្គការសង្គមស៊ីវិល ឬពីសមាជិកសភា គឺតែងតែត្រូវបានបដិសេធដោយមន្ត្រីរដ្ឋាភិបាលដោយហេតុផលផ្សេងៗ។

លើសពីនេះទៅទៀត កង្វះតម្លាភាពចំណូលសម្រាប់ថវិកាជាតិ (បន្ទាត់ថវិកា៧៥ និងបន្ទាត់ថវិកា៥០ ដែលបានមកប្រាក់កម្ចីជំនួយ និងការឧបត្ថម្ភធន) ត្រូវបានអនុវត្តក្រៅរតនាគារជាតិក្នុងឆ្នាំ២០១៤ ប្រហែល៨៦៥លានដុល្លារសហរដ្ឋអាមេរិក និងប្រហែល៩២១លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៥ និងប្រហែល៩៦៦លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៦។ តួលេខនៃកំណើនចំណូលដែលបានមកពីប្រាក់កម្ចី ជំនួយ និងការឧបត្ថម្ភធនអនុវត្តក្រៅរតនាគារជាតិកើនឡើងប្រហែល៥០លានដុល្លារក្នុងមួយឆ្នាំ រាប់ចាប់ពីឆ្នាំ២០១៤មក។

ទន្ទឹមនឹងនោះ សំណួរប៉ុន្តែគ្មានចម្លើយលើការប្រើប្រាស់ថវិកា ដែលជាថវិកាជាតិចំណាយមិនទាន់បែងចែកក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១៦ប្រមាណជាង៧២៧លានដុល្លារអាមេរិក ស្មើនឹង១៦,៦៨ភាគរយនៃថវិកាដែលត្រូវចំណាយសរុប។ ចំនួននេះបានធ្លាក់ចុះ បើប្រៀបធៀបជាមួយការចំណាយក្រៅខ្ទង់ក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១៥ ដែលមានប្រមាណ១,៥៣ពាន់លានដុល្លារអាមេរិក។ វាជាចំនួនទឹកប្រាក់ដ៏ធំដែលជាប់មន្ទិលសង្ស័យថា បានប្រើប្រាស់ដោយគ្មានតម្លាភាព

---

[29] CCHR Case Studies Series “Boeung Kork”, Vol. 5, Boeung Kork, October 2011.

អាចជាទ្វារចំហសំរាប់ភាពមិនប្រក្រតី ការគិបកេង និងប្រើប្រាស់សម្រាប់ផលប្រយោជន៍នយោបាយ។ រដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអះអាងថា ភាគច្រើននៃថវិកាជាតិដែលមិនទាន់បានបែងចែកស្ថិតក្នុងគោលដៅរួចហើយ ដោយថវិកាទាំងនោះនឹងត្រូវចំណាយលើផ្នែកជាច្រើន ដូចជាហេដ្ឋារចនាសម្ព័ន្ធ រួមមានផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ និងបម្រុងទុកសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះគ្រោះធម្មជាតិ និងបញ្ហាសន្តិសុខជាតិ។

ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ និងស្ពាន គឺជាផ្នែកមួយដ៏សំខាន់ក្នុងចំណោមវិស័យអាទិភាពផ្សេងៗទៀត ដែលរដ្ឋាភិបាលមានផែនការចំណាយថវិកាខ្ពស់នៅក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១៥ ក៏ដូចជាឆ្នាំ២០១៦នេះដែរ ព្រោះថាវាជាសរសៃឈាមសម្រាប់តភ្ជាប់ការធ្វើពាណិជ្ជកម្ម អាជីវកម្ម និងការធ្វើដំណើរប្រាស្រ័យទាក់ទងគ្នារបស់ប្រជាពលរដ្ឋ។ យ៉ាងណាក៏ដោយ ទោះជាវិស័យនេះនាពេលបច្ចុប្បន្នហាក់មានការរីកចំរើនគួរឲ្យកត់សម្គាល់ក៏ដោយ ប៉ុន្តែសម្រាប់គុណភាព ក្នុងការប្រើប្រាស់ហាក់មិនសូវជាល្អនៅឡើយ និងតែងតែមានការរិះគន់ពីសាធារណជនផងដែរ។ អំពើពុករលួយក្នុងវិស័យផ្លូវថ្នល់ត្រូវបានគេមើលឃើញថា មានបីដំណាក់កាល។ ទី១៖ អំពើពុករលួយកើតមាននៅក្នុងដំណាក់កាលនៃការដេញថ្លៃជាមួយក្រុមហ៊ុនសាងសង់ ឬស្ថាបនា ទី២៖ នៅដំណាក់កាលពេលផ្លូវកំពុងសាងសង់ ឬស្ថាបនាប្រព្រឹត្តដោយក្រុមហ៊ុនទទួលសាងសង់ និងទី៣៖នៅដំណាក់កាលផ្លូវត្រូវបានធ្វើរួចរាល់ហើយ ប៉ុន្តែអាជ្ញាធរ មន្ត្រីខូចខិលដែលទទួលខុសត្រូវខាងត្រួតពិនិត្យទម្ងន់រថយន្ត បានឃុបឃិតគ្នាជាមួយក្រុមហ៊ុនដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់លោកឧកញ៉ា ដែលមានទ្រព្យសម្បត្តិវាល់កោដិ អនុញ្ញាតឲ្យប្រភេទរថយន្តទំងន់យក្សផ្ទុកលើសចំណុះ បើកបរឆ្លងកាត់ផ្លូវជាដើម។ ដូច្នេះផ្លូវដែលកំពុងស្ថិតក្នុងលក្ខខណ្ឌនៃគុណភាពមិនល្អមួយទៅហើយ ដោយបូករួមជាមួយការដឹកលើសទម្ងន់ឥតត្រាប្រណីពីរថយន្តទម្ងន់យក្សថែមទៀត គឺវាកាន់តែអាក្រក់ជាន់លើអាក្រក់។

អង្គការសង្គមស៊ីវិល បានជំរុញរដ្ឋាភិបាលចាយវាយមាន តម្លាភាពលើផ្លូវថ្នល់ការស្នើរបស់សង្គមស៊ីវិលនេះ ត្រូវបានធ្វើឡើងនៅក្នុងវេទិកាសាធារណៈ ស្តីអំពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលរៀបចំធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាវេទិកាលើកដំបូងមួយរបស់ក្រសួងនេះ ដែលផ្តល់ការចូលរួមពីស្ថាប័នដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានបានចូលរួមសួរសំណួរ និងស្តាប់ការស្រាយបំភ្លឺនានាពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល កាលពីថ្ងៃចន្ទ ទី២២ ខែធ្នូ ឆ្នាំ២០១៤។ ករណីជាក់ស្តែងមួយដែលធ្វើឲ្យមានការរិះគន់អំពើពុករលួយនៃការសាងសង់ផ្លូវជាតិលេខ៣៣ ដែលភ្ជាប់ពីភ្នំពេញទៅកាន់ខេត្តកំពត ត្រង់ចំណុចពីទីរួមខេត្តកំពតទៅស្រុកកំពង់ត្រាច។ ផ្លូវមួយខ្សែនេះត្រូវបានស្ថាបនាឡើងវិញមិនទាន់បានមួយឆ្នាំត្រឹមត្រូវផង ឥឡូវត្រូវរងការខូចខាតយ៉ាងដំណំ ចាប់ពីចំណុចភូមិកំពង់កេស រហូតដល់ភូមិត្រពាំងពីរ ហៅចម្ការសាវម៉ាវ ក្នុងឃុំត្រពាំងសង្កែ ស្រុកទឹក

ឈ្នូ[30]។ ផ្លូវជាតិលេខ៣៣នេះត្រូវបានស្ថាបនានៅឆ្នាំ២០១៤ បន្ទាប់ពីការសាងសង់បានរយៈពេលប្រមាណ១០ខែ ផ្លូវនេះបានរងការខូចខាតទៅវិញយ៉ាងខ្លាំងដំណំ ខណៈដែលផ្លូវនេះត្រូវបានគ្រោងដាក់ឲ្យសម្ពោធចុងខែមិថុនាឆ្នាំ២០១៥។ ក្រោយពីបែកធ្លាយរឿងអាស្រូវនេះ ក្រុមហ៊ុនបានសម្រុកជួសជុលឡើងវិញទាំងយប់ទាំងថ្ងៃ ដើម្បីទទួលលោកនាយករដ្ឋមន្ត្រីមកកាត់ខ្សែបូរ សម្ពោធឆ្លងឲ្យប្រើប្រាស់ជាផ្លូវការ។ ផ្លូវដែលរងការខូចខាតខាងលើ ត្រូវបានមជ្ឈដ្ឋានជាច្រើនបានដាក់សំណួរសួរថា តើខូចមកពីរថយន្តដឹកធ្ងន់ ឬក៏ខូចមកពីខ្វះបច្ចេកទេស? មិនមែនមានតែករណីផ្លូវជាតិលេខ៣៣នេះមួយប៉ុណ្ណោះឡើយ ដែលទទួលរងការខូចខាត គឺនៅមានផ្លូវជាច្រើនខ្សែទៀតដែលបាន និងកំពុងធ្លុះធ្លាយ ប្រេះស្រាំ ស្រុត ហើម ប៉ោង ក្រោយពីបានធ្វើការស្ថាបនាសាងសង់ និងជួលជុលរួចត្រឹមតែរយៈពេលមួយឆ្នាំ។ ដោយឡែក ចំពោះផ្លូវក្នុងក្រុង និងរាជធានីភ្នំពេញជាច្រើនខ្សែ ត្រូវបានធ្វើរួចមិនទាន់បានប៉ុន្មានផង ស្រាប់តែត្រូវបានគេជីកកាត់ ពុះកាត់ដាក់លូ ឬទុយយោទឹក ឬខ្សែភ្លើងដោយក្រុមហ៊ុនខ្សែកាបតបណ្ដាញផ្សេងៗ និងឯកជនជាដើម។ ផ្លូវដែលត្រូវបានពុះ ជីកកាត់ទាំងអស់នោះ មិនត្រូវបានលុប ឬជួសជុលឲ្យមានសភាពដូចដើមវិញឡើយ ហើយអាជ្ញាធរមូលដ្ឋាន ក៏មិនដែលរវីរវល់បើកភ្នែកមើលដែរ។

មន្ត្រីរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានទទួលស្គាល់ថា គុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ នៅកម្ពុជានាពេលបច្ចុប្បន្ន ពិតជាមិនទាន់មានគុណភាពល្អនៅឡើយ ដោយសារតែលទ្ធផលនៃបញ្ហាអំពើពុករលួយ[31]។

ភាគច្រើនថវិកាដែលរដ្ឋាភិបាលកម្ពុជា យកទៅសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពានជាកម្ចីពីបរទេស ហើយឥណទានទាំងនោះភាគច្រើនបានមកពីប្រទេសចិន។ ទំហំកម្ចីឥណទានរបស់កម្ពុជាពីបរទេស ជាពិសេសពីប្រទេសចិន និងដៃគូអភិវឌ្ឍន៍ផ្សេងៗកំពុងបន្តកើនឡើងឥតឈប់ឈរ។ យោងតាមច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦បង្ហាញថា ចំណាយមូលធនថវិកាថ្នាក់ជាតិឆ្នាំ២០១៦ ត្រូវបានគ្រោងប្រមាណជិតមួយពាន់លានដុល្លារអាមេរិក (ជាង៩៦៦លានដុល្លារអាមេរិក)។ ការចំណាយមូលធនថវិកាថ្នាក់ជាតិឆ្នាំ២០១៦នេះ បានធ្លាក់ចុះ បើធៀបនឹងការចំណាយក្នុងឆ្នាំ២០១៥ ដែលមានរហូតដល់១,៤៣ពាន់លានដុល្លារអាមេរិក។ ក្នុងនោះប្រមាណជាជាង៧០ ទៅ៨០ភាគរយនៃថវិកានេះ ត្រូវបានបែងចែកសម្រាប់វិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ ធារាសាស្ត្រ ផ្លូវរថភ្លើង បណ្ដាញអគ្គិសនី និងកំពង់ផែជាដើម។

បញ្ហាសំខាន់មួយទៀតពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាជាតិមិនប្រក្រតីនេះដែរ គឺករណីពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាជាតិខ្ជះខ្ជាយទៅលើមន្ត្រីជាន់ខ្ពស់ដ៏ច្រើនស្អេកស្កះ ដែលជាសមាជិកគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ ទីប្រឹក្សារដ្ឋាភិបាល និងនាយកដ្ឋមន្ត្រី ព្រមទាំងជំនួយការទី

---

30 ប្រាក់ សារិទ្ធ *ផ្លូវជាតិលេខ៣៣កំពត-កំពង់ត្រាចមិនទាន់ដាក់សម្ពោធផង ត្រូវរថយន្តធុនធំៗបំផ្លាញបណ្ដើរៗហើយ* កោះសន្តិភាព ថ្ងៃសុក្រ ទី២៦ ខែមិថុនា ឆ្នាំ២០១៥ ។

31 **PHANN ANA**, *CPP Official Alleges Embezzlement of Roads Budgets*, The Cambodia Daily, July 11, 2014.

ប្រឹក្សាក្រសួង ទីប្រឹក្សា និងជំនួយការប្រធាន និងអនុប្រធានរដ្ឋសភា ព្រឹទ្ធសភា ព្រមទាំងការចំណាយថវិកាជាតិខ្វះខ្វាយទៅលើមន្ត្រីខ្មោច និងមន្ត្រីរាជការដែលកាន់ការងារ ឬបម្រើការក្នុងក្រសួងច្រើនជាងមួយ។ ការតែងតាំងសមាសភាពមន្ត្រីនយោបាយជាន់ខ្ពស់ជាទីប្រឹក្សា រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ជំនួយការ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានគេមើលឃើញថា វាមានចំនួនច្រើនស្មោកស្មុះហួសហេតុពេក ។ ការតែងតាំងដាក់បញ្ចូលនេះ បានឱ្យអំណាចលើសលប់ពេកទៅលើស្ថាប័ននីតិប្រតិបត្តិ គឺនាយករដ្ឋមន្ត្រី។ វាកើតឡើងដោយសារតែគ្មានបទបញ្ញត្តិនៃច្បាប់ណាមួយបញ្ញត្តិកំណត់អំពីចំនួនអប្បបរមានៃមន្ត្រីជាន់ខ្ពស់ ជាសមាជិកគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា និងជំនួយការនាយករដ្ឋមន្ត្រី ប្រធាន និងអនុប្រធានរដ្ឋសភា និងព្រឹទ្ធសភា ព្រមទាំងទីប្រឹក្សាតាមក្រសួង និងស្ថាប័នជាតិផ្សេងៗទៀតជាច្រើនរាជរដ្ឋាភិបាលនីតិកាលទី៥ ហើយបញ្ហានេះធ្វើឲ្យស្ថាប័ននីតិប្រតិបត្តិនេះ មានអំណាចសម្រេចចិត្តយ៉ាងធំធេងក្នុងការតែងតាំង និងស្នើឲ្យមានការតែងតាំងមន្ត្រីទាំងអស់នោះ។ យោងតាមច្បាប់រដ្ឋបាល ព្រះមហាក្សត្រគ្មានជម្រើស ឬអំណាចអ្វីផ្សេងក្រៅតែពីឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំងទាំងនោះ។ មានន័យថា ព្រះអង្គគ្មានអំណាចបដិសេធថា មិនឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងទាំងនោះឡើយ។ យោងតាមមាត្រា១៤ កថាខណ្ឌទី២នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំងផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដូចខាងក្រោម៖

- ទេសាភិបាល ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
- ទីបឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង
- ប្រតិភូរាជរដ្ឋាភិបាល
- អភិបាលខេត្ត រាជធានី
- ឯកអគ្គរាជទូត
- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- អគ្គសេនាធិការ និងអគ្គសេនាធិការរង
- ឧត្តមសេនីយ៍ឡើងទៅ[32]

សម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានតំណែង និងឋានៈដែលមានចែងក្នុងមាត្រា១៥ ប៉ុន្តែលើកលែងមាត្រា២៨នៃច្បាប់នេះ នាយករដ្ឋមន្ត្រីមានសិទ្ធិពេញលេញ ក្នុងការចេញអនុក្រឹត្យតែងតាំងមន្ត្រីទាំងនោះ។ មន្ត្រីក្នុងតំណែង ដែលត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រីទាំងនោះ

[32] មាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំ និងការព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ១៩៩៤។

រួមមានអភិបាលស្រុក និងអភិបាលខេត្តរង គឺតែងតាំងផ្ទាល់ដោយអនុក្រឹត្យ និងរដ្ឋបាលថ្នាក់ជាតិ (ក្រសួង និងស្ថាប័នរដ្ឋ) ឋានៈចាប់ពីប្រធាននាយកដ្ឋានឡើងដល់ អគ្គនាយករង/អគ្គាធិការរង/អគ្គលេខាធិការរងនៃអគ្គលេខាធិករដ្ឋាន អនុប្រធានខុទ្ទកាល័យ ត្រូវបានតែងតាំងដោយអនុក្រឹត្យ។ សម្រាប់ជួរកងយោធពលខេមរភូមិន្ទ ឋានៈវរៈសេនីយ៍ត្រី(សក្តិបួន)ឡើង ដល់វរៈសេនីយ៍ឯក(សក្តិ៥) ឬអនុព័ន្ធយោធា។ សម្រាប់មន្ត្រីការទូត រួមមានមន្ត្រីការទូតឋានៈលេខាធិការឯកអគ្គរាជទូតទី១ និងទី២ និងអគ្គហេរញ្ញឹកជាដើម។

ករណីជាក់ស្តែងមួយ គឺចំនួនទីប្រឹក្សារបស់អតីតប្រធានព្រឹទ្ធសភា និងអតីតប្រធានគណបក្សប្រជាជនកម្ពុជាដែលត្រូវបានគេដឹងថា មានចំនួនរហូតដល់ទៅ៣៨៣នាក់ ក្នុងនោះរួមមានមានឋានៈស្មើទេសរដ្ឋមន្ត្រីចំនួន៣នាក់ ឋានៈស្មើរដ្ឋមន្ត្រីចំនួន៣៨នាក់ ឋានៈស្មើរដ្ឋលេខាធិការចំនួន២០៩នាក់ ឋានៈស្មើអនុរដ្ឋលេខាធិការចំនួន៥២នាក់ និងឋានៈស្មើអគ្គនាយកចំនួន៤១នាក់ បើគិតត្រឹមខែឧសភា ឆ្នាំ២០១៥កន្លងទៅ[33]។ ក្រៅពីករណីអតីតប្រធានព្រឹទ្ធសភាខាងលើ នៅមានថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សកាន់អំណាចជាច្រើនទៀតផងដែរ ដែលមានទីប្រឹក្សា និងជំនួយការច្រើនស្អេកស្កះ រួមមានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន[34] មានខ្ទង់មិនតិចជាង៥០នាក់ជាជំនួយការ និងទីប្រឹក្សាផ្ទាល់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន មានចំនួន៦២នាក់[35] គិតត្រឹមខែឧសភា ឆ្នាំ២០១៥ ប្រធានព្រឹទ្ធសភាបច្ចុប្បន្នមានចំនួន៣៨នាក់ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានចំនួន៩៥ និងជំនួយការ៦៧នាក់ គិតមកដល់ចុងឆ្នាំ២០១៥[36]។ ចំពោះស្ថាប័នរដ្ឋសភាក៏ត្រូវបានគេរិះគន់ថា មានចំនួនទីប្រក្សាច្រើនស្អេកស្កះផងដែរ ដូចជាប្រធានរដ្ឋសភាក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងទៅ លោកមានទីប្រឹក្សាចំនួន២៤៨នាក់ ហើយក្នុងចំណោមទីប្រឹក្សារបស់លោកទាំងចំនួន២៤៨នាក់នោះមាន៣នាក់ឋានៈស្មើទេសរដ្ឋមន្ត្រី ២៥នាក់ឋានៈស្មើរដ្ឋមន្ត្រី ១៤១នាក់ឋានៈស្មើរដ្ឋលេខាធិការ និងចំនួន៧៩នាក់មានឋានៈស្មើអនុរដ្ឋលេខាធិការ។ ក្រៅពីនេះ សម្តេច ហេង សំរិននៅមានជំនួយការចំនួន១៧នាក់ទៀតដែលមានឋានៈស្មើអគ្គនាយក[37]។ ដោយឡែក ត្រឹមតែជាអនុប្រធានទី២នៃរដ្ឋសភា ប៉ុន្តែលោកមានទីប្រឹក្សា និងជំនួយការរហូតដល់៦៣នាក់ ហើយក្នុងចំណោម៦៣នាក់ គេមានឃើញ

[33] *ទីប្រឹក្សានិងជំនួយការមេបក្សកាន់អំណាចជាង៣០០នាក់ ដែលចាយលុយជាតិជាង១៤ម៉ឺនដុល្លារក្នុង១ខែ ត្រូវរំសាយ*, សារព័ត៌មានដើមត្នោត, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៥។

[34] ក្នុងនីតិកាលទី៥នៃរដ្ឋសភា (២០១៣ ២០១៨) នេះ លោកនាយករដ្ឋមន្ត្រី ទទួលបានទីប្រឹក្សា និងជំនួយការផ្ទាល់ផ្លូវការចំនួន៥៥នាក់។ ចំនួននេះ មិនទាន់គិតចូលការតែងតាំងបន្តបន្ទាប់ក្រោយៗមកទៀតឡើយ។

[35] ម៉ម មុនីរតន៍, *អ្នកវិភាគរិះគន់ការតែងតាំងទីប្រឹក្សានិងបញ្ចប់តំណែងទីប្រឹក្សារបស់លោក ជា ស៊ីម*, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥។

[36] *សម្តេចក្រឡាហោម ស ខេង រំលោភសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន* សារព័ត៌មានដើមត្នោត ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦។

[37] *សម្តេចអគ្គមហាពញាចក្រី ហេងសំរិន ប្រធានរដ្ឋសភានីតិកាលទី៤មានទីប្រឹក្សាចំនួន២៤៨នាក់* សារព័ត៌មានដើមត្នោត ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣។

ឈ្មោះសាច់ញាតិរបស់លោក២នាក់ផងដែរ គិតត្រឹមមកដល់ខែតុលា ឆ្នាំ២០១៤។ ក្នុងចំណោមទីប្រឹក្សាទាំង៦៣នាក់នេះដែរ មាន១៧រូបមានឋានៈស្មើរដ្ឋមន្ត្រី២៣រូប មានឋានៈស្មើរដ្ឋលេខាធិការ២២រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និង១រូបមានឋានៈស្មើអគ្គនាយក[38]។

ប្រការ៦នៃសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ៣៧សសរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដែលចុះហត្ថលេខាផ្ទាល់ដោយលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចែងកំណត់ថា «ឧបនាយករដ្ឋមន្ត្រីមួយរូបៗ មានទីប្រឹក្សា៤រូប ក្នុងនោះ២រូបមានឋានៈស្មើរដ្ឋលេខាធិការ ២រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងជំនួយការ៥រូប ក្នុងនោះ១រូបមានឋានៈស្មើអគ្គនាយក ២រូបមានឋានៈស្មើអគ្គនាយករង និង២រូបមានឋានៈស្មើប្រធាននាយកដ្ឋាន» «ខណៈប្រការ៣នៃសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលដដែលនេះ បានបញ្ជាក់ឲ្យដឹងថា ឧបនាយករដ្ឋមន្ត្រីទាំងអស់មានចំនួន៩រូប» ។

មន្ត្រីរាជការទូទាំងប្រទេសកម្ពុជា មានប្រហែលជាង២០ម៉ឺននាក់ ប៉ុន្តែក្នុងចំណោមពួកគេទាំងនោះ មានមន្ត្រីរាជការមួយចំនួនមិនដែលមកធ្វើការ ប៉ុន្តែពួកគេអាចបើកប្រាក់ខែដូចមន្ត្រីរាជការផ្សេងទៀតដែលមកធ្វើការជាធម្មតាដែរ។ មន្ត្រីរាជការដែលយកម៉ោងរដ្ឋ ទៅធ្វើការកន្លែងផ្សេង ឬមិនមកធ្វើការនៅស្ថាប័នរបស់ខ្លួន តែទទួលបានប្រាក់បៀវត្សដូចគេឯងដែរ ត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយឲ្យឈ្មោះថា «មន្ត្រីខ្មោច»។ « មន្ត្រីខ្មោច » អាចមានន័យពីរប្រភេទ។ ទី១៖ មានឈ្មោះស៊ីប្រាក់ខែ តែបុគ្គលមិនដែលមកធ្វើការសោះ (ទៅធ្វើការកន្លែងផ្សេង) និងទី២៖ មានតែឈ្មោះស៊ីប្រាក់ខែ តែគ្មានមនុស្សទេ(ឈ្មោះបន្លំ)។ ពិតណាស់ថា «មន្ត្រីខ្មោច»នៅក្នុងរដ្ឋបាលសាធារណៈ គឺជាបញ្ហាដ៏ចំណាស់។ ក្នុងមួយឆ្នាំៗ មានថវិកាជាតិមិនតិចទេដែលបានបាត់បង់ដោយសារតែការបើកប្រាក់ខែឲ្យ«មន្ត្រីខ្មោច»។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា មូលហេតុច្រើនយ៉ាងដែលនាំឲ្យកើតមាន «មន្ត្រីខ្មោច» នៅក្នុងរដ្ឋបាលសាធារណៈរបស់រដ្ឋ។ ដើម្បីជាថ្នូរទៅធ្វើការកន្លែងផ្សេង ហើយរក្សាមុខតំណែង និងការងារជាមន្ត្រីរាជការពេញក្របខណ្ឌរបស់ខ្លួន មន្ត្រីខ្មោចខ្លះបានចរចាគ្នាជាមួយប្រធានអង្គភាពរបស់ខ្លួន ដោយប្រាក់ខែរបស់ខ្លួនគឺត្រូវបានប្រធានអង្គភាពជាអ្នកបើកយកជាធម្មតា។ មន្ត្រីខ្មោចខ្លះទៀតយកម៉ោងរដ្ឋ ទៅបម្រើការនៅស្ថាប័នឯកជន ឬប្រកបការងារផ្សេងទៀត ប៉ុន្តែនៅតែមកបើកប្រាក់ខែពីស្ថាប័នរបស់ខ្លួនជាធម្មតា។ វត្តមានមន្ត្រីខ្មោចទាំងអស់នោះ បានធ្វើឲ្យបាត់បង់ថវិកាជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងមួយឆ្នាំៗ។ មានករណីផ្ទុះឡើងមួយដ៏ធំនៅក្នុងឆ្នាំ២០១៤ បានកើតនៅក្នុងស្ថាប័នរដ្ឋសភាជាតិ[39]។ តាំងពីដើមនីតិកាលទី៥នៃរដ្ឋសភាមកម្ល៉េះ ដែលរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ

---

38 *ចំនួនទីប្រឹក្សាលោក ងួន ញិល លើសទីប្រឹក្សាលោក កឹម សុខា ជាង៤ដង* សារព័ត៌មានថ្មីៗ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤។ http://thmeythmey.com/index.php?page=detail&ctype=article&id=19488&lg=kh&#detail_block_read

39 លោក សុន ឆ័យ បានប្រាប់ក្រុមអ្នកសារព័ត៌មាន នៅក្នុងរដ្ឋសភា នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ថា «*កាលពីជំនាន់សម្ដេចក្រុមព្រះ អ្នកដែលជាមន្ត្រី(រដ្ឋសភា) ផ្លូវការ ដែលលោកបានចាកចេញទៅពីឆ្នាំ២០០៦ហ្នឹង មានមិនដល់៤០០នាក់ផងទេ ហើយឥឡូវនេះ វាមានទៅដល់ជាង*

គណបក្សប្រជាជនកម្ពុជា មានអង្គភាពប្រឆាំងអំពើពុករលួយជាសេនាធិការ បានប្រកាសដាក់ចេញវិធានការកំចាត់មន្ត្រីខ្មោច ហើយនៅក្នុងឆ្នាំ២០១៤ អង្គភាពប្រឆាំងអំពើពុករលួយនេះបានព្រមានចាត់វិធានការទ្រង់ទ្រាយធំលើបញ្ហានេះ រហូតនៅដើមឆ្នាំ២០១៥ អង្គភាពនេះបានសហការ និងបានដាក់ចេញនូវចំណាត់ការលើមន្ត្រីខ្មោចនៅតាមក្រសួង និងស្ថាប័ននានារបស់រដ្ឋ ប៉ុន្តែរហូតមកដល់ពេលនេះ វិធានាការនេះហាក់ដូចជាមិនទទួលបានផ្លែផ្កា ឬគ្មានប្រសិទ្ធភាពនៅឡើយទេ[40]។ គេនៅមិនទាន់ឃើញមានរបាយការណ៍ណាមួយ បញ្ជាក់អំពីតួលេខមន្ត្រីខ្មោចរបស់ក្រសួង ឬស្ថាប័នរដ្ឋនីមួយៗ ដែលត្រូវបានចាត់វិធានការដោយអង្គភាពប្រឆាំងអំពើពុករលួយ ឬស្ថាប័នសាមីដែលមន្ត្រីខ្មោចទាំងនោះកំពុងធ្វើការឡើយ រហូតដល់ដំណាច់ឆ្នាំ២០១៥នេះ។ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងជាពិសេសអង្គភាពប្រឆាំងអំពើពុករលួយ ហាក់ដូចជាគ្មានចំណាត់ការធំដុំឲ្យបានម៉ត់ចត់ និងតឹងតែងចំពោះបញ្ហានេះនៅឡើយទេ។ របាយការណ៍រកឃើញថា នៅក្នុងឆ្នាំ២០១៥មានក្រសួងមហាផ្ទៃតែមួយគត់ ក្នុងចំណោមក្រសួងទាំង២៨ដែលបានដាក់វិធានការហាមប្រាមមិនឲ្យមន្ត្រីរបស់ខ្លួនធ្វើឲ្យមានតួនាទីពីរ ឬការងារពីរ ក្នុងពេលតែមួយ ដោយសារមូលហេតុថា អំពើនេះជាការប្រព្រឹត្តិផ្ទុយពីព្រះរាជក្រឹត្យ ស្តីពីការហាមឃាត់មន្ត្រីរាជការមានការងារពីរក្នុងពេលតែមួយ[41]។

ថ្វីបើរហូតមកដល់ពេលនេះ ពុំទាន់មានការសិក្សាពីទំហំនៃការចំណាយថវិកាជាតិ ទៅលើទីប្រឹក្សា និងជំនួយការនេះយ៉ាងណាក៏ដោយចុះ ប៉ុន្តែមានគេប៉ាន់ប្រមាណថា ទីប្រឹក្សា និងជំនួយការក្នុងម្នាក់ៗអាចចំណាយប្រាក់ខែចន្លោះ យ៉ាងហោចណាស់ប្រហែលពី២០០ដុល្លារ ទៅជិត៨០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែដែរ[42]។

ចំនួនសមាជិករដ្ឋាភិបាល មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលដ៏ធំបែប និងច្រើនបែបនេះ ត្រូវបានប្រើប្រាស់ដើម្បីផលប្រយោជន៍របស់គណបក្សកាន់អំណាច និងថែមទាំងបានបង្កើតបញ្ហាទំនាស់ក្នុងការគ្រប់គ្រង និងជាបន្ទុកដ៏ធ្ងន់ធ្ងររបស់ពលរដ្ឋកម្ពុជាទាំងអស់។ ជារួម រដ្ឋាភិបាលបានចំណាយថវិកាជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងមួយឆ្នាំៗ លើប្រាក់បៀវត្សរបស់ពួកគេ។ អ្វីទាំងអស់នេះ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់និន្នាការនយោបាយទាំងអស់ ខណៈដែលបំណុលបរទេស និងការបង់ពន្ធក៏កំពុងតែកើនផងដែរនោះ។

---

*១៣០០នាក់ ដែលជាចំនួនសឹងឡើងមួយទៅជាបីដែលយើងត្រូវការ ការបញ្ជាក់ដែលថា តើចំនួន១៣៥១នាក់នេះមកពីណាមកធ្វើអី? នៅក្នុងរដ្ឋសភានេះ»*។

[40] មាស សុខជា *អង្គភាពប្រឆាំងអំពើពុករលួយព្រមានចាប់ខ្លួនប្រធានស្ថាប័នដែលការពារមន្ត្រីខ្មោច* កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ អានផងដែរ អត្ថបទ*អង្គភាពប្រឆាំងអំពើពុករលួយព្រមានចាប់ខ្លួនប្រធានស្ថាប័ន ដែលការពារមន្ត្រីខ្មោច* កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤។ អានផងដែរអត្ថបទ មាស សុខជា and តាំង វីដា ស្ថាប័នរដ្ឋចាប់ផ្តើមពិនិត្យមន្ត្រីរាជការខ្មោច កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤។

[41] **MECH DARA**, Interior Ministry Reminds Civil Servants of Ban on Two Jobs, the Cambodia Daily, February 9, 2015.

[42] សូមអានអត្ថបទលេខយោងទី៣៧ខាងលើ។

## ៥.២. អំពើពុករលួយទាក់ទងនឹងនយោបាយ

ដូចដែលបានបង្ហាញខាងលើ អំពើពុករលួយទាក់ទងនឹងនយោបាយ គឺសំដៅការរំលោភអំណាច ការប្រើប្រាស់សិទ្ធិអំណាច និងតួនាទីជាមន្ត្រីនយោបាយ ឬមន្ត្រីមានអំណាចក្នុងមុខតំណែងដើម្បីផលប្រយោជន៍ដល់សាច់ញាតិ និងខ្សែស្រឡាយនិយម ការខ្វះតម្លាភាពក្នុងចរិកាជាតិ ភាពមិនប្រក្រតីជាមួយសំណូក និងការកិបកេងដោយមន្ត្រីនយោបាយ ការកិបកេង និងភាពមិនប្រក្រតីសំណូកដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែងជាដើម។

### ៥.២.១. ការរំលោភអំណាចដោយមន្ត្រីនយោបាយជាន់ខ្ពស់

របាយការណ៍រកឃើញ ១១ករណីពាក់ព័ន្ធនឹងការរំលោភអំណាច ដែលប្រព្រឹត្តដោយមន្ត្រីនយោបាយគណបក្ស និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាល។ មានករណីរំលោភអំណាចដោយរដ្ឋាភិបាល និងអាជ្ញាធរ ឬដោយថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ ដើម្បីបំរើផលប្រយោជន៍នយោបាយ ក្នុងនោះមានការចេញបទបញ្ជាដែលលើសពីច្បាប់កំណត់ ឬគ្មានច្បាប់ចែង ការរំលោភបទបញ្ញត្តិនានាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ស្ដីពីគោលការណ៍នៃការបែងចែងអំណាចរវាងស្ថាប័នកំពូលទាំងបី គឺស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ និងសិទ្ធិមួយចំនួនដូចជាស្ដីអំពីអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា និងព្រឹទ្ធសភា។ ជាករណីសិក្សាដោយឡែកមួយទៀត គឺការចាត់វិធានការលើលោក សម រង្ស៊ី ពាក់ព័ន្ធនឹងករណីបរិហារកេរ្តិ៍ លោក ណាំហុងដែលបានកាលពីឆ្នាំ២០១០ ដោយស្ថាប័នតុលាការ ក្រោមគំនាបនយោបាយ ខណៈដែលលោក សម រង្ស៊ី កំពុងតែត្រូវបានការពារដោយអភ័យឯកសិទ្ធិសភា និងការប្រកាសដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងការពារជាតិ និងកងកំលាំងប្រដាប់អាវុធមាននាយទាហានជាន់ខ្ពស់ ឲ្យគាំទ្រសកម្មភាពគណបក្សប្រជាជនដោយចំហ ឬប្រឆាំងអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងជាដើម។ ការបន្តដាក់សម្ពាធ និងគំរាមកំហែង ដោយប្រើប្រាស់ប្រព័ន្ធតុលាការលើអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងទាំង៧រូប ដែលត្រូវបានគេចោទប្រកាន់ថា បានជាប់ពាក់ព័ន្ធនឹងអំពើហឹង្សានៅស្ពាននាគកាលពីដើមឆ្នាំ២០១៤ ដែលអ្នកតំណាងរាស្ត្រទាំងអស់នោះ កំពុងមានអភ័យឯកសិទ្ធិសភាជាសិទ្ធិមានការការពារដោយច្បាប់កំពូលស្រាប់ ខុសពីពលរដ្ឋសាមញ្ញទូទៅ។ មានការរិះគន់ជាច្រើនចំពោះបញ្ហានេះ ដែលចោទជាចម្ងល់ផ្លូវច្បាប់ និងគោលការណ៍នៃការបែងចែកអំណាចរវាងស្ថាប័នកំពូលទាំងបីថា អ្នកតំណាងរាស្ត្រទទួលការការពារដោយច្បាប់កំពូលពេញទី ប៉ុន្តែនៅតែមានការរំលោភបំពាន និងការប្រើប្រាស់ឥទ្ធិពល និងអំណាចរបស់នីតិប្រតិបត្តិលើស្ថាប័នតុលាការ ដោយការធ្វើទុក្ខបុកម្នេញដោយការកោះហៅទៅសួរចម្លើយ ដូចពិរុទ្ធជនធម្មតាដែលគ្មានអភ័យឯកសិទ្ធិអ្វីសោះ។ ការបំពាន និងការប្រើឥទ្ធិពលជ្រៀតជ្រែកនេះ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរដល់គោលការណ៍ឯករាជ្យភាព និងការបែងចែងអំណាចគ្នា រវាងស្ថាប័ននយោបាយកំពូលទាំងបី ដែលពិតជាធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលជាស្មារតីដ៏សំខាន់បំផុតនៃរដ្ឋធម្មនុញ្ញកម្ពុជា និងជាពិសេសមុខមាត់របស់កម្ពុជានៅ

លើឆាកអន្តរជាតិ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញសេចក្តីសម្រេចរបស់ខ្លួនថា ប្រជាពលរដ្ឋមិនតម្រូវឲ្យបង់ថ្លៃប័ណ្ណបើកបរម៉ូតូកម្លាំង១២៥សេសេ បើទោះជាច្បាប់បានចែង និងតម្រូវឲ្យអ្នកបើកបរមានប័ណ្ណបើកបរក៏ដោយ។

### ៥.២.២. ភាពមិនប្រក្រតីនៃតំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម (Nepotism, Cronyism) និងទំនាស់ផលប្រយោជន៍ (Conflict of Interest)

តំណែង និងតួនាទីសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម គឺជាករណីលម្អៀងផលប្រយោជន៍ទៅសមាជិកនៃសាច់ញាតិ គ្រួសារ និងខ្សែស្រឡាយដោយមន្ត្រីនយោបាយ និន្នាការគណបក្សនយោបាយ ជាពិសេសការជួយជ្រោមជ្រែងលើកបន្តុប ឬតែងតាំងឱ្យសមាជិកសាច់ញាតិ គ្រួសារ និងខ្សែស្រឡាយរបស់ខ្លួនកាន់តំណែងក្នុងស្ថាប័នរបស់ខ្លួនដោយការជ្រើសរើសដោយគ្មានតម្លាភាពជាដើម។ ការសង្កេតបានរកឃើញភាពមិនប្រក្រតីក្នុងរឿងនេះ មានចំនួន៨ករណីដែលជាករណីថ្មីសំខាន់ៗត្រូវបានកត់ត្រាក្នុងឆ្នាំ២០១៥នេះ។

តំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយមត្រូវបានមើលឃើញថា កើតមាននៅស្ទើរគ្រប់ក្រសួង ស្ថាប័ន នាយកដ្ឋាន និងមន្ទីរតាមបណ្តារាជធានី ខេត្តនានាក្នុងប្រទេសកម្ពុជា។ ហើយបញ្ហានេះនៅតែបន្តកើតមាន និងគ្មានការដោះស្រាយ។ បើទោះបីជា កម្ពុជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើបក្សពួកនិយម ខ្សែស្រឡាយសាច់ញាតិនិយម ឬគ្រួសារនិយមក៏ដោយ តែបើគិតពីអភិបាលកិច្ចល្អ ការប្រព្រឹត្តិអំពើបក្សពួក ខ្សែស្រឡាយសាច់ញាតិ ឬគ្រួសារនិយម គឺជារឿងដែលមិនអាចទទួលយកបាន ហើយវាជាទំនាស់ផលប្រយោជន៍ បណ្តាលឲ្យខូចប្រព័ន្ធដឹកនាំបែបអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រស្នូលរបស់រដ្ឋាភិបាល ច្បាប់ប្រឆាំងអំពើពុករលួយ និងមិនស្របតាមកតិកាសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងអំពើពុករលួយ។ ភាពមិនប្រក្រតីនៃការតែងតាំងបក្សពួក ខ្សែស្រឡាយ សាច់ញាតិនិយម ឬគ្រួសារនិយមក្នុងស្ថាប័នរដ្ឋ អាចឈានទៅប្រព្រឹត្តអំពើពុករលួយបានយ៉ាងងាយ ដោយសារពួកគេមានឥទ្ធិពលទៅវិញទៅមក ហើយវាក៏ជាបញ្ហាប្រឈមយ៉ាងធំសំរាប់ការប្រឆាំងអំពើពុករលួយផងដែរ។

ការចាត់តាំង ឬការតែងតាំងជាលក្ខណៈបក្សពួក ខ្សែស្រឡាយសាច់ញាតិ ឬគ្រួសារនិយម ដោយគ្មានតម្លាភាពដែលបានបិទឱកាស និងរារាំងការចូលរួមដោយពេញលេញ។ ករណីជាច្រើនកំពុងបានកើតមាននៅក្នុងគណបក្សនយោបាយ និងតាមស្ថាប័នរដ្ឋដោយគ្មានការត្រួតពិនិត្យ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនក៏ធ្លាប់បានព្រមានដល់មន្ត្រីមិនឱ្យក្រសួង ឬស្ថាប័ននីមួយៗក្លាយជាទីកន្លែងសម្រាប់រៀបចំឱ្យមានបក្សពួក ខ្សែស្រឡាយ សាច់ញាតិ ឬគ្រួសារនិយម [43] និងថាការងាររបស់ពួកគេមិនមែនជាជម្ងឺតពូជក៏ដោយ[44]។

ជាការពិត សាច់ញាតិ កូន ប្តី ប្រពន្ធនៃអ្នកនយោបាយ ឬសមាជិកគណបក្សនយោបាយ

---

[43] ហេឡូវីអូអេ, ការកាត់បន្ថយបញ្ហាគ្រួសារនិងបក្សពួកនិយមនៅកម្ពុជា, ថ្ងៃ១៤ ខែវិច្ឆិកា ឆ្នាំ២០១៤

[44] http://www.phnompenhpost.com/lift/nepotism-family-problem

ត្រូវបានជាប់ឆ្នោត មិនមែនជាបញ្ហានោះទេ ប៉ុន្តែបញ្ហានៅត្រង់ថា របៀបដែលពួកគេក្លាយជាបេក្ខជនឈរឈ្មោះជាតំណាងរាស្ត្រតាមនីតិវិធីគ្មានតម្លាភាព។ នៅកម្ពុជា មេដឹកនាំគណបក្ស គឺជាមនុស្សមានអំណាច និងសិទ្ធិសម្រេចតែងតាំងបេក្ខជន ដាក់ទៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ក្រុមមេដឹកនាំគណបក្សសំខាន់ៗបានដាក់ ឬជ្រើសរើសាច់ញាតិ កូន ប្តី ប្រពន្ធរបស់ខ្លួនឱ្យឈរជាបេក្ខជន។ ការជ្រើសរើសតែងតាំងនេះ គឺគ្មានតម្លាភាព ធ្វើឱ្យមិនមានការប្រកួតប្រជែងដោយស្មើភាពគ្នាក្នុងគណបក្សនោះ។

មានករណីតែងតាំង និងដាក់ជំនួសកូនប្រុសទាំងពីរ និងក្មួយប្រុសបង្កើតរបស់លោក ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំទីស្តីការរដ្ឋមន្ត្រីឲ្យក្លាយជាតំណាងរាស្ត្រខេត្តតាកែវ និងកូនប្រុសម្នាក់ទៀតត្រូវបានតម្លើងឋានៈ និងតែងតាំងជាអគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកស្រាប់។ ដោយឡែក ក្មួយប្រុសបង្កើតរបស់លោកម្នាក់ត្រូវបានតែងតាំងជាជំនួយការផ្ទាល់របស់លោកផ្ទាល់។ ក្រៅពីករណីលោក សុខ អាន មានករណីផ្សេងទៀតពាក់ព័ន្ធនឹងលោក សៅ សុខា ជាប្រធានប្រធានសហព័ន្ធបាល់ទាត់កម្ពុជា និងជានាយឧត្តមសេនីយ៍ផ្កាយបួន អគ្គមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលកូនប្រសារប្រុសរបស់លោក ឈ្មោះ ប៉ោ វណ្ណនិត អតីតមេបញ្ជាការរងកងរាជអាវុហត្ថក្រុងភ្នំពេញ ត្រូវបានតែងតាំងជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប។ លោក ប៉ោ វណ្ណនិត គឺជាកូនប្រុសបង្កើតរបស់លោកឧត្តមសេនីយ៍ ប៉ោ វណ្ណៈ មេបញ្ជាការកងរាជអាវុធហត្ថខេត្តបាត់ដំបង។ ករណីមួយទៀតដែរ កូនប្រុសរបស់លោកឧបនាយកដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបច្ចុប្បន្នជាតំណាងរាស្ត្រខេត្តព្រៃវែងដោយព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៣៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ ។

មានករណីមួយផ្សេងទៀត គឺលោក ដួង សារឿនជាប្រធានមន្ទីរធម្មការ និងកូនស្រីឈ្មោះ វ៉ា វ៉ារី ដែលត្រូវបានតែងតាំងជាអនុប្រធានមន្ទីរក្តោបក្តាប់រដ្ឋបាលហិរញ្ញវត្ថុ ត្រូវបានគេចោទប្រកាន់ថា មានអំពើពុករលួយបានកើតចេញពីគ្រួសារនិយម បក្សពួកនិយមក្នុងមន្ទីរដែលមានឪពុកជាប្រធានមន្ទីរ និងកូនស្រីជាអនុប្រធានមន្ទីរនេះ។ ករណីនេះ ត្រូវបានបុគ្គលិកធ្វើការនៅក្នុងមន្ទីរធម្មការខេត្តកោះកុងចោទប្រកាន់ ទំហំនៃការប្រព្រឹត្តអំពើពុករលួយ គឺពិតជាបានធ្វើឱ្យមន្ត្រីផ្សេងទៀត ដែលមានប្រវត្តិការងារយូរអង្វែង ត្រូវតែចេញមុខលាតត្រដាងពីករណីប្រើអំណាចពុករលួយ ដោយបាត់បង់ថវិកាជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងឆ្នាំ២០១៣ និង២០១៤(45)។

មានករណីជាច្រើនទាក់ទងនឹងការចាត់តាំង និងតែងតាំងសមាជិកគ្រួសារ សាច់ញាតិបង្កើត រួមទាំងប្តី ឬប្រពន្ធ ឬកូន ដើម្បីក្លាយជាមន្ត្រីសាធារណៈរបស់រដ្ឋក្នុងមុខតំណែងក្នុងស្ថាប័នរដ្ឋដែលសព្វថ្ងៃនេះពួកគេនៅបម្រើការ ហើយការតែងតាំងនេះនៅតែបន្តកើតមាន ហើយសម្រាប់អ្នកត្រូវបានតែងតាំងរួចមកហើយ គឺនៅតែបន្តធ្វើការក្នុងទម្រង់បក្សពួកនិយម និងគ្រួសារនិយមបែបនេះដដែលដោយគ្មានការផ្លាស់ប្តូរអ្វីឡើយ។

[45] *ធ្លាយរឿងពុករលួយ និងគ្រួសារនិយមនៅមន្ទីរធម្មការខេត្តកោះកុង* កាសែតព័ត៌មានជាតិ ចេញផ្សាយថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៥។

ករណីផ្សេងទៀត ដែលខុមប្រែហ្វលបានកត់ត្រាពីឆ្នាំកន្លងទៅ ដែលកំពុងបន្តកាន់កាប់តំណែង ដូចជាករណីគ្រួសារ ខ្សែស្រឡាយ និងសាច់ញាតិនិយមក្នុងស្ថាប័នក្រសួងរបស់ខ្លួន ជាអ្នកមានអំណាចរដ្ឋមន្ត្រីដែលតែងតាំងកូន ឬ/និងប្រពន្ធ និងសមាជិកក្រុមគ្រួសាររបស់ខ្លួន ត្រូវបានចាត់តាំង ឬតែងតាំងជាមន្ត្រីសាធារណៈរបស់រដ្ឋក្នុងមុខតំណែង ស្ថិតនៅក្រោមការគ្រប់គ្រងស្ថាប័នរបស់ខ្លួន មានលោក សុខ អាន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស លោក ចម ប្រសិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលនៅពេលនេះត្រូវប្តូរទៅធ្វើជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល លោក ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា លោកងួន ញ៉ិលអនុប្រធានទីពីរនៃរដ្ឋសភា ព្រមទាំងរដ្ឋមន្ត្រីនៅតាមបណ្តាក្រសួង មន្ទីរជាច្រើនផ្សេងទៀត សូម្បីតែលោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ក៏មានកូនស្រីម្នាក់កាន់ការងារនៅក្រោមបង្គាប់របស់លោកដោយផ្ទាល់ផងដែរ[46]។

ជាមួយគ្នានេះ មានករណីជាច្រើនទាក់ទងនឹងវិសមិតភាពមន្ត្រីសាធារណៈរបស់រដ្ឋ ដែលមិនទាន់ដោះស្រាយនៅឡើយផងដែរ ដែលពួកគាត់ជាមន្ត្រីសាធារណៈក្នុងតំណែង ជាពិសេសសមាជិករាជរដ្ឋាភិបាល កាន់កាប់ ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដែលករណី ឬសកម្មភាពទាំងនេះគឺជាការរំលោភបំពានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា១២០ ដែលបានចែងថា *«មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនឹងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ»* និងផ្ទុយពីមាត្រា៣៥ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា *«ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវការចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល»*។ ឧទាហរណ៍ ករណីចោទប្រកាន់ ស្តីពីវិសមិតភាពថាបានប្រព្រឹត្តផ្ទុយទៅនឹងមាត្រាខាងលើ លោក កៅ គឹមហួន ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីដែលជាសមាជិករាជរដ្ឋាភិបាល ហើយមានតួនាទីជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជា។ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជា គឺជាស្ថាប័នឯកជន ក៏ដូចជាផ្នែកនៃ*វិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម*[47]។

បញ្ហាបក្សពួក និងគ្រួសារនិយម ត្រូវបានគេរាប់បញ្ចូលទៅក្នុងទម្រង់មួយនៃអំពើពុករលួយ ដែលក្រៅពីសំណូក ការកេងប្រវ័ញ្ច ការលួចបន្លំ ការសម្លុតគំរាម និងអំពើពុករលួយផ្នែកនយោបាយ។ បក្ខពួកនិយម (Nepotism) គឺជាយន្តការនៃការរំលោភអំណាច និងលើកតម្កើងតែក្រុម ឬញាតិសន្តានរបស់អ្នកដឹកនាំដើម្បីគ្រប់គ្រងតួនាទីណាមួយ។ បញ្ហាបក្សពួកនិយមក្នុងក្រសួង ឬស្ថាប័នរដ្ឋនេះនាំមកនូវផលវិបាកជាច្រើន ដូចជាការប្រកួតប្រជែងមិនស្មើភាព និងគុណភាព

---

[46] ប៊ិច សុធារី and Kevin Ponniah, *សង្គ្រោះជាតិស្នើអគ្គលេខាធិការសភាពន្យល់ពីការគ្រប់គ្រងបុគ្គលិកដ៏ច្រើនសម្បើម* http://www.postkhmer.com/; Thu, 23 October 2014

[47] គេហទំព័រដើមឆ្នោត ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥។

ការងារធ្លាក់ចុះជាដើម។ លើសពីនេះ វានឹងធ្វើឱ្យមានការប្រព្រឹត្តិអំពើពុករលួយទ្រង់ទ្រាយធំក្នុងស្ថាប័ននោះ។*«វាអាចធ្វើឱ្យបាក់ទឹកចិត្តដល់បញ្ញវន្ត ឬក៏អ្នកដែលរៀនសូត្រ អ្នកដែលមានជំនាញ និងសមត្ថភាពពិតប្រាកដ ដែលគាត់ចង់ចូលទៅបម្រើស្ថាប័ននោះ ហើយគាត់មិនមានឱកាស ព្រោះត្រូវបានឆក់យក ឬក៏រក្សាទុកដើម្បីឱ្យក្រុមគ្រួសារសាច់ញាតិ។ ពេលណាដែលយើងមាន ក្រុមគ្រួសារ ឬបក្សពួកនិយមអញ្ចឹង វាអាចធ្វើឱ្យការបំពេញការងារមិនសូវមានប្រសិទ្ធភាព ហើយ និងគុណភាព»*[48]។ ទាក់ទងនឹងការប្រកាសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីឆ្នាំកន្លងទៅ ស្តីពីការលុបបំបាត់បញ្ហាគ្រួសារនិយម និងការរិះគន់របស់លោកនាយករដ្ឋមន្ត្រី លើបញ្ហាអន្តរាគមន៍នានារបស់ញាតិសន្តានដែលជាប្តី ប្រពន្ធកាន់តំណែងខ្ពស់ក្នុងជួររដ្ឋាភិបាល លោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានប្រសាសន៍ដោយខ្លីថា វាជាកិច្ចការរបស់បក្សមិនទាក់ទងអ្វីនឹងអង្គភាពរបស់លោកទេ៖ *«សូមជម្រាបថា នោះជាកិច្ចការរបស់បក្ស។ កិច្ចការរបស់អង្គភាពប្រឆាំងអំពើពុករលួយ គឺឯករាជ្យ។ ខ្ញុំសុំមិនលូកលាន់ទេ។ កុំនាំខ្ញុំច្របូកច្របល់ បាយបិណ្ឌ ជាបាយបាត្រ»*[49]។

### ៥.២.៣. ភាពមិនប្រក្រតីនៃសំណូកនយោបាយ និងការកិបកេងដោយមន្ត្រីនយោបាយមានអាណត្តិ

មន្ត្រីនយោបាយ ក្នុងរបាយការណ៍នេះសំដៅលើមន្ត្រីមានអាណត្តិ ដោយការបោះឆ្នោត និងអាណត្តិដែលកើតឡើង និងបញ្ចប់ទៅវិញដោយសារការផ្តើម និងបញ្ចប់អាណត្តិនីមួយៗនៃការបោះឆ្នោត។ មន្ត្រីទាំងនោះ រួមមានសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ និងសមាជិកក្រុមប្រឹក្សាខេត្ត/រាជធានី រដ្ឋលេខាធិការ រដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី សមាជិកសភា និងរដ្ឋសភា ព្រឹទ្ធសភា និងសមាជិករាជរដ្ឋាភិបាល។ របាយការណ៍ឆ្នាំ២០១៥នេះ បានរកឃើញមានចំនួន១១ករណីពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃសំណូក និងការកិបកេងប្រវ័ញ្ច ប្រព្រឹត្តដោយមន្ត្រីនយោបាយ។

ច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ នៅតែជាច្បាប់ដែលមិនទាន់បានឆ្លុះបញ្ចាំងអំពីតម្លាភាពពិតប្រាកដនៅឡើយទេ។ មិនតម្លាភាពត្រង់ថា ការប្រកាសទ្រព្យសម្បត្តិដែលតម្រូវដោយច្បាប់ប្រឆាំងអំពើពុករលួយ មិនបានតម្រូវឲ្យប្រកាសដោយបើកចំហជាសាធារណៈ ឬថាព័ត៌មានស្តីពីទ្រព្យសម្បត្តិរបស់មន្ត្រីទាំងនោះត្រូវបានគេចាត់ទុកថា ជាព័ត៌មានសម្ងាត់ ដោយមិនអនុញ្ញាតឲ្យលេចចេញទៅក្រៅឲ្យស្ថាប័ន ឬបុគ្គលណាម្នាក់ដឹងបានឡើយ ក្រៅតែពីប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។ មានការចោទប្រកាន់ និងទឡ្ហីករណ៍អំពីភាពមិនប្រក្រតីសំណូក និងការកិបកេងដោយមន្ត្រីនយោបាយ ដែលក្នុងនោះពាក់ព័ន្ធនឹងករណីកិបកេងថវិកា ការរំលោភដីធ្លី និងការបណ្តេញចេញដោយបង្ខំ ភាពមិនប្រក្រតីក្នុងការសូកប៉ាន់ដើម្បីបានតំណែងល្អៗ កន្លែងរកប្រាក់

---

48 លោកព្រាប កុល ក្នុងកិច្ចសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី ក្នុងអត្ថបទ *«សង្គមស៊ីវិលចង់ឱ្យបញ្ចូលបញ្ហាបក្សពួកនិយមក្នុងច្បាប់ប្រឆាំងអំពើពុករលួយ»* ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦។

49 សូមអានអត្ថបទខាងលើ។

បានច្រើន ការដោះដូរទីតាំងក្រសួង មន្ទីរ ការិយាល័យសាធារណៈជាដើម។

ករណីជម្លោះដីធ្លីដ៏រ៉ាំរ៉ៃនៅតំបន់បឹងកក់ គឺជាបញ្ហាដែលលេចធ្លោ ក្នុងចំណោមករណីរំលោភបំពានដីធ្លី និងការបណ្តេញចេញនៃតំបន់ផ្សេងៗទៀតក្នុងរាជធានីភ្នំពេញ ដែលរហូតមកដល់ពេលនេះ គឺជនរងគ្រោះពីការបណ្តេញចេញដោយបង្ខំ មិនទាន់បានដោះស្រាយឲ្យអស់នៅឡើយទេ។ ភាពមិនប្រក្រតីក្នុងការដោះដូរទីតាំងក្រសួងសុខាភិបាល និងការផ្តល់លុយគោលនយោបាយដោយគ្មានច្បាប់ ដែលមានទីតាំងនៅវិថីកម្ពុជាក្រោមក្នុងសង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញត្រូវដោះដូរទៅទីតាំងថ្មីក្នុងខណ្ឌទួលគោក ស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដែលការដោះដូរទីតាំងនេះ ត្រូវបានបែងចែកលុយពីការលក់ទ្រព្យសម្បត្តិសាធារណៈ។

## ៥.២.៤.ភាពមិនប្រក្រតីនៃសំណូក និងកិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែង

របាយការណ៍បានរកឃើញ និងកត់ត្រាបានចំនួន១៣៥ករណី (ស្មើនឹងជាង៤៥ភាគរយ) លើករណីសរុប ដែលពាក់ព័ន្ធនឹងសំណូកការកិបកេង ប្រព្រឹត្តប្រព្រឹត្តដោយមន្ត្រីរាជការសាធារណៈក្នុងតំណែងដែលជាមន្ត្រីកងយោធពលខេមរភូមិន្ទ មន្ត្រីតុលាការ និងនគរបាលក្នុងមុខតំណែង។ មានចំនួន៦៤ករណី ដែលត្រូវបានប្រព្រឹត្តដោយមន្ត្រី រាជការសាធារណៈក្នុងតំណែងដែលបម្រើការងារជាមន្ត្រីរាការស៊ីវិល ក្នុងស្ថាប័នរដ្ឋមាន៤៣ករណីផ្សេងទៀត ប្រព្រឹត្តដោយស្ថាប័ន កងកំលាំងប្រដាប់អាវុធ ១៥ភាគរយប្រព្រឹត្តដោយមន្ត្រីតុលាការ និង១២ភាគដោយអាជ្ញាធរមូលដ្ឋាន។ ការរកឃើញបង្ហាញថា គ្រប់២៦ខេត្ត/រាជធានីទាំងអស់សុទ្ធតែរកឃើញនូវករណីនៃភាពមិនប្រក្រតីនៃប្រព្រឹត្តអំពើពុករលួយ និងរំលោភអំណាច ឬសមត្ថកិច្ចផ្នែករដ្ឋបាលដោយមន្ត្រីសាធារណៈក្នុងមុខតំណែង ដោយរាជធានីភ្នំពេញបាននាំមុខគេ គឺមាន២៩ករណី និងខេត្តមណ្ឌលគិរីមាន១០ករណី។ សម្រាប់២៣ខេត្ត ក្រៅពីនេះ គឺមានតិចជាង១០ករណី និងច្រើនជាង១ករណី។ ភាពមិនប្រក្រតីនៃសំណូក និងការកិបកេងប្រព្រឹត្តប្រព្រឹត្តដោយមន្ត្រីសាធារណៈក្នុងតំណែងនេះ គឺរបាយការណ៍សង្កេត និងប្រមូលករណីត្រឹមតែមន្ត្រី ដែលកំពុងកាន់តំណែង និងឋានៈជា ទី១៖ មន្ត្រីរាជការស៊ីវិល ដែលមានឋានៈប្រធាន ឬអនុប្រធានមន្ទីរ/ការិយាល័យក្រសួង/មន្ទីរ/ប្រធាន និងអនុប្រធាននាយកដ្ឋាន អគ្គនាយក/អគ្គាធិការ/អគ្គលេខាធិការ និងអគ្គនាយករង/អគ្គារធិការរង/អគ្គលេខាធិការរង អភិបាលរងក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី ប្រធាន និងអនុប្រធានឧទ្ទកាល័យ ឯកអគ្គរដ្ឋទូត លេខាធិការប្រចាំស្ថានទូត និងកុងស៊ុលនៅក្រៅប្រទេស ទី២៖ នគរបាលនៃក្រសួងមហាផ្ទៃដែលមានឋានៈ នាយប៉ុស្តិ៍ នាយប៉ុស្តិ៍រងនៃឃុំ/សង្កាត់ អធិការ អធិការរងក្រុង/ស្រុក/ខណ្ឌ ប្រធាន អនុប្រធានការិយាល័យ នាយកដ្ឋាន ស្នងការ ស្នងការរងខេត្ត និងអគ្គស្នងការរាជធានី ទី៣៖ កងយោធពលខេមរភូមិន្ទដែលមានឋានៈ មេបញ្ជាការ មេបញ្ជាការរងនៃកងពល មេបញ្ជាការ មេបញ្ជាការរងតំបន់សឹក មេបញ្ជាការកងពល មេបញ្ជាការ មេបញ្ជាការរង

យោធភូមិភាគ តំបន់ អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ។ ផ្នែកខាងអាវុធហត្ថ៖ នាយអាវុធហត្ថ នាយអាវុធហត្ថរង ស្រុក/ខណ្ឌ/ក្រុង មេបញ្ជាការកងរាជអាវុធហត្ថខេត្ត/រាជធានី អគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរងរាជអាវុធហត្ថលើផ្ទៃប្រទេស។

មន្ត្រីកងតុលាការក៏មានព័ត៌មានចោទប្រកាន់ ទាក់ទងនឹងការកិបកេង និងភាពមិនប្រក្រតីសំណូកដែរ ឧទាហរណ៍ ករណីចោទប្រកាន់ និងចាប់ខ្លួនដោយអង្គភាពប្រឆាំងអំពើពុករលួយលើប្រធានសាលាដំបូងរាជធានីភ្នំពេញ លោក អាំង មាលតីជាដើម។ ក្រៅពីនេះ មន្ត្រីអាជ្ញាធរមូលដ្ឋាន មន្ត្រីបំរើការនៅវិស័យជលផល និងព្រៃឈើ ដូចជានាយខណ្ឌ/សង្កាត់រដ្ឋបាលជលផល និងព្រៃឈើក៏មានជាប់ពាក់ព័ន្ធនឹងអំពើភាពមិនប្រក្រតីសំណូក ក្នុងពេលបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដែរ ដូចជាករណីពាក់ព័ន្ធនឹងបទគំរាមកំហែងយករបស់នាយសង្កាត់ និងនាយរងសង្កាត់រដ្ឋបាលព្រៃនៅខេត្តមណ្ឌលគិរី រតនគិរី និងខេត្តជាប់តាមព្រំដែនវៀតណាមពាក់ព័ន្ធនឹងករណីអនុវត្តឲ្យមានការនាំឈើចេញដោយខុសច្បាប់ និងការអនុញ្ញាតឲ្យជនជាតិវៀតណាមចូលមកទឹកដីកម្ពុជាកាប់ឈើតាមតែអំពើចិត្តជាដើម។

## ៥.៣. ភាពមិនប្រក្រតីនៃទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សសំខាន់ៗ

ឆ្នាំ២០១៥នេះ ក៏ដូចជាឆ្នាំមុនៗដែលគ្មានព័ត៌មាន ឬរបាយការណ៍ ស្តីអំពីទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ជាពិសេសគណបក្សកាន់អំណាច។ របាយការណ៍ស្តីពីហិរញ្ញវត្ថុគណបក្សកាន់អំណាច មិនថាសាធារណជនទេ សូម្បីតែសមាជិករបស់គណបក្សមិនដែលបានទទួលរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ។ របៀបវារៈនៃកិច្ចប្រជុំ និងសន្និបាតរបស់គណបក្សធំៗ ពុំដែលបានលើកឡើងពីការធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬបច្ចុប្បន្នភាពស្ថានភាពហិរញ្ញវត្ថុគណបក្ស។ គណបក្សទាំងនេះបានយកលេសថា បានធ្វើរបាយការណ៍ប្រចាំឆ្នាំទៅក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណបក្សនយោបាយខ្លះ ជាពិសេសគណបក្សកាន់អំណាចបានលក់ និងជួលអគារ/ស្នាក់ការគណបក្ស។ កន្លងមក គេឃើញមានការប្រកាសអំពីចំនួនទឹកប្រាក់ជាមូលនិធិទូរទស្សន៍ ឬការរៃអង្គាសប្រាក់សម្រាប់សកម្មភាពរបស់គណបក្សសង្គ្រោះជាតិ ដែលទទួលបានពីសប្បុរសជនទាំងក្នុង និងក្រៅស្រុក។

ក្រោយពីបានសង្កេត ទៅលើការចំណាយក្នុងយុទ្ធនាការបោះឆ្នោត ខុមហ្វ្រែលបានសង្កេតថែមទៀត លើការបន្តផ្តល់ប្រាក់កាសរបស់បុគ្គលឯកជនសម្រាប់ជាអំណោយ ឬការកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមេដឹកនាំគណបក្សកាន់អំណាច ខណៈដែលករណីទាំងនេះ ក្លាយជាការទិញសន្លឹកឆ្នោតក្នុងយុទ្ធនាការនៃការឃោសនាបោះឆ្នោត និងឥទ្ធិពលនយោបាយក្នុងការសម្រេចរបស់រដ្ឋាភិបាល និងរដ្ឋសភា។

## ៦. សន្និដ្ឋាន

ការសង្កេតក្នុងអំឡុងចន្លោះពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៥ រកឃើញយ៉ាងហោចណាស់មាន២៩៧ករណី ជាអំពើពុករលួយនយោបាយ និងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ។ ចំនួនករណីដែលប្រមូល និងកត់ត្រាទុកនេះបានកើនឡើងចំនួន៨០ករណី លើសចំនួនករណីដែលប្រមូលបាន និងកត់ត្រាទុកកាលក្នុងឆ្នាំ២០១៤កន្លងទៅ។ ក្នុងនោះ ចំនួន១១ករណីពាក់ព័ន្ធនឹងការរំលោភអំណាចធ្ងន់ធ្ងរ ប្រព្រឹត្តដោយថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ ថ្នាក់ដឹកនាំស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ ឬថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សនយោបាយជាដើម។ ភាពមិនប្រក្រតីនៃសំណូក និងកិបកេង ប្រព្រឹត្តដោយមន្ត្រីសាធារណៈក្នុងតំណែងមានចំនួន១៣៥ករណី ក្នុងនោះ ត្រូវបានចាត់វិធានការបានចំនួន៤៣ករណី ខណៈដែលករណីដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ មានក្នុងគោលបំណងបម្រើផលប្រយោជន៍ឲ្យគណបក្សនយោបាយមានចំនួន១៣៣ករណី ក្នុងនោះមាន២ករណី ត្រូវបានចាត់វិធានការ។ ករណីភាពមិនប្រក្រតីសំណូក និងការកិបកេងប្រព្រឹត្តដោយមន្ត្រីនយោបាយមានអាណត្តិដោយការបោះឆ្នោតមាន១១ករណី និងភាពមិនប្រក្រតីនៃករណីពាក់ព័ន្ធនឹងការតែងតាំងសាច់ញាតិខ្សែស្រឡាយនិយមមាន៨ករណី។

មានការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ក្នុងគោលបំណងបម្រើផលប្រយោជន៍ឲ្យគណបក្សនយោបាយមានចំនួន១៣៣ករណី ដែលរបាយការណ៍សង្កេតបានកត់ត្រាដូចខាងលើ មានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់ ឬមន្ត្រីជាន់ខ្ពស់នៃស្ថាប័នកងកម្លាំងប្រដាប់អាវុធ (កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ) និងមន្ត្រីសាធារណៈក្នុងមុខតំណែង និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ(វិទ្យុ និងទូរទស្សន៍ជាតិ) ក្នុងការធ្វើសកម្មប្រឆាំង ឬគាំទ្រចំពោះគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្សផ្សេង។ ចំនួនករណីនៃការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ក្នុងឆ្នាំ២០១៥នេះ មានចំនួន១៣៣ករណី ដូច្នេះគឺមានការកើនឡើងជាងឆ្នាំ២០១៤ ដែលក្នុងឆ្នាំ២០១៤កន្លងទៅ មានត្រឹមតែ៦០ករណី។ ករណីខាងលើកើតមាននៅ២៤ ក្នុងនៃ២៦រាជធានី/ខេត្តទូទាំងប្រទេស។ ដោយឡែក នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះវិហារ មានករណីប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឲ្យគណបក្សនយោបាយច្រើនជាងគេ បើប្រៀបធៀបជាមួយខេត្តផ្សេងទៀត។

ករណីរំលោភអំណាច ប្រព្រឹត្តដោយថ្នាក់ដឹកនយោបាយជាន់ខ្ពស់ និងស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលមានចំនួន១១ករណី។

ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ដោយឡែកទូរទស្សន៍ជាតិកម្ពុជា (ទទក) ត្រូវបានគេប្រើប្រាស់ជាឧបករណ៍ផ្សព្វផ្សាយគោលនយោបាយឃោសនាឱ្យគណបក្សកាន់អំណាច ឬឃោសនាវិះគន់ វាយប្រហារប្រឆាំង ហើយសកម្មភាពផ្សព្វផ្សាយនេះ នៅតែបន្តភាពលំអៀងក្នុងការផ្សព្វផ្សាយរបស់ខ្លួន ក្នុងឋានៈជាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដដែល ក្នុងឆ្នាំ២០១៥កន្លងទៅថ្មីៗនេះ មន្ត្រីអង្កេត

ផ្នែកវិទ្យុ និងទូរទស្សន៍ជាតិបានធ្វើការសន្និដ្ឋានថា កម្មវិធីផ្សាយព័ត៌មានទូរទស្សន៍ជាតិកម្ពុជាប្រហែល៧០% មាននិន្នាការទំនោរទៅរកគណបក្សកាន់អំណាច។

ស្ថានភាពតម្លាភាពនៃការគ្រប់គ្រងថវិកានៅកម្ពុជា គឺនៅមានកម្រិតទាបខ្លាំងនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ និងផ្សព្វផ្សាយព័ត៌មាន ស្តីពីដំណើរការនៃតាក់តែងសេចក្តីព្រាងថវិកាជាតិ និងច្បាប់ថវិកាជាតិដែលអនុម័តដោយរដ្ឋសភាឲ្យបានគ្រប់គ្រាន់ ទូលំទូលាយដល់សាធារណជនទូទៅ ជាពិសេសដល់តំណាងរាស្ត្រគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងអង្គការសង្គមស៊ីវិល អ្នកស្រាវជ្រាវជាដើម។ កង្វះតម្លាភាពនេះ ក៏កើតមានផងដែរ ចំពោះការគ្រប់គ្រងថវិកាជាតិលើការចំណាយ និងប្រភពចំណូល។ រដ្ឋសភាមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីសិក្សាស្រាវជ្រាវ លម្អិតអំពីពង្រាងច្បាប់ និងការធ្វើអធិការកិច្ចទៅលើរបាយការណ៍ និងសេចក្តីព្រាងច្បាប់ថវិកាជាតិ។ ជាមួយគ្នានេះផងដែរ សមាជិកសភាគណបក្សកាន់អំណាច ហាក់ដូចជាដើរតួនាទីជាអ្នកការពាររដ្ឋាភិបាល ក្នុងការអនុម័តច្បាប់ ស្តីពីថវិកាជាតិជារៀងរាល់ឆ្នាំ។ គេឃើញជាទូទៅថា សេចក្តីព្រាងច្បាប់ថវិកាជាតិ មិនដែលត្រូវបានអនុម័ត ដោយមានវត្តមានសម្លេងគណបក្សប្រឆាំងឡើយ។

# ៧. ឧបសម្ព័ន្ធ

## ៧. ១. ឧទាហរណ៍ ឯកសារខ្លះទាក់ទិននឹងគណបក្សប្រជាជនមានវត្តមានសម្ព័ន្ធក្នុងស្ថាប័នរដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក)**
**សាខាក្រសួងមហាផ្ទៃ**

*លេខ :..១៧../១៥.....ស.ស.យ.ក/ម.ផ*

*រាជធានីភ្នំពេញ, ថ្ងៃទី..១១..ខែមិថុនា ឆ្នាំ ២០១៥*

**សូមគោរពជូន**
**ឯកឧត្តម សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** *សារលិខិតចូលរួមរំលែកទុក្ខ ចំពោះមរណភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា។*

*យើងខ្ញុំជាមន្ត្រីរាជការក្រោមចំណុះក្រសួងមហាផ្ទៃ ដែលជាសមាជិក សមាជិកា នៃសហភាពសហព័ន្ធយុវជនកម្ពុជា មានក្តីសោកសង្រេង និងអាឡោះអាល័យឥតឧបមា ចំពោះការបាត់បង់វីរៈរដ្ឋបុរសប្រវត្តិសាស្ត្រ ក្នុងដំណើរដឹកនាំសង្គ្រោះ ការពារ កសាង និងអភិវឌ្ឍ មាតុភូមិកម្ពុជាដ៏បវរនៃយើង ។ សេរីភាព សន្តិភាព វឌ្ឍនភាព និងវិបុលសុខ ដែលយើងខ្ញុំជាយុវជនបាន និងកំពុងទទួលបាន មិនមែនកើតមកដោយចៃដន្យឡើយ គឺដោយសារគុណូបការៈ វីរៈភាព និងការលះបង់មិនអាចកាត់ថ្លៃបានរបស់* **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** *ក្នុងនាមជាមគ្គុទេសក៍ផ្តើមមួយរូប នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក៏ដូចជាមុខតំណែង និងតួនាទីសំខាន់ៗក្នុងឆាកនយោបាយ វប្បធម៌ សង្គម សេដ្ឋកិច្ច និងសាសនា ដែលសម្តេចបានបំពេញយ៉ាងខ្ជាប់ខ្ជួន ក្នុងបុព្វហេតុជាតិមាតុភូមិពិត ដែលយើងខ្ញុំជាយុវជន សូមទទួលយកជាគំរូដោយក្តីមោទនៈ និងចាត់ទុកជាមរតកមិនអាចកាត់ថ្លៃបាន ក្នុងក្រអៅបេះដូង ពីនេះតទៅជារៀងរហូត ។*

*យើងខ្ញុំសូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ សូមវិញ្ញាណក្ខន្ធ* **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** *បានទៅកាន់សុគតិភព សម្រេចបាននូវអរិយសច្ចៈទាំងបួនកុំបីឃ្លៀងឃ្លាតឡើយ។*

*សូម* **ឯកឧត្តម ប្រធានព្រឹទ្ធសភា** *មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីយើងខ្ញុំ។*

**ជ.គណៈកម្មាធិការ ស.ស.យ.ក ក្រសួងមហាផ្ទៃ**
**ប្រធាន**

នុត_សម្ផនា

**Hun Manet** added 9 new photos to the album: **រាជធានីភ្នំពេញ, ថ្ងៃពុធ ទី ៥ សីហា ២០១៥**.

Aug 7, 2015 at 7:49am •

ពិធីបំពាក់ឯកសណ្ឋាន និងសំណេះសំណាលជាមួយប្អូនៗយុវជនគណបក្សប្រជាជនកម្ពុជា សាខាបក្សអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។



**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ

**លេខ:** ០១៨/១៥ **គប.កអជ.** ស១

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃសៅរ៍ ៤ កើត ខែបឋមាសាឍ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា គ.ស.២០១៥

## សារលិខិតជូនពរ

### សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ក្នុងនាមគណៈកម្មាធិការ និងសមាជិក សមាជិកាគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមចូលរួមអបអរសាទរដោយស្មោះ ជាមួយនឹងមនោសញ្ចេតនារីករាយជាទីបំផុត ក្នុងឱកាសដែលគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា បានបោះឆ្នោតជ្រើសតាំង **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជា **ប្រធានគណបក្សប្រជាជនកម្ពុជា** ។

តួនាទីដឹកនាំដ៏កំពូលនេះ គឺជាការឆ្លើយតបយ៉ាងស័ក្តិសមចំពោះគុណូបការៈដ៏ធំធេងមិនអាចកាត់ថ្លៃបានរបស់ **សម្តេចប្រធាន** ដែលមានទាំងសមត្ថភាព បទពិសោធន៍ និងស្នាដៃជាក់ស្តែងយ៉ាងពិតប្រាកដលើទំព័រប្រវត្តិសាស្ត្រកម្ពុជា ។ យើងខ្ញុំទាំងអស់គ្នាសូមប្តេជ្ញាចិត្តថា នឹងដើរតាមមគ្គុទេសក៍ដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចប្រធាន** ដែលជានិច្ចកាល តែងតែខិតខំយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បទពិសោធន៍ និងភាពប៉ិនប្រសព្វ រក្សាបាននូវភាពសុខដុមរមនារបស់គណបក្ស និងសម្រេចដោះស្រាយនូវបញ្ហាធំៗរបស់ជាតិ នៅគ្រប់កាលៈទេសៈ និងគ្រប់ស្ថានភាព ការពារបានយ៉ាងរឹងមាំនូវបូរណភាពទឹកដី សន្តិភាព ស្ថេរភាពនយោបាយ ការបង្រួបបង្រួមជាតិ លើកកម្ពស់បាននូវកិត្យានុភាពជាតិ ដើម្បីការអភិវឌ្ឍឥតឈប់ឈររបស់មាតុភូមិ និងសុភមង្គលនៃប្រជាជនយើង ។

យើងខ្ញុំទាំងអស់គ្នា សូមគោរពជូនពរ **សម្តេចអគ្គមហាសេនាបតីតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** សូមបានប្រកបទៅដោយសុខភាពល្អ ពលានុភាពខ្លាំងក្លា ប្រាជ្ញាវាងវៃ អាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រះរាជាណាចក្រកម្ពុជា ឱ្យមានសុខសន្តិភាពយូរអង្វែង មានវឌ្ឍនភាព និងវិបុលភាពជារៀងរហូតតទៅ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានគណបក្សប្រជាជនកម្ពុជា** និងជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា ។

**ជ. គណៈអចិន្ត្រៃយ៍**

**ប្រធាន**

ជា សុផារ៉ា

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

លេខ: ៩៤៧ លគ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ.ថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ២០១៤

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ**

**ប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** : អំពីការណែនាំដល់សមាជិកគណបក្ស ឱ្យទៅចុះឈ្មោះបោះឆ្នោត ។

**យោង** : សេចក្ដីជូនដំណឹងលេខ ០៩.០០១/១៤ គ.ជ.ប/អគ្គ.ពស ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០១៤។

តាមកម្មវត្ថុ និងយោងខាងលើ **គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល** សូមជម្រាបជូន **ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រសួង ស្ថាប័ន** ជ្រាបថា : ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះ នឹងត្រូវចាប់ធ្វើពីថ្ងៃទី ០១ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ នៅតាមសាលាឃុំ សង្កាត់ ។

អាស្រ័យហេតុនេះ **សូមឯកឧត្តម លោកជំទាវ** យកចិត្តទុកដាក់ណែនាំជំរុញសមាជិកគណបក្ស និងអ្នកគាំទ្រគណបក្សដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត ឬអ្នកដែលទើបគ្រប់អាយុបោះឆ្នោត ឬអ្នកដែលទើបផ្លាស់ទីលំនៅមកពី ឃុំ សង្កាត់ផ្សេង ឱ្យទៅធ្វើការចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្នានៅតាមសាលាឃុំ សង្កាត់ ដែលបងប្អូនកំពុងរស់នៅ ។

សូមជូនពរឱ្យមានសុខភាពល្អ និងជ័យជម្នះ ។

**ប្រធានគណៈអចិន្ត្រៃយ៍**

**សាយ ឈុំ**

**<u>ចម្លងជូន</u>**

-សម្ដេច ឯកឧត្តម លោកជំទាវ ប្រធាន និងអនុប្រធានទី១

ក្រុមការងារថ្នាក់កណ្ដាលចុះជួយរាជធានី ខេត្ត

(ដើម្បីជួយជំរុញការអនុវត្ត)

## ៧.២. ឧទាហរណ៍ ឯកសារទាក់ទិននឹងញត្តិគាំទ្រគណបក្សកាន់អំណាច ឬប្រឆាំងគណបក្សជំទាស់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈបញ្ជាការឯកភាពសមរភូមិ
ព្រំដែនកម្ពុជា-ថៃ

**ញត្តិស្នើសុំ**

យើងខ្ញុំទាំងអស់គ្នាជានាយទាហាន នាយទាហានរង និង ពលទាហានទាំងអស់ដែលកំពុងបំពេញភារកិច្ចនៅសមរភូមិព្រំដែនកម្ពុជា-ថៃ សូមគោរពស្នើសុំ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង អ្នកតំណាងរាស្ត្រទាំងអស់ដកលោក កឹម សុខា ចេញពីអនុប្រធានទី១រដ្ឋសភា។ យើងខ្ញុំទាំងអស់គ្នាបានតាមដានយ៉ាងយកចិត្តទុកដាក់បំផុតអំពីសភាពការណ៍នយោបាយរបស់ប្រទេសជាតិ និងបានមើលឃើញពីសកម្មភាពដ៏ពិសពុលរបស់លោក កឹម សុខា អនុប្រធានទី១រដ្ឋសភា និង ជាអនុប្រធានគណបក្សសង្គ្រោះជាតិ ដែលកំពុងធ្វើការឃោសនាបោកប្រាស់ប្រជាពលរដ្ឋ ញុះញង់អុចអាលលាបពណ៌ បង្ករកំហឹងរើសអើងពូជសាសន៍ និងឈានទៅបង្កសង្គ្រាមផ្ទៃក្នុង ដែលមិនសមជាទង្វើរបស់ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ជាតិ។

ដើម្បីសុខសន្តិភាពរបស់ប្រទេសជាតិ និងការរស់នៅប្រកបដោយភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ ជាថ្មីម្តងទៀតយើងខ្ញុំទាំងអស់គ្នា សូមធ្វើការអំពាវនាវដល់សម្តេច ប្រធានរដ្ឋសភា និង អ្នកតំណាងរាស្ត្រទាំងអស់ មេត្តាដក លោក កឹម សុខា ចេញពីអនុប្រធានទី១រដ្ឋសភាឲ្យបានឆាប់តាមដែលអាចធ្វើបាន។

យើងខ្ញុំសង្ឃឹមថា សម្តេចប្រធាន និង អ្នកតំណាងរាស្ត្រទាំងអស់ និង ចាត់វិធានការតាមការស្នើសុំ របស់យើងខ្ញុំ និង ប្រជាពលរដ្ឋទាំងអស់ ជាក់ជាមិនខាន។

ប្រាសាទព្រះវិហារ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៥
តំណាងនាយទាហាន នាយទាហានរង និង ពលទាហានទាំងអស់
ដែលកំពុងបំពេញភារកិច្ចនៅសមរភូមិព្រំដែនកម្ពុជា-ថៃ
**អគ្គមេបញ្ជាការរង**
**អនុប្រធានទី១គណៈបញ្ជាការឯកភាព សមរភូមិព្រំដែនកម្ពុជា-ថៃ**
**នាយឧត្តមសេនីយ៍ គង់ គឹម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខ :..............................

រាជធានីភ្នំពេញ. ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០១៥

# ញត្តិគាំទ្រ

អគ្គស្នងការដ្ឋាននគរបាលជាតិ បានតាមដានយ៉ាងយកចិត្តទុកដាក់នូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំធ្វើបទបង្ហាញជាសាធារណៈ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី អំពីការផ្ទៀងផ្ទាត់ផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ក្នុងការកំណត់ខណ្ឌសីមាព្រំដែនជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងផែនទីដែលអង្គការសហប្រជាជាតិបាននាំយកមកឲ្យព្រះរាជាណាចក្រកម្ពុជាខ្ចីដើម្បីធ្វើការផ្ទៀងផ្ទាត់ ពិនិត្យភាពត្រឹមត្រូវ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការជាតិ អន្តរជាតិ ស្ថាប័នសង្គមស៊ីវិល និងបណ្តាញផ្សព្វផ្សាយព័ត៌មានផងដែរ។

តាមរយៈការធ្វើបទបង្ហាញ និងការបកស្រាយអំពីផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងផែនទីរបស់អង្គការសហប្រជាជាតិដោយអ្នកជំនាញកិច្ចការព្រំដែនរបស់រាជរដ្ឋាភិបាលកម្ពុជានោះ បានបង្ហាញលទ្ធផលយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាពិតជាបានប្រើប្រាស់ផែនទីខ្នាត១/១០០០០០ផលិតដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនពិតប្រាកដ មិនដូចការញុះញង់របស់ជនអគតិមួយចំនួនដែលធ្វើប្រជាភិថុត ដើម្បីកេងយកប្រយោជន៍ផ្នែកនយោបាយក្នុងគោលបំណងបង្កើតភាពវឹកវរ ចលាចលក្នុងសង្គម សំដៅផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជា។

សកម្មភាពជាប្រវត្តិសាស្ត្រនេះ ឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ពីការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលកន្លងមក **សម្តេច** បានយកអស់កម្លាំងកាយចិត្តតស៊ូរំដោះជាតិ ទឹកដីពីរបបប្រល័យពូជសាសន៍ ខិតខំការពារ ស្តារ និងកសាងប្រទេសជាតិ រួមចំណែកយ៉ាងធំធេងក្នុងការបង្កើតព្រះរាជាណាចក្រកម្ពុជាឡើងវិញ និងបានដឹកនាំកម្ពុជាឈានឆ្ពោះទៅរកការអភិវឌ្ឍន៍លើគ្រប់វិស័យមានទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាប្រទេសលើពិភពលោក។

កងកម្លាំងនគរបាលជាតិកម្ពុជាទូទាំងប្រទេស សូមធ្វើការថ្កោលទោសដាច់អហង្ការចំពោះល្បិចកលទុច្ចរិតមួលបង្កាច់រាជរដ្ឋាភិបាល និងសូមប្តេជ្ញាចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដោយមិនអនុញ្ញាតឲ្យឧបាយកលឆ្លៀតយកបញ្ហាផែនទី និងការកំណត់បង្គោលខណ្ឌសីមាបង្កភាពចលាចលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គមជាតិបានឡើយ។

អគ្គស្នងការនគរបាលជាតិ

នាយឧត្តមសេនីយ៍.នេត_សាវឿន

ព្រះរាជាណាចក្រកម្ពុជា
**ជាតិ សាសនា ព្រះមហាក្សត្រ**

**យោធភូមិភាគទី១**
**តំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី**

## ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា ជាមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង ព្រមទាំងពលទាហានទាំងអស់បានធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់ខ្ពស់បំផុត ចំពោះព្រឹត្តិការណ៍ជាតិជាប្រវត្តិសាស្រ្ត នៃការផ្ទៀងផ្ទាត់ផែនទី ព្រមទាំងការវាស់វែងព្រំប្រទល់ ទឹកដី និងដាក់បង្គោល ខ័ណ្ឌសីមា មានភាពត្រឹមត្រូវយ៉ាងពិតប្រាកដ រវាង កម្ពុជា និងវៀតណាម ។ ដោយការស្នើរសុំខ្ចី ពីសំណាក់**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ហើយអង្គការសហប្រជាជាតិ ក៏បានអនុញ្ញាតអោយ **សម្តេច តេជោ** ខ្ចីផែនទី ប្រទេសកម្ពុជា ដើម្បីមកផ្ទៀងផ្ទាត់ ជាមួយនឹងផែនទី ច្បាប់ដើមរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្នាត ១/១០០.០០០ ដែលកំពុងប្រើប្រាស់ ក្នុងការកំណត់ បោះបង្គោលព្រំដែនជាមួយប្រទេសជិតខាងយើងនេះ ។

ទន្ទឹមគ្នានេះ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់អោយយើង ជ្រួតជ្រាបយ៉ាងច្បាស់លាស់ ពីសេចក្តីថ្លែងការណ៍នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ នេះហើយគឺជាការឆ្លុះបញ្ចាំង អំពីសច្ចភាពភាពត្រឹមត្រូវ និងការខិតខំ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការវាស់វែងបោះបង្គោល និងការដោះស្រាយបញ្ហាព្រំដែន ដើម្បីធានាអោយបាននូវ បូរណៈភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា មិនអោយមានការបាត់បង់ សូម្បីមួយម៉ែត្រក្រឡាក៏ដោយ ។ ជាមួយគ្នានេះដែរ **សម្តេច តេជោ** ក៏សុំធ្វើការថ្កោលទោសទៅលើជនណា រឺក្រុមណា ដែលមានចេតនាបំភាន់ញុះញង់ ជាហេតុធ្វើអោយមានការភាន់ច្រឡំលើបញ្ហាព្រំសីមារបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបោកបញ្ឆោត ទឹកចិត្តស្នេហាជាតិ របស់ប្រជាពលរដ្ឋខ្មែរ ចំពោះជាតិមាតុភូមិរបស់ខ្លួន ។

យើងខ្ញុំទាំងអស់គ្នា សូមប្រកាសគាំទ្រ យ៉ាងពេញទំហឹងនិងយ៉ាងឧឡារិក បំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់បំផុត របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវ ឧត្តមគតិស្នេហាជាតិ ដ៏ឧត្តុងឧត្តម ក្នុងបុព្វហេតុការពារ អធិបតេយ្យភាព និងបូរណៈភាពទឹកដី របស់ជាតិមាតុភូមិ និងសូមគាំទ្រទាំងស្រុង ចំពោះរាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំ ប្រឹងប្រែងប្រកបដោយភាពទទួលខុសត្រូវខ្ពស់ បន្តចចារដោះស្រាយ បញ្ហាព្រំដែនជាមួយប្រទេសជិតខាង ។

ជាងនេះទៅទៀត យើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាចិត្ត យ៉ាងមុតមាំដើម្បីការពារអោយបានដាច់ខាត នូវ ជាតិ សាសនា ព្រះមហាក្សត្រ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរាជរដ្ឋាភិបាលស្របច្បាប់ ដែលប្រសូត្រចេញពីឆន្ទៈ ប្រជាពលរដ្ឋកម្ពុជា ដែលមាន **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ និងថែរក្សាការពារ សន្តិភាព ស្ថេរភាព សុវត្ថិភាពសន្តិសុខសណ្តាប់ធ្នាប់សង្គមដើម្បីប្រទេសជាតិ និងប្រជាពលរដ្ឋខ្មែរយើងហើយយើងខ្ញុំ និងប្រឆាំងអោយបានដាច់ខាត រាល់ចលនាបដិវត្តន៍ពណ៌ ។

ធ្វើនៅមណ្ឌលគិរី ថ្ងៃទី..១០.. ខែ..កញ្ញា..ឆ្នាំ២០១៥
**មេបញ្ជាការ**

ឧត្តមសេនីយ៍ត្រី **យឹន_រ៉េមរស្មី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គបញ្ជាការដ្ឋាន**

## ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជានាយទាហាន នាយទាហានរង និង ពលទាហាន ទូទាំងកងយោធពលខេមរភូមិន្ទ បានតាមដានយ៉ាងយកចិត្តទុកដាក់បំផុតនូវសេចក្តីថ្លែងការណ៍ប្រកបទៅដោយការទទួលខុសត្រូវខ្ពស់ ដែលមានអត្ថន័យក្នុងប្រវត្តិសាស្រ្ត របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ។

តាមរយៈសេចក្តីថ្លែងការណ៍នេះ ធ្វើឲ្យយើងខ្ញុំជានាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ មើលឃើញពីការខិតខំប្រឹងប្រែងប្រកបដោយភាពទន់ភ្លន់តែម៉ឺងម៉ាត់ហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់របស់សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាលក្នុងការថែរក្សាការពារអធិបតេយ្យភាពបូរណភាពទឹកដីពិសេសក្នុងការបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាងសំដៅកសាងបាននូវព្រំដែនមួយដែលមានសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការល្អ និង ការអភិវឌ្ឍន៍ ។

យើងខ្ញុំទាំងអស់គ្នាជានាយទាហាន នាយទាហានរង និង ពលទាហានទូទាំងកងយោធពលខេមរភូមិន្ទ សូមគាំទ្រទាំងស្រុងនូវសេចក្តីថ្លែងការណ៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្រ្តី** ស្តីពីបញ្ហាព្រំដែន ។

ទោះក្នុងតម្លៃណាក៏ដោយ យើងខ្ញុំទាំងអស់គ្នាជា នាយទាហាន នាយទាហានរង និងពលទាហាន សូមធ្វើការប្រឆាំងនិងថ្កោលទោសយ៉ាងដាច់ដាច់ខាត ចំពោះសកម្មភាពនិងទង្វើរបស់ជនអគតិមួយចំនួនដែលតែងតែប្រឌិតនិងចោទប្រកាន់ មួលបង្កាច់ទាំងងងឹតងងុលនាពេលកន្លងមកដើម្បីបំរើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួន បំផ្លាញដល់សុខសន្តិភាព ស្ថេរភាព និងភាពរស់នៅសុខសាន្តរបស់ប្រជាជនកម្ពុជាទាំងមូល ។

ប្រាសាទព្រះវិហារ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៥
**អគ្គមេបញ្ជាការរង នាយសេនាធិការចំរុះ**

ឧត្តមសេនីយ៍ គន់ គីម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គបញ្ជាការដ្ឋាន**
**កងពលធំពិសេសឆត្រយោង៩១១**

## ញត្តិគាំទ្រ

យើងខ្ញុំមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងពលទ័ពពិសេសឆត្រយោង ៩១១ សូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងតែបានបូជាកម្លាំងកាយចិត្ត ដោយប្រកាន់ខ្ជាប់នូវឧត្តមគតិស្នេហាជាតិ ក្នុងការការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ជាពិសេសក្នុងការដោះស្រាយបញ្ហា ព្រំដែនជាមួយប្រទេសជិតខាង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ចំពោះជោគវាសនារបស់ជាតិមាតុភូមិ។

ការផ្ទៀងផ្ទាត់រៀងផែនទីUTM ខ្នាត១/១០០.០០០ ចំនួន ១៨ ផ្ទាំង ដែលដឹកល់ទុកនៅអង្គការសហប្រជាជាតិ ជាមួយនឹងផែនទីខ្នាត១/១០០.០០០ ផលិតដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនកម្ពុជា-វៀតណាម នាព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ នៅវិមានសន្តិភាព ដោយមានសមាសភាពចូលរួមមកពីគ្រប់ភាគីពាក់ព័ន្ធ រួមមានតំណាងរាជរដ្ឋាភិបាលកម្ពុជា តំណាងគណបក្សប្រជាជនកម្ពុជា តំណាងគណបក្សសង្គ្រោះជាតិ តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច តំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតំណាងរាជបណ្ឌិតសភាកម្ពុជា បង្ហាញឱ្យឃើញច្បាស់ថា ផែនទីដែលអង្គការសហប្រជាជាតិនាំមក និងផែនទីដែលរាជរដ្ឋាភិបាល បាននិងកំពុងប្រើប្រាស់មានភាពដូចគ្នា។

លទ្ធផលនៃការផ្ទៀងផ្ទាត់ បង្ហាញឱ្យឃើញច្បាស់នូវភាពត្រឹមត្រូវពិតប្រាកដ នៃផែនទីដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងប្រើប្រាស់ បង្ហាញឱ្យឃើញអំពីការខិតខំប្រឹងប្រែង ប្រកបដោយមនសិការស្នេហាជាតិខ្ពស់ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចការពារអធិបតេយ្យភាព បូរណភាពទឹកដី និងបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀត អំពីនយោបាយបោកប្រាស់របស់ក្រុមអគតិ ដែលភូតកុហកបោកប្រាស់ មួលបង្កាច់ខុសពីការពិត ក្នុងគោលបំណងកេងចំណេញផលប្រយោជន៍នយោបាយ សម្រាប់ក្រុមមួយក្តាប់តូចរបស់ខ្លួន ដោយមិនគិតពីឧត្តមប្រយោជន៍ជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការថ្កោលទោសដាច់ខាត ចំពោះសកម្មភាពអគតិទាំងឡាយ ដែលព្យាយាមធ្វើនយោបាយប្រជាភិថុត ដើម្បីកេងចំណេញផលប្រយោជន៍សម្រាប់ក្រុមរបស់ខ្លួន ហើយតែងតែមួលបង្កាច់ចោទប្រកាន់ទាំងងងឹតងងល់ មកលើរាជរដ្ឋាភិបាល ដែលបាននិងកំពុងខំតខំប្រឹងប្រែង ប្រកបដោយមនសិការជាតិខ្ពស់ ដើម្បីធានាបាននូវផលប្រយោជន៍ជាតិ ក្នុងកិច្ចការព្រំដែន។

មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងពលទ័ពពិសេសឆត្រយោង៩១១ សូមប្រកាសថា ជានិច្ចកាលប្រកាន់ខ្ជាប់នូវគោលជំហរ គោរពអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនដាច់ខាតក្នុងការការពារ **ជាតិ សាសនា ព្រះមហាក្សត្រ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងគាំទ្រ អនុវត្តតាមគោលនយោបាយ និងវិធានការនានា របស់រាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជាពិតប្រាកដ ដើម្បីថែរក្សាការពារសន្តិភាព ស្ថិរភាព សុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម បម្រើឱ្យឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥

**មេបញ្ជាការ**

ឧត្តមសេនីយ៍ឯក.**ចាប_ភក្តី**

## ៧.៣. ឧទាហរណ៍ ឯកសារព័ត៌មានចុះផ្សាយស្តីពីការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋបម្រើប្រយោជន៍គណបក្សកាន់អំណាច

លោកផ្កាយមាស៤ ជា តារា ថាកងទ័ពជាទ័ពរបស់គណបក្សប្រជាជនកម្ពុជា

ដោយ ប្រាជ្ញ ចេវ

2015-07-29




មេទាហានផ្កាយមាស៤ នៃកងយោធពលខេមរភូមិន្ទម្នាក់ លើកឡើងថា ទាហាននៃកងយោធពលខេមរភូមិន្ទជារបស់គណបក្សប្រជាជនកម្ពុជា ព្រោះ លោក ហ៊ុន សែន ដែលជាប្រធានគណបក្សនេះជាអ្នកផ្គត់ផ្គង់ទាហាននាពេលបច្ចុប្បន្ន។ បញ្ហានេះ គណបក្សប្រឆាំង និងអ្នកវិភាគនយោបាយ ថាការលើកឡើងនេះ ខុសទៅនឹងរដ្ឋធម្មនុញ្ញ ដែលចែងពីកងកម្លាំងប្រដាប់អាវុធជាកងកម្លាំងរបស់រដ្ឋ មិនមែនជារបស់បក្សទេ និងទាមទារឲ្យមានការកែតម្រូវ។

អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាតំណាងគណៈមេបញ្ជាការឯកភាពសមរភូមិប្រាសាទព្រះវិហារ ផ្កាយមាស៤ លោក ជា តារា រំឭកទៅកងទ័ពថា កងទាហានទាំងអស់ជារបស់គណបក្សប្រជាជនកម្ពុជា និងជារបស់ប្រជាជន។ ថ្លែងនៅចំពោះមុខមន្ត្រីយោធា មន្ត្រីរដ្ឋាភិបាល និងវិស័យឯកជន មេទាហានផ្កាយមាស៤ ប្រចាំតំបន់ព្រះវិហារ នៅវិមានសន្តិភាព ថ្ងៃទី២៩ ខែកក្កដា លោក ជា តារា និយាយសម្តីស្មោះត្រង់របស់ខ្លួនថា កងទ័ពត្រូវការចូលរួមការពារជាតិ និងការពារមិនឲ្យមានបដិវត្តន៍ពណ៌៖ *«បើនិយាយឲ្យចំ កងទ័ព គឺជារបស់គណបក្សប្រជាជន ព្រោះសម្តេចតេជោជាអ្នកចិញ្ចឹមបីបាច់ថែរក្សា ដឹកនាំបញ្ជាកងទ័ព»*។

ការលើកឡើងរបស់ លោក ជា តារា នេះ គឺស្របទៅនឹងគណបក្សប្រជាជនកម្ពុជា បានដាក់បញ្ចូលសមាសភាពថ្នាក់ដឹកនាំកងកម្លាំងជាច្រើនរូប ជាសមាជិកគណៈកម្មការកណ្តាលរបស់គណបក្សកាន់អំណាចចាស់វស្សាមួយនេះ។ ក្នុងនោះក៏មាន លោក ជា តារា កាន់តួនាទីនៅក្នុងគណៈកម្មការកណ្តាលគណបក្សនេះដែរ។ ការបញ្ចូលថ្នាក់ដឹកនាំយោធា និងថ្នាក់ដឹកនាំកងរាជអាវុធហត្ថទៅក្នុងជួរដឹកនាំគណបក្សនេះ ត្រូវបានសាធារណជនរិះគន់យ៉ាងខ្លាំងដែលមន្ត្រីទាំងនោះទទួលប្រាក់ខែពីរដ្ឋ តែបែរជាបម្រើការងារឲ្យបក្សទៅវិញ។

ការលើកឡើងរបស់មន្ត្រីជាន់ខ្ពស់យោធាបែបនេះ ត្រូវបានអ្នកវិភាគនយោបាយលើកឡើងថា ជាកាយវិការមួយចង់បង្ហាញថា កងកម្លាំងឯករាជ្យរបស់រដ្ឋក្លាយទៅជាកម្មសិទ្ធិផ្ដាច់មុខរបស់គណបក្សកាន់អំណាច ហើយក៏អាចឆ្លុះបញ្ចាំងពីឥទ្ធិពលកងកម្លាំងយោធាក្នុងការការពារគណបក្សនេះនៅពេលចាញ់ឆ្នោតក៏ថាបាន។

ចំណែកអ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ លោក យ៉ែម បុញ្ញឫទ្ធិ សម្ដែងការសោកស្ដាយចំពោះការលើកឡើងរបស់ លោក ជា តាវា នេះ និងថា លោក ជា តាវា យល់ដឹងពីជាតិនៅមានកម្រិត។ អ្នកនាំពាក្យគណបក្សប្រឆាំងរូបនេះ ចង់ឃើញស្ថាប័ននីតិប្រតិបត្តិមានការកែតម្រូវនៅពេលខាងមុខ៖ *«យើងមានការសោកស្ដាយណាស់នូវអ្វីដែលបានលើកឡើង ព្រោះហាក់បីដូចជាមិនបានយល់អ្វីទៅហៅថា កងទ័ព ជាតិ អ្វីទៅនាយករដ្ឋមន្ត្រី»*។

ការអះអាងរបស់ លោក ជា តាវា ដែលថាកងយោធពលខេមរភូមិន្ទជាកងទ័ពរបស់គណបក្សប្រជាជនកម្ពុជា ហាក់ផ្ទុយពីការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថ្លែងកាលពីថ្ងៃទី២៣ កក្កដា ថា កងកម្លាំងប្រដាប់អាវុធ គឺជាឧបករណ៍របស់រដ្ឋក្នុងកិច្ចការពារជាតិ ការពាររដ្ឋធម្មនុញ្ញ និងការពាររដ្ឋាភិបាលស្របច្បាប់។

អ្នកជំនាញផ្នែកវិទ្យាសាស្ត្រនយោបាយ លោកបណ្ឌិត រស់ រ៉ាវុធ មានប្រសាសន៍ថា កងប្រដាប់អាវុធគ្រប់ប្រភេទរបស់ជាតិបើកប្រាក់ខែពីជាតិ ត្រូវបម្រើជាតិ មិនមែនបក្សទេ។ លោកបណ្ឌិតស្នើឲ្យ លោក ជា តាវា កែតម្រូវការលើកឡើងបែបនេះ ព្រោះផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញរបស់ជាតិ៖ *«តាមទៅមិនត្រឹមត្រូវទេពាក្យនេះ ពីព្រោះកងទ័ព គឺជារបស់ជាតិ ការពារប្រយោជន៍ជាតិ មិនមែនការពារគណបក្សណាមួយទេ ចឹងគាត់មានកាតព្វកិច្ចមួយការពារជាតិ មិនមែនកងទ័ពការពារគណបក្សទេ»*។

ច្បាប់ស្ដីពីសហលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ មាត្រា១ ចែងថា កងយោធពលខេមរភូមិន្ទ មានភារកិច្ចបម្រើប្រទេសជាតិ។ បេសកកម្មរបស់កងយោធពលខេមរភូមិន្ទ គឺត្រូវរៀបចំកម្លាំងដើម្បីការពារ កសាងមាតុភូមិ និងដើម្បីបម្រើផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិ។

ទោះបែបនេះក្ដី អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក ឈឹម ផលវរុណ គាំទ្រការលើកឡើងរបស់ លោក ជា តាវា ព្រោះរដ្ឋាភិបាលកម្ពុជា សព្វថ្ងៃដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដូចនេះទាហានមិនអាចទៅការពារគណបក្សផ្សេងបានទេ។ លោកបន្ថែមទៀតថា ពាក្យដែលលើកឡើងថា នាយករដ្ឋមន្ត្រីចិញ្ចឹមទាហាន គឺមានន័យថា នាយករដ្ឋមន្ត្រីគ្រប់គ្រងទាហាន៖ *«គោលនយោបាយរដ្ឋាភិបាល ជាគោលនយោបាយរបស់គណបក្សឈ្នះឆ្នោត ហើយបច្ចុប្បន្នជាគោលនយោបាយរបស់គណបក្សប្រជាជន មានន័យថា ការពារគណបក្សឈ្នះឆ្នោតនេះឯង»*។

យ៉ាងណាក៏ដោយចុះ អ្នកជំនាញផ្នែកវិទ្យាសាស្ត្រនយោបាយ លោកបណ្ឌិត រស់ វ៉ាវុធ ពន្យល់ថា កងកម្លាំងបាត់បង់អព្យាក្រឹតភាព ប្រសិនបើគណបក្សនយោបាយផ្សេងឈ្នះឆ្នោតឈានដល់ការកាន់អំណាចនៅពេលខាងមុខ អាចនឹងមានរដ្ឋប្រហារយោធា ឬក្លាយជារបបផ្តាច់ការមួយ ប៉ុន្តែលោកថា ក្នុងបរិបថប្រទេសកម្ពុជា សព្វថ្ងៃ មិនអាចកើតមានរឿងនេះបានទេ ហើយនេះគ្រាន់តែជាការបញ្ចេញមតិរបស់មេទ័ពម្នាក់ប៉ុណ្ណោះ៕

http://www.rfa.org/khmer/news/politics/Dara-said-RCAF-is-belong-to-CPP-07282015235842.html

## នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង ប្រាប់ប្រជាពលរដ្ឋ ឲ្យជឿជាក់លើដឹកនាំ របស់សម្តេចតេជោ

គេហទំព័រ ប្រៃសណីយ៍៖

**(កណ្តាល)៖** នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានគណៈពង្រឹងខេត្តកណ្តាល និងជាប្រធានក្រុមការងារ ថ្នាក់ជាតិប្រចាំស្រុកកណ្តាលស្ទឹង បានប្រាប់ឲ្យប្រជាពលរដ្ឋ ជឿជាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា ទាំងលើការដឹកនាំ និងការការពារបូរណភាពទឹកដី។

ការថ្លែងរបស់នាយឧត្តមសេនីយ៍កិត្តិបណ្ឌិត ហ៊ីង ប៊ុនហៀង បានធ្វើឡើងនៅព្រឹកថ្ងៃសុក្រ ទី១៦ ខែតុលា ឆ្នាំ២០១៥ នេះ ក្នុងឱកាសដែលរូបលោក អញ្ជើញចុះសំណេះសំណាល ជាមួយសមាជិកគណបក្សប្រជាជនកម្ពុជា និងប្រជាពលរដ្ឋចំនួន ៣.៨៤២នាក់ ស្ថិតនៅ ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង។

នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង បានក្រើនរំលឹក និងបញ្ជាក់ជាថ្មីដល់ប្រជាពលរដ្ឋ ក៏ដូចជា សមាជិកគណបក្សប្រជាជនទាំងអស់ ត្រូវមានទំនុកចិត្តលើការដឹកនាំ របស់សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋាភិបាលកម្ពុជា ដែលបានខិតខំយកចិត្តទុកដាក់ ធ្វើការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ដោយប្រយ័ត្នប្រយែងបំផុត។

នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង បានបន្តថា ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការផ្ទៀងផ្ទាត់ផែនទីកម្ពុជា ដែលខ្ចីពី អង្គការសហប្រជាជាតិឃើញថា មានលក្ខណៈដូចគ្នា ទាំងស្រុងទៅនិងផែនទី រាជរដ្ឋាភិបាលកំពុងប្រើ។

នាយឧត្តមសេនីយ៍ បានផ្តាំផ្ញើដល់ប្រជាពលរដ្ឋ ចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការកសាង និងអភិវឌ្ឍន៍ ជាសេសថែរក្សាសមិទ្ធផលនានា របស់រាជរដ្ឋាភិបាល ដែលមានសព្វថ្ងៃ ដើម្បីទុកជា

ប្រយោជន៍ ដល់កូនចៅជំនាន់ក្រោយៗទៀត និងកុំចាញ់បោកការឃោសនា របស់ជនអគតិមួយចំនួន ដែលតែងតែយកបញ្ហាព្រំដែន និងបញ្ហាទំនាស់ដីធ្លី ជាដើមយកមកញុះញង់ប្រជាពលរដ្ឋ ក្នុងន័យកេងចំណេញ ខាងនយោបាយបម្រើបក្ស របស់ពួកគេតែប៉ុណ្ណោះ។

នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង បានបញ្ជាក់យ៉ាងដូច្នេះ «**សូមពុក ម៉ែ បងប្អូន ត្រូវជឿជាក់ និងចូលរួមគាំទ្រដល់ កិច្ចដំណើរការខិតខំប្រឹងប្រែង ដោះស្រាយបញ្ហាព្រំដែន និងបញ្ហាដទៃទៀត របស់រាជរដ្ឋាភិបាល ដើម្បីសុខសន្តិភាពមិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ជាមួយប្រទេសជិតខាង**»។

ក្នុងនោះដែរ ឯឧ បាននាំយកអំណោយដ៏ថ្លៃថ្លា របស់សម្តេចតេជោ និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ចែកជូនផ្ទាល់ដៃដល់សមាជិកបក្ស និងប្រជាពលរដ្ឋលោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ និងថវិកា ១.០០០ដុល្លារ ស៊ីម៉ង់ត៍ ១០តោន ប្រគេនដល់វត្តក្រាំងគន្ធរ និងសម្ភារៈមួយចំនួនផងដែ៕

http://www.freshnewsasia.com/index.php/en/11339-2015-10-17-04-02-14.html





## ៧.៤. សារព័ត៌មានចុះផ្សាយទាក់ទិននឹងការចេញផ្សាយនៃរបាយការណ៍

**អង្គការមួយថាប្រជាធិបតេយ្យនៅកម្ពុជាកំពុងរងការគំរាមកំហែងពីបក្សកាន់អំណាច**

ដោយ លោក ញឹម សុខន | ថ្ងៃអង្គារ ទី២៩ ខែមីនា ឆ្នាំ២០១៦




នាយកប្រតិបត្តិអង្គការឃ្លាំមើលការបោះឆ្នោតហៅកាត់ខុមហ្វ្រែល លោក គល់ បញ្ញា

អង្គការឃ្លាំមើលការបោះឆ្នោតមួយអះអាងថាប្រជាធិបតេយ្យនៅកម្ពុជាកំពុងរងការគំរាមកំហែងពីគណបក្សកំពុងគ្រប់គ្រងអំណាចដូចជាការរឹតបន្តឹងសេរីភាពបញ្ចេញមតិ គំរាមកំហែងលើបក្សប្រឆាំង និងការប្រើអំណាចរដ្ឋាភិបាល រំលោភលើស្ថាប័នជាតិកំពូលៗរួមមានរដ្ឋសភានិងតុលាការជាដើម។

ក្នុងសន្និសីទសារព័ត៌មាននាព្រឹកថ្ងៃទី២៩ខែមីនានេះនាយកប្រតិបត្តិអង្គការឃ្លាំមើលការបោះឆ្នោតហៅកាត់ខុមហ្វ្រែល លោក គល់ បញ្ញា ថ្លែងថាតាមរបាយការណ៍អង្កេតប្រចាំឆ្នាំលោកថាប្រជាធិបតេយ្យនៅកម្ពុជាកំពុងគំរាមកំហែងធ្ងន់ធ្ងរពីគណបក្សកំពុងគ្រប់គ្រងអំណាច។

លោកបន្តថា៖ "យើងមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីដំណើការប្រជាធិបតេយ្យនៅកម្ពុជាដោយសារការបង្ក្រាបដោយរាជរដ្ឋាភិបាលនិងការធ្វើទុក្ខបុកម្នេញ ការវាយប្រហារហិង្សាប្រឆាំងនឹងអ្នកតំណាងរាស្ត្រ និងការចាប់ដាក់ពន្ធនាគារ លើសមាជិកព្រឹទ្ធសភានិងសកម្មជននៃបក្សប្រឆាំង នេះជាការព្រួយបារម្ភធ្ងន់ធ្ងរទៅលើដំណើរការប្រជាធិបតេយ្យនៅកម្ពុជា"។

លោក គល់ បញ្ញា ឲ្យដឹងទៀតថាប្រជាធិបតេយ្យមិនមែនមានន័យថាគ្រាន់តែបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ហើយចប់នោះទេ តែលោកថារដ្ឋាភិបាលត្រូវធានាពីសិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពបង្កើតសមាគម ពិសេសលោកថា មន្ត្រីបក្សប្រឆាំងដើរតួនាទីសំខាន់ក្នុងការជំរុញឲ្យមានការតស៊ូមតិ តែលោកថាសេរីភាពទាំងនោះត្រូវបានបង្ក្រាប។

មន្ត្រីសង្គមស៊ីវិលរូបនោះឲ្យដឹងទៀតថាក្រៅពីប្រើអាជ្ញាធររដ្ឋគំរាមកំហែងលើមន្ត្រីបក្សប្រឆាំង លោកថារដ្ឋាភិបាលភិបាលក៏បានធ្វើច្បាប់គ្រប់គ្រងអង្គការសង្គមស៊ីវិលដែលលោកថាជាឧបករណ៍សម្រាប់រដ្ឋាភិបាលកម្រិតសិទ្ធិអង្គការសង្គមស៊ីវិលណាដែលហ៊ានរិះគន់ពីភាពខ្វះចន្លោះរបស់រដ្ឋាភិបាល។

ជាងនេះទៀតមន្ត្រីសម្របសម្រួលជាន់ខ្ពស់របស់អង្គការនេះគឺលោក គឹម ឈន លើកឡើងដែរថាដំណើរការប្រជាធិបតេយ្យនៅកម្ពុជានឹងគ្រោះថ្នាក់ជាងនេះទៀតបើសេរីភាពបញ្ចេញមតិតាមបណ្តាញសង្គមរបស់យុវជនដែលលោកថាបានចូលរួមបញ្ចេញមតិយ៉ាងសកម្មនោះត្រូវបានរដ្ឋាភិបាលរឹតបន្តឹងទៀតនោះ។

លោកបន្ថែមថា៖ "បើសិនជារដ្ឋយកប្រព័ន្ធអ្នកប្រើប្រាស់បណ្តាញសង្គមនេះធ្វើបញ្ហាចំបងទៅលើការរិតត្បិតសេរីភាពហ្នឹង អញ្ចឹងអាការចូលរួមក្នុងការបញ្ចេញមតិហ្នឹង ការចូលរួមផ្តល់យោបល់តាមរយៈប្រព័ន្ធបណ្តាញសង្គមអីហ្នឹង គឺថាវាអាចធ្វើឲ្យមានការរួមតូច"។

ក្រៅពីធ្វើសន្និសិទ អង្គការខុមហ្វ្រែលបានចេញរបាយការណ៍អង្កេតពីរដាក់ដោយឡែកពីគ្នា គឺរបាយការណ៍ស្តីពីការឃ្លាំមើលដំណើរការប្រជាធិបតេយ្យ និងរបាយការណ៍អង្កេតស្តីពីភាពមិនប្រក្រតីនិងអំពើពុករលួយផ្នែកនយោបាយ។

របាយការណ៍បង្ហាញថា នៅឆ្នាំ២០១៥អំពើពុករលួយផ្នែកនយោបាយមាន២៩៧ករណី ចំនួននេះខុមហ្វ្រែលថា បានកើនឡើង៨០ករណីបើប្រៀបធៀបនឹងឆ្នាំ២០១៤។ ក្នុងនោះ១៣៥ករណីអង្គការនោះអះអាងថាទាក់ទិននឹងភាពមិនប្រក្រតីនៃសំណូកនិងការកិបកេងប្រព្រឹត្តដោយមន្ត្រីសាធារណៈ។ ១៣៣ករណីពាក់ព័ន្ធការប្រើប្រាស់ធនធានរដ្ឋមានទាំងធនធានមនុស្សនិងសម្ភារសម្រាប់បំរើជាប្រយោជន៍នយោបាយដល់បក្សកាន់អំណាច។ ១១ករណីទាក់ទិននឹងការរំលោភអំណាចធ្ងន់ធ្ងរប្រព្រឹត្តដោយថ្នាក់ដឹកនាំរដ្ឋាភិបាលទៅលើស្ថាប័នរដ្ឋសភានិងតុលាការ។

អង្គការខុមហ្វ្រែលលើកឡើងទៀតថាការដកអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ និងដកអភ័យឯកសិទ្ធិ លោក សម រង្ស៊ី មន្ត្រីសង្គមស៊ីវិលថាធ្វើឡើងខុសរដ្ឋធម្មនុញ្ញដោយមិនបានអនុឡោមទៅតាមសំឡេង២ភាគ៣នោះទេ។ ខុមហ្វ្រែល ក៏កត់សំគាល់ទៀតថាការដកតំណែងលោក កឹម សុខា ពីអនុប្រធានទី១នៃរដ្ឋសភាគឺបានធ្វើឡើងក្រោយពីមានការប្រតិកម្មពីនាយករដ្ឋមន្ត្រី។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន បានច្រានចោលរបាយការណ៍និងការលើកឡើង របស់អង្គការខុមហ្វ្រែលដោយអះអាងថាចំណាត់ការកន្លងទៅលើមន្ត្រីបក្សប្រឆាំង លោកថាជាវិធានការច្បាប់។

អ្នកនាំពាក្យគណបក្សកំពុងគ្រប់គ្រងអំណាចរូបនោះបានវាយបកវិញថារបាយការណ៍របស់ខុមហ្វ្រែលហាក់គាំទ្រទៅលើសកម្មភាពរបស់គណបក្សប្រឆាំង។ លោកថា៖ "ឯកឧត្តម ហុង សុខហួរ គាត់ល្មើសច្បាប់ហើយប្រព្រឹត្តជាក់ស្តែង អាហ្នឹងត្រូវតែមានវិធានការផ្លូវច្បាប់បាទ។ អញ្ចឹងទេ អត់មានទៅគំរាមកំហែងអីយកប្រព័ន្ធតុលាការទៅរំលោភច្បាប់អីទេ អត់ទេ ធ្វើត្រឹមត្រូវតាមផ្លូវច្បាប់ដើម្បីធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជាទៅជានីតិរដ្ឋ"។

ទោះជាយ៉ាងណាអង្គការឃ្លាំមើលការបោះឆ្នោតមួយនោះបានទទួលស្គាល់ថាកន្លងទៅរដ្ឋាភិបាលបានធ្វើកំណែទម្រង់ខ្លះរួមទាំងធ្វើកំណែទម្រង់ស្ថាប័នជាតិរៀបចំការបោះឆ្នោត គជប ដើម្បីឆ្លើយតបនឹងតម្រូវការនិងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ។

ប៉ុន្តែខុមហ្វ្រែលថាកំណែទម្រង់នោះមិនឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ពលរដ្ឋនិងគោលការណ៍ការលិទ្ធិប្រជាធិបតេយ្យទេ៕

## "កម្ពុជាជាប្រទេសប្រកាន់របបប្រជាធិបតេយ្យបែបផ្តាច់ការនិយម"



ដោយ ខែ សុណង

2016-03-29 RFA/Khe Sonorng

ទីប្រឹក្សាគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយ

សេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) លោក ម៉ៃឃើល ស៊ូលលីវ៉ាន់ (MICHAEL Sullivan) ថ្លែងក្នុងសន្និសីទកាសែតនៅថ្ងៃទី២៩ មីនា ឆ្នាំ២០១៦ នារាជធានីភ្នំពេញ។

អង្គការសង្គមស៊ីវិលដែលធ្វើការលើកស្ទួយកិច្ចការបោះឆ្នោត ធ្វើសន្និសីទកាសែតបង្ហាញរបាយការណ៍ និងវាយតម្លៃថា នៅឆ្នាំ២០១៥ មានការបង្ក្រាបដោយអាជ្ញាធររដ្ឋាភិបាល អំពើហិង្សាបំពានលើរាងកាយ និងការធ្វើទុក្ខបុកម្នេញទៅលើគណបក្សសង្គ្រោះជាតិ គឺជាការគំរាមកំហែងធ្ងន់ធ្ងរដល់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។ ការលើកឡើងនេះ ត្រូវមន្ត្រីរដ្ឋាភិបាលច្រានចោល។

អ្នកសិក្សាកិច្ចការបរទេសនិងស្ថានការណ៍នយោបាយបានហៅប្រទេសកម្ពុជា ថាជាប្រទេសប្រកាន់របបប្រជាធិបតេយ្យបែបផ្តាច់ការនិយម។

ទីប្រឹក្សាគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (COMFREL) លោក ម៉ៃឃើល ស៊ូលលីវ៉ាន់ (MICHAEL Sullivan) បានថ្លែងថា គណបក្សប្រឆាំងបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ប៉ុន្តែមិនអាចតទល់ប្រឆាំងនឹងប្រព័ន្ធនៃការរៀបចំការបោះឆ្នោតដែលមានស្រាប់បានឡើយ។

លោកថា មានការបង្ក្រាបទៅលើគណបក្សប្រឆាំង តាំងពីដំបូងមុនការបោះឆ្នោត ស្របពេលដែលគណបក្សកាន់អំណាចគឺរដ្ឋាភិបាលសន្យាកំណែទម្រង់ និងខិតខំធ្វើអ្វីផ្សេងៗនោះ៖ *«របបផ្តាច់ការនិយមតាមបែបការបោះឆ្នោតវាតែងតែធ្វើឲ្យមានដំណើរការបោះឆ្នោតជាធម្មតា ហើយដំណើរការបោះឆ្នោតនេះ ជាចំណុចសំខាន់ដែលធ្វើឲ្យគណបក្សកាន់អំណាចមានលទ្ធភាពប្រើប្រាស់ដំណើរការបោះឆ្នោតជាមធ្យោបាយ ដើម្បីគ្រប់គ្រង និងអនុវត្តដំណើរការផ្តាច់ការរបស់ខ្លួនតាមរយៈការបោះឆ្នោត ពោលគឺការប្រើប្រាស់ការបោះឆ្នោតគ្រាន់តែជាឧបករណ៍ដើម្បីបានអំណាច»*។

លោក ម៉ៃឃើល ស៊ូលលីវ៉ាន់ បញ្ជាក់ថា មានការបង្ក្រាបទៅលើសេរីភាពបញ្ចេញមតិ មានការប្រើអំពើហិង្សាវាយប្រហារលើអ្នកតវ៉ា ការចាប់អ្នកតំណាងរាស្ត្រ និងសកម្មជនបក្សប្រឆាំងនៅក្នុងអំឡុងពេលមុនការប្រកួតប្រជែងការបោះឆ្នោតមកដល់។

លោកថ្លែងបែបនេះ នៅក្នុងសន្និសីទកាសែតស្តីពី "របាយការណ៍ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់ប្រចាំឆ្នាំ២០១៥" នៅថ្ងៃ២៩ ខែមីនា នាការិយាល័យគណៈកម្មាធិការខុមហ្វ្រែល។

របាយការណ៍បានវាយតម្លៃថា នៅឆ្នាំ២០១៥ មានការបង្ក្រាបដោយអាជ្ញាធររដ្ឋាភិបាល មានអំពើហិង្សាបំពានលើរាងកាយ និងការធ្វើទុក្ខបុកម្នេញទៅលើគណបក្សសង្គ្រោះជាតិ គឺជាការគំរាម

កំហែងធ្ងន់ធ្ងរដល់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។ របាយការណ៍ឲ្យដឹងទៀតថា ដោយមូលហេតុនយោបាយមានការកើនឡើងនូវអំពើហិង្សាបំពានលើរូបរាងកាយ និងការធ្វើទុក្ខបុកម្នេញផ្សេងៗ ក្នុងនោះរួមមាន ការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី និងតំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភាដោយសាលាដំបូងរាជធានីភ្នំពេញ។ ការបោះឆ្នោតទម្លាក់លោក កឹម សុខា ចេញពីតំណែងអនុប្រធានទី១ នៃរដ្ឋសភា ការចោទប្រកាន់ និងការចាប់ខ្លួនតំណាងរាស្ត្រ និងសកម្មជនបក្សនេះដាក់ពន្ធនាគារ ព្រមទាំងចាប់ខ្លួន លោក ហុង សុខហួរ សមាជិកព្រឹទ្ធសភាគណបក្សសម រង្ស៊ី ផង ដែលបង្កើតជាចម្ងល់ និងសំណួរអំពីឯករាជភាព និងអព្យាក្រឹតភាពនៃប្រព័ន្ធតុលាការនៅកម្ពុជា។

ឆ្លើយតបបញ្ហានេះ អ្នកនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន មានប្រសាសន៍ថា ការបញ្ចេញរបាយការណ៍នេះគឺជាការបង្ហាញដោយគ្មានភាពស្មោះត្រង់ក្នុងការវិភាគឲ្យបានត្រឹមត្រូវទន្ទឹមនឹងពេលដែលរដ្ឋាភិបាលមានទិសដៅច្បាស់លាស់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងពង្រឹងនីតិរដ្ឋ និងកំណែទម្រង់តាមដានមន្ត្រីរាជការយុត្តិធម៌រហូតដល់ចៅក្រមនោះ។

លោក ផៃ ស៊ីផាន៖ *«ជាធម្មជាតិនៃអង្គការនោះ គឺជាអង្គការទទួលប្រាក់ពីបរទេស បម្រើផលប្រយោជន៍មួយដែលយើងសង្ស័យ គឺមិនមែនជាផលប្រយោជន៍ការពិត និងផលប្រយោជន៍របស់ពលរដ្ឋកម្ពុជាទេ។ ចំណែកទី២ ការលើកឡើងរបស់គេ តាំងពីការចាប់ផ្ដើមអង្គការហ្នឹងរហូតដល់ពេលនេះ មិនដែលឃើញសេវាកម្មរបស់រាជរដ្ឋាភិបាលមានភាពវិជ្ជមាន មានលក្ខណៈមួយដែលអាចធ្វើឲ្យមានភាពចម្រូងចម្រាសបាន គឺមិនដែលមានទេ គឺឃើញខ្មៅងងឹត»*។

ទោះជាយ៉ាងណា គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា បានស្នើឲ្យម្ចាស់ជំនួយ និងសហគមន៍អឺរ៉ុប យល់ឲ្យបានច្បាស់ កុំឲ្យគ្រាន់តែគាំទ្រដើម្បីតែស្ថិរភាពដែលអាចយល់ច្រឡំថា ការគាំទ្រនោះបានតែបង្កើតនូវរបបផ្ដាច់ការនិយមបែបបោះឆ្នោត ប៉ុន្តែគួរតែគាំទ្រឲ្យមានដំណើរការបោះឆ្នោត និងប្រជាធិបតេយ្យឲ្យរីកចម្រើនពិតប្រាកដទៅមុខនៅកម្ពុជា។

អង្គការនេះបានប្រមើលមើលថា ឥរិយាបថរបស់ម្ចាស់ជំនួយ ជាពិសេសសហគមន៍អឺរ៉ុបអាចប្រែប្រួលដោយប្រើប្រាស់ការដាក់ទណ្ឌកម្ម ប្រសិនបើការបោះឆ្នោតនៅពេលខាងមុខមិនត្រឹមត្រូវ និងមានការបន្លំសន្លឹកឆ្នោត។

នៅថ្ងៃដដែលគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ក៏បានបង្ហាញរបាយការណ៍ស្ដីអំពីភាពមិនប្រក្រតីផ្នែកនយោបាយ អំពើពុករលួយនយោបាយ និងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ មានចំនួន ២៩៧ករណី។ ចំនួននេះ មានការកើនឡើង ៨០ករណីដែលបានកត់ត្រាទុកកាលពីឆ្នាំ២០១៤។

បញ្ហាទាំងនោះ ពាក់ព័ន្ធនឹងការរំលោភអំណាចធ្ងន់ធ្ងរប្រព្រឹត្តដោយថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ថ្នាក់ដឹកនាំស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នតុលាការ ឬថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សនយោបាយជាដើម។ ក្រៅពីនោះគេក៏បានរាយការណ៍ពីភាពមិនប្រក្រតីនៃសំណូក ការកិបកេងប្រព្រឹត្តដោយមន្ត្រីសាធារណៈក្នុងមុខតំណែងក្នុងបំណងបម្រើផលប្រយោជន៍ឲ្យបក្សនយោបាយ និងការតែងតាំងសែស្រឡាយសាច់ញាតិចូលកាន់តំណែង។

តែទោះជាយ៉ាងណា អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន បានហៅរបាយការណ៍នេះថា ជារបាយការណ៍ព្រៃ៕

## ខុមហ្វ្រែលៈអំពើពុករលួយនយោបាយនិងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវមានការកើនឡើងរហូត២៩៧ករណី

ដោយ អេង គីមហុង29/03/2016 29/03/2016



គណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ ខុមហ្វ្រែល ។

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ហៅកាត់ថា ខុមហ្វ្រែល បានបង្ហាញរបាយការណ៍ប្រចាំឆ្នាំ២០១៥ ថា យ៉ាងហោចណាស់មាន២៩៧ករណី ដែលជាអំពើពុករលួយផ្នែកនយោបាយនិងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវប្រព្រឹត្តឡើងដោយរដ្ឋាភិបាលនៃគណបក្សកាន់អំណាច។ ចំនួននេះមានការកើនឡើងជាងឆ្នាំមុន៨០ករណី។**

ក្នុងចំណោម២៩៧ករណីនៃអំពើពុករលួយផ្នែកនយោបាយនិងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ គឺ១១ករណីពាក់ព័ន្ធការរំលោភអំណាចកើតចេញពីមន្ត្រី តុលាការ ព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល និង គណបក្សនយោបាយ។ ភាពមិនប្រក្រតីនិងការកិបកេងដោយមន្ត្រីសាធារណៈក្នុងមុខតំណែងមានចំនួន១៣៥ករណី។ ទាំងនេះគឺជាអំពើពុករលួយផ្នែកនយោបាយ។ ហើយ ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវដែលមានគោលបំណងបម្រើផលប្រយោជន៍ឲ្យគណបក្សនយោបាយមានចំនួន១៣៣ករណី។ ប៉ុន្តែការប្រើប្រាស់យានយន្តរបស់រដ្ឋមិនត្រឹមត្រូវមានការធ្លាក់ចុះ។ ការធ្លាក់ចុះក៏ដោយសារតែរដ្ឋាភិបាលបានដាក់ចេញនូវវិធានការណែនាំ និង ចាត់ការវិធាន

ការជាក់ស្តែងដោយក្រសួងមួយចំនួនដូចជាៈក្រសួងមហាផ្ទៃ។ ចំពោះករណីមិនប្រក្រតីនៃសំណូកនិងការកិបកេងរបស់មន្ត្រីនយោបាយមានអាណត្តិដោយការបោះឆ្នោតមាន១១ករណី និង ភាពមិនប្រក្រតីពាក់ព័ន្ធនឹងការតែងតាំងខ្សែស្រឡាយ សាច់ញាតិមានចំនួន៨ករណី។ ក្នុងពេលតែមួយនេះខុមប្រែ្វលក៏បានបង្ហាញពីដំណើរការប្រជាធិបតេយ្យ ការបោះឆ្នោត និង កំណែទម្រង់ប្រចាំឆ្នាំ២០១៥។ ប្រជាធិបតេយ្យនៅកម្ពុជាបានដើរថយក្រោយតាមរយៈការបង្រ្កាបដោយអាជ្ញាធរ រដ្ឋាភិបាលលើតំណាងរាស្រ្តនិងការធ្វើទុកបុកម្នេញទៅលើគណបក្សសង្រ្គោះជាតិ។ រួមនិងការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី ការបោះឆ្នោតទម្លាក់លោក កឹម សុខា ព្រមទាំងដាក់ពន្ធនាគារសកម្មជនទាំង១១នាក់របស់គណបក្សប្រឆាំងនិងការឃុំខ្លួន លោក ហុង សុខហួរ ព្រឹទ្ធសមាជិកមកពីគណបក្ស សម រង្ស៊ី ។

សម្រាប់ដំណើរការកំណែទម្រង់ពាក់ព័ន្ធអភិបាលកិច្ចនៅកម្ពុជា មានការជឿនលឿនក្នុងកម្រិតមានតំណត់នៅឡើយ បើទោះបីជាមានកំណែទម្រង់និងការឆ្លើយតបរកដំណោះស្រាយផ្សេងៗពីរដ្ឋាភិបាលជាពិសេសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រោយការបោះឆ្នោតយ៉ាងណាក៏ដោយ។

ប៉ុន្តែយ៉ាងណាក៏ដោយចំពោះចំណុចវិជ្ជមានដែលស្ថាប័នមួយលើកសសើរនោះគឺកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត និង ច្បាប់បោះឆ្នោតដែលមានទម្រង់ជាក់លាក់មួយត្រូវបានចាប់ផ្តើមធ្វើឡើង៕

# ការវិវត្តលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈដើរថយក្រោយក្នុងឆ្នាំ២០១៥

ដោយ ឃី សុវុត្ថី និង Tej Parikh | March 30, 2016

យោងតាមរបាយការណ៍ប្រចាំឆ្នាំដែលចេញដោយអង្គការឃ្លាំមើលមួយ បានឲ្យដឹងកាលពីម្សិលមិញថា ការវិវត្តលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាឃើញថា មានដំណើរថយក្រោយខ្លាំងកាលពីឆ្នាំមុន ដោយរដ្ឋាភិបាលបានរំលោភបំពានច្បាប់ឥតឈប់ឈរ បំបិទសេរីភាពនៃការបញ្ចេញមតិ និងមិនអើពើចំពោះអំពើពុករលួយដែលកំពុងបន្ត កើតមានក្នុងរដ្ឋាភិបាល។

លោក គល់ បញ្ញា នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ដែលបានចងក្រោយការសិក្សានេះបានព្រមានថា ប្រទេសកម្ពុជាកំពុងធ្វើដំណើររអាក់រអួលលើមាគ៌ារបស់ខ្លួនឆ្ពោះទៅ រកលទ្ធិប្រជាធិបតេយ្យ ដោយការបោះឆ្នោតឃុំ-សង្កាត់ និងការបោះឆ្នោតជាតិកាន់តែខិតជិតមកដល់ក្នុងរយៈពេលពីរឆ្នាំ ក្រោយនេះ។

លោកបានថ្លែងថា ‟រដ្ឋាភិបាលបានបង្ក្រាបទៅលើក្រុមប្រឆាំងកាលពីឆ្នាំមុន ដោយការបង្ករបួសស្នាមលើរាងកាយ ការឃាយីផ្លូវច្បាប់ និងការចាប់ខ្លួនជាដើម។ សេរីភាពក្នុងការធ្វើបាតុកម្មក៏ត្រូវបានរឹតត្បិតផងដែរ ហើយសេរីភាពនៃការជួបជុំគ្នាស្ថិតនៅក្រោមការគំរាមកំហែងជាមួយ ច្បាប់អង្គការមិនមែនរដ្ឋាភិបាលថ្មី″។

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានចូលជាធរមានកាលពីខែសីហា បើទោះជាមានកង្វល់យ៉ាងខ្លាំងពីប្រទេសផ្តល់ជំនួយ និងអង្គការសិទ្ធិមនុស្សនានា រួមទាំងគណៈកម្មាធិការខុមហ្វ្រែល ដែលបារម្ភថា ច្បាប់នេះនឹងត្រូវគេប្រើដើម្បីបន្ទុចបង្អាក់ ដល់ការងាររបស់អ្នកដែលរិះគន់គណបក្សកាន់អំណាច។

របាយការណ៍នេះបន្ថែមថា មានការរារាំងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអុីន ធឺណិតផងដែរកាលពីឆ្នាំមុន ដោយមានការផ្តន្ទាទោស និងការដាក់ពន្ធនាគារចំពោះពលរដ្ឋណាដែលសម្តែងមតិប្រឆាំង រដ្ឋាភិបាលតាមប្រព័ន្ធអុីនធឺណិត។ គណៈកម្មាធិការខុមហ្វ្រែល ក៏បានកត់សម្គាល់ផងដែរថា កាលពីឆ្នាំមុន មានឧទាហរណ៍ជាច្រើនពីប្រព័ន្ធតុលាការ ស្ថិតក្រោមឥទ្ធិពលគណបក្សប្រជាជនកម្ពុជា។

របាយការណ៍ដដែលនេះបន្តថា ‟សរុបមក មន្ត្រីគណបក្សសង្គ្រោះជាតិ និងអ្នកគាំទ្រ ត្រូវបានចោទប្រកាន់ ផ្តន្ទាទោស និងចាប់ដាក់ពន្ធនាការស្ថិតក្រោមស្ថានភាពដែលគួរឲ្យសង្ស័យ និងមិនត្រឹមត្រូវតាមផ្លូវច្បាប់″។

ការសិក្សាដាច់ដោយឡែកមួយទៀតដែលចេញដោយគណៈកម្មាធិការខុមហ្វ្រែល កាលពីម្សិលមិញបង្ហាញថា ករណីអំពើពុករលួយក្នុងជួររដ្ឋាភិបាលដែលត្រូវបានកត់ត្រាទុកបាន កើនឡើងប្រហែល៣៥ភាគរយកាលពីឆ្នាំមុន ផ្អែកលើព័ត៌មានដែលប្រមូលបានពីអង្គការសិទ្ធិមនុស្សនានា ការស្ទង់មតិសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយដែលគួរឲ្យទុកចិត្ត។

របាយការណ៍នេះបានរកឃើញថា ករណី ពុករលួយទាក់ទិននយោបាយដែលត្រូវបានកត់ត្រាទុក ២៥៧ករណីកាលពីឆ្នាំ មុន រួមមានករណីស៊ីសំណូក និងឆបោក១៣៥ករណី និង ករណីពាក់ព័ន្ធការប្រើប្រាស់ធនធានរបស់រដ្ឋមិនត្រឹមត្រូវ ១៣៣ករណី។ ការឃុបឃិតក្នុងការរំលោភអំណាចដើម្បីផលប្រយោជន៍នយោបាយគឺ "មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងអគ្គមេបញ្ជាការកងទ័ព ព្រមទាំងមន្ត្រីនគរបាលជាតិជាន់ខ្ពស់ផងដែរ"។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយបានមានប្រសាសន៍ថា មានទំនាក់ទំនងដោយផ្ទាល់ រវាងអំពើពុករលួយ ស្ថាប័នច្បាប់ទន់ខ្សោយ និងកង្វះគណនេយ្យភាពទូទៅក្នុងជួររដ្ឋាភិបាល ប៉ុន្តែបានលើកឡើងថា បើទោះជាដូច្នេះ គណបក្សកាន់អំណាចបានបង្ហាញពីសញ្ញាថាកាន់តែយកចិត្ត ទុកដាក់ចំពោះសាធារណជន។

លោកបានថ្លែងថា "ឥឡូវនេះយុវជនជាច្រើនបានចូលរួមសម្តែងមតិរបស់ខ្លួនក្នុងចំនួន ដ៏ច្រើន ហើយបើទោះជាគណបក្សកាន់ អំណាចមិនល្អឥតខ្ចោះក៏ដោយ ក៏ពួកគេឆ្លើយតបចំពោះសម្ពាធនេះដែរ ដោយព្យាយាមយកចិត្តអ្នកបោះឆ្នោត ដែលនេះជាដំណើរការលទ្ធិប្រជាធិបតេយ្យ"។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍ថា របាយការណ៍របស់គណៈកម្មាធិការខុមហ្វ្រែលបានមើលរំលងកំណែទម្រង់ ជាច្រើនដែលរដ្ឋាភិបាលបានធ្វើដើម្បីលើកកម្ពស់លទ្ធិប្រជាធិប តេយ្យ និងដាក់កម្រិតលើការប្រព្រឹត្តអំពើពុករលួយ។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា "អង្គការនេះមិនដែលនិយាយអ្វីវិជ្ជមានពីរដ្ឋាភិបាលឡើយ។ ខ្ញុំមិនយកចិត្តទុកដាក់ខ្លាំងចំពោះពួកគេទេ"។

លោកបានថ្លែងថា"ទី១ច្បាប់ប្រឆាំងអំពើពុករលួយធ្វើឡើងដើម្បី កែប្រែផ្នត់គំនិត និងឥរិយាបថរបស់មន្ត្រីរដ្ឋាភិបាល។ ទី២ យើងឃ្លាំមើលយ៉ាងដិតដល់អំពីភាពមិនប្រក្រតីទាក់ទងទ្រព្យសម្បត្តិក្នុងចំណោមក្រុមមន្ត្រី និងប្រជាពលរដ្ឋ"។

លោកបានបន្ថែមថា "ចំណែកលទ្ធិប្រជាធិបតេយ្យវិញ រដ្ឋមន្ត្រីជាន់ខ្ពស់ជាច្រើនបានចុះទៅកាន់មូលដ្ឋានដើម្បីសំណេះ សំណាលជាមួយប្រជាពលរដ្ឋដែលក្នុងនោះកែលម្អតួនាទីស្នូលរបស់ រដ្ឋាភិបាលឱ្យបានប្រសើរឡើងក្នុងនាមជាអ្នកផ្តល់សេវា"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានរិះគន់កាន់តែខ្លាំងជាងហ្នឹងទៀត ដោយចាត់ទុក គណៈកម្មាធិការខុមហ្វ្រែល ក្នុងចំណោម"ក្រុមជ្រុលនិយម" ដែលប្រឆាំងរដ្ឋាភិបាល។

លោក សុខ ឥសាន បានថ្លែងថា "យោងតាមការវាយតម្លៃរបស់ឥស្សរជនជាន់ខ្ពស់មួយចំនួន លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាមិនបានធ្លាក់ចុះទេ។ លោក ចន ឃើរី រដ្ឋមន្ត្រីការបរទេសអាមេរិក និងលោក បារ៉ាក់ អូបាម៉ា ប្រធានាធិបតីអាមេរិក បានវាយតម្លៃថា ប្រទេស កម្ពុជាទើបតែងើបផុតពីសង្គ្រាម ហើយកំពុង តែប្រសើរឡើង"។

លោកបានបន្ថែមថា "ប៉ុន្តែមានអ្នកជ្រុលនិយមខ្មែរមួយចំនួនដែលធ្វើការវាយតម្លៃបែបនេះ វាមិនត្រឹមត្រូវទេ"។

លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថា បើទោះជាមានការរីកចម្រើនក្នុងវិស័យមួយចំនួនក៏ដោយ ក៏លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះចង្អុលបង្ហាញឲ្យ ឃើញថា ចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ចំពោះបញ្ហាកំណែ ទម្រង់រដ្ឋាភិបាលជាលក្ខណៈប្រព័ន្ធដែរ។

លោកបានពន្យល់ថា អង្គភាពប្រឆាំងអំពើពុករលួយ និងស្ថាប័នតុលាការបន្តខ្វះឯករាជភាព មិនមានយន្តការសវនកម្មរបស់រដ្ឋាភិបាលដែលកំពុងដំណើរការ និងការប្រមូលចំណូលរបស់រដ្ឋ ហើយការចំណាយចេះតែបន្តដោយគ្មានតម្លាភាព។

លោកបានបន្ថែមថា "មានបញ្ហាច្រើនទៀតដែលត្រូវធ្វើនៅគ្រប់ថ្នាក់ទាំងអស់"៕ *សារុន*

# Cambodia's Democratic Progress Stymied in 2015

by Khy Sovuthy and Tej Parikh | March 30, 2016 | អានជាភាសាខ្មែរ

The evolution of Cambodia's democracy saw significant setbacks last year, with the government repeatedly violating the law, suppressing freedom of expression and overseeing continued state corruption, according to an annual report released by a watchdog on Tuesday.

Koul Panha, executive director of the Committee for Free and Fair Elections (Comfrel), which compiled the study, warned that Cambodia was faltering on its path to democracy with local and national elections approaching in the next two years.

"The government cracked down on the opposition last year—with physical assaults, legal harassment and arrests," he said. "The freedom to demonstrate was also restricted, and the freedom of association is under threat with the new NGO law."

The Law on Associations and Non-Governmental Organizations came into force in August, despite widespread concern from donors and rights organizations including Comfrel, who fear it will be used to impede the work of those critical of the ruling party.

The report adds that curbs to free speech also moved online last year with the prosecution and imprisonment of citizens who expressed anti-government opinions on the Internet. Comfrel also noted that the last year brought numerous examples of the judiciary being beholden to the CPP.

"In total, fourteen CNRP officials and supporters were charged, prosecuted and imprisoned under questionable and dubious legal circumstances," it says.

A separate study released on Tuesday by Comfrel shows that recorded instances of state-based corruption increased by about 35 percent last year, based on information gathered from rights groups, public surveys and trusted media outlets.

The report found 297 recorded cases of political corruption last year, including 135 cases of bribes and fraud and 133 related to the misuse of state resources. Complicit in the abuse of power for political gain were "senior government officials and commanders in chief of armed forces as well as senior national police officials," it says.

Political analyst Ou Virak said there was a direct connection between rife corruption, weak legal institutions and a general lack of government accountability, but said that despite its failings, the ruling party had shown signs of being more attentive to the public.

"A lot of young people are now taking part in expressing their own opinion, in massive numbers," he said. "And though the ruling party are not perfect, they are responding to this pressure to try to please voters—that's how democracy should work."

Council of Ministers spokesman Phay Siphan said Comfrel's reports overlooked numerous reforms the government had made to improve the state of democracy and limit corruption.

“That organization never says anything positive about the government. I don’t really pay much attention to them,” Mr. Siphan said.

“First, the Anti-Corruption Law is working to change the mindset and behavior of government officials. Secondly, we are more closely monitoring wealth irregularities among officials and citizens,” he said.

“As for democracy, high-ranking ministers do go to the grassroots to speak to people, which improves the government’s core role as a service provider.”

CPP spokesman Sok Eysan took his criticism a step further, counting Comfrel among “extremists” working against the government.

“According to the evaluation of some senior figures, democracy in Cambodia has not decreased,” Mr. Eysan said. “United States Secretary of State John Kerry and President Barack Obama even evaluated that Cambodia has been rescued from war and is getting better.”

“But there are some Cambodian extremists who make evaluations like this—it is not correct,” he added.

Despite progress in some areas, the research’s broad findings point to the pressing need for holistic and systematic government reforms, said Preap Kol, executive director of Transparency International Cambodia.

The state’s anti-corruption body and the judiciary continue to lack independence, there is not a functioning government audit mechanism, and state revenue collection and spending continue to be opaque, he explained.

“There are many things that need to be done at various levels.”

*sovuthy@cambodiadaily.com*, *parikh@cambodiadaily.com*